ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ស្នាដៃរឿងខ្លីពីរបបខ្មែរក្រហម នឹងនាំឱ្យមានការចងចាំនិងជួយឱ្យធូរស្បើយផ្លូវចិត្ត
- វត្តមាននៃការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តតាកែវ
- គង់ ច័ន្ទវ៉ាន់ណេង ម្ចាស់ជ័យលាភីរឿង «ព្រះអាទិត្យឥតពន្លឺ» និយាយពីប្រវត្តិឪពុកក្នុងរបបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៤៨ ខែសីហា ឆ្នាំ២០២០

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៤៨ ខែសីហា ឆ្នាំ២០២០


## មាតិកា


**សំបុត្រ**

◆ ស្នាដៃរឿងខ្លីពីរបបខ្មែរក្រហម ................ ១

**ផ្នែកឯកសារ**

◆ លេខាស្រុកជាំក្សាន្ត តំបន់ព្រះវិហារ ......... ៥
◆ យឹម សំបាត់ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ .. ៨
◆ វិញ មិញចូវ អនុសេនីយ៍ផ្កាយពីរ ............ ១០
◆ ហួយ ទូច ទទួលខុសត្រូវអង្គរ ............. ១២

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ រូបថតបង្ហាញពេលវេលានៃអំពើឧក្រិដ្ឋ... ១៤
◆ គង់ ច័ន្ទវ៉ាន់ណេង ម្ចាស់ជ័យ លាភី ........ ១៧
◆ អៀ ហុកនីម៖ ម្ចាស់ជ័យ លាភីរៀង ...... ១៩
◆ បូជាភ្លើង ................................... ២១
◆ ព្រលឹងប្ដីខ្ញុំនៅវិលវល់ ..................... ២៦
◆ ហោរទាយថា ប្អូនប្រុសខ្ញុំកំពុងរស់នៅ .. ៣០

**ផ្នែកច្បាប់**

◆ សាលក្រមសំណុំរឿង០០២/០២ ......... ៣៣

**ផ្នែកវេទិកាសាធារណៈ**

◆ មជ្ឈមណ្ឌលឯកសារកម្ពុជាបើក .......... ៤១
◆ វត្តមាននៃការិយាល័យស្រាវជ្រាវ........ ៤៥

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មី
ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

◆ សូត នៅ ៖ វេជ្ជបណ្ឌិត.................... ៤៧
◆ ព្រុំ ធុជ ៖ វេជ្ជបណ្ឌិត...................... ៤៩
◆ អែ វ៉ា ៖ អ្នកគ្រប់គ្រងសេវាកម្មអាហារដ្ឋាន ៥០
◆ ទន់ ឈុំ ៖ វេជ្ជបណ្ឌិត..................... ៥២
◆ ទេព គីមទ្រី ៖ គិលានុបដ្ឋាយិកា .......... ៥៤
◆ ព្រឹត្តិការណ៍ ថ្ងៃ១៥មេសា ................ ៥៧




កម្មករផ្នែករោងពុម្ពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-៧៩) កំពុងបោះពុម្ពទស្សនាវដ្ដីបដិវត្តន៍ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ៖** សុង ថាណៃ, សន ប៊ុនស៊ីម, មីឆែល វ៉ាឆុន, ហេឌី ហ្វ្រាយ, ប៊ិង ពីរិន្ទ, វេនី ខកហ្វៀល, កៅ សំរិទ្ធ, វ៉ាន់ថាន់ ពៅដារ៉ា និងឡុង ដានី **អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ថុនា,ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដារី **អ្នកបកប្រែ៖** ហូ ថុនា
**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ថុនា
**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង រ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org




# ស្នាដៃរឿងខ្លីពីរបបខ្មែរក្រហម

## នឹងនាំឱ្យមានការចងចាំ និងជួយឱ្យធូរស្បើយផ្លូវចិត្ត

*សោម ប៊ុនថន និង ដារ៉ារដ្ឋ មេត្តា*




លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការវាយតម្លៃប្រគល់វិញ្ញាបនបត្រ និងពានរង្វាន់ដល់ម្ចាស់ជ័យលាភី នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ៗ (សន ប៊ុនស៊ីម/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រឿងខ្លីទាក់ទងនឹងជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្រោមរបប «កម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត» ចំនួន ៩រឿង ក្នុងចំណោម ៦៧រឿង ត្រូវបានជ្រើសរើសចេញពីស្នាដៃរបស់អ្នកតែងនិពន្ធ និងអ្នកសរសេរជនជាតិខ្មែរៗ រឿងខ្លីទាំងនេះ ត្រូវបានសរសេរតាមវិធីសាស្ត្រផ្សេងដើម្បីរំពុកឡើងវិញពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ «ពីឆ្នាំ១៩៧៥-១៩៧៩» ដែលបានប្រព្រឹត្តអំពើឃោរឃៅ និងបណ្ដាលឲ្យប្រជាជនកម្ពុជាប្រមាណជាង ៣លាននាក់បានបាត់បង់អាយុជីវិតៗ ដោយឡែកនៅក្នុងរឿងខ្លីទាំងនេះអ្នកនិពន្ធបានសរសេរឡើងដោយមិនផ្ដោតតែទៅលើការឈឺចាប់ទុក្ខវេទនារបស់ប្រជាជន និងជីវិតផ្ទាល់ខ្លួនដែលបានឆ្លងកាត់ក្នុងកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត ទេ គឺអ្នកនិពន្ធបានសរសេររំលេចឡើងនូវវិធីសាស្ត្រដែលខ្លួនបានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហា និងយកឈ្នះលើរឿងរ៉ាវទាំងឡាយ

ដែលខ្លួនជួបប្រទះក្នុងរបបនោះ។ រឿងខ្លីទាំងនេះ គឺជាផ្នែកមួយ ដែលនឹងអាចជួយឲ្យប្រជាជន និងក្មេងជំនាន់ក្រោយគិតពិចារណាឡើងវិញពីការប្រព្រឹត្ត របស់ខ្មែរក្រហមមកលើប្រជាជន ជួយឲ្យមានការផ្សះផ្សានៅក្នុងសង្គម និងជួយឲ្យមានការធូរស្បើយផ្លូវចិត្តសម្រាប់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់ និងរស់រានមានជីវិត។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) មេដឹកនាំខ្មែរក្រហមបានប្រើវិធីសាស្ត្រនិពន្ធសរសេរសាច់រឿង ចម្រៀង ពាក្យស្លោកទាក់ទងនឹងបដិវត្តន៍ ដែលបង្កប់អត្ថន័យ ឈឺចាប់ គំនុំគំកួន និងការសងសឹក ដើម្បីឃោសនាដល់ប្រជាជន ហើយជាលទ្ធផលបានបណ្តាលឲ្យមានការសម្លាប់យ៉ាងរង្គាលនៅទូទាំង

**ចម្រៀងបដិវត្តន៍ខ្មែរក្រហម**
**អក្ខរាកូនៗ**

ឱៗពុកម៉ែទីស្នេហា    កូនសូមផ្ញើអក្សរាជូនពីចម្ងាយ
ដើម្បីថ្វាថ្លៃងថែងបរិយាយ    ជូនពុកម៉ែជិតឆ្ងាយជ្រាបសេចក្តី។
ម៉ែអើយចិត្តកូនគួចត្របាញ់    រំពុករលេញទឹកដល់អ្នកថ្លៃ
នឹកដល់បងប្អូនទាំងប្រុស ទាំងស្រី    ធ្លាប់រួមមេត្រីយ៉ាងកម្សត់។
បើតាមចិត្តកូនចង់ឆ្លៀតឱកាសយ៉ាងខ្លី    រហ័សទៅសួរសុខទុក្ខ
ប៉ុន្តែសព្វថ្ងៃកូនជាប់សម្រុក    ភារកិច្ចជាតិសព្វមុខដ៏ឧត្តម។
កូនៗកំពុងជួសជុលថ្នល់    កូនខំជំរុលផ្លូវរថភ្លើងធំ
កូនខំធ្វើស្ពានថ្មីៗមាំៗ    ដើម្បីរៀបចំសង្គមជាតិថ្មី។
កូនៗធ្វើការក្នុងរោងចក្រ    កូនប្រយុទ្ធគ្មានស្រាកខំត្បាញកាគី
ត្បាញផាឌឹមសខ្មៅរាប់ពាន់គី    ធ្វើគ្រឿងអនាម័យបម្រើអ្នក។
កូបបើកកប៉ាល់បើករថយន្ត    ខំដឹកជញ្ជូនយ៉ាងលឿនគ្រឹកគ្រាក់
អំបិលក្រណាត់និងសម្ភារ    បញ្ជូនទៅអ្នកតាមអង្គការ។
កូនកាន់កាំភ្លើងការពារជាតិ    កូនឆ្លៀតធ្វើស្រែទៅប្រាំងវស្សា
កូនបំពេញភារកិច្ចជាតិថ្លៃថ្លា    មិត្តភក្តិផងគ្នាស្រឡាញ់ជិតជុំ។
កូនបានដំណឹងយ៉ាងរីករាយថា    ភូមិយើងសព្វថ្ងៃប្រែស្រស់មនោរម្យ
ចំណែកពុកម៉ែក៏បានសុខុម    ក្រុមសាមគ្គីឧត្តមគ្មានព្រួយសោះ។
ចំណែកកូនៗនៅឯនាយ    បានសុខសប្បាយរីករាយទាំងអស់
កូនកសាងខ្លួនបម្រើនលោតផ្លោះ    អង្គការសោមនស្សស្រឡាញ់ពេញចិត្ត។
នេះគឺសុភមង្គលផងកូន    សូមពុកម៉ែបងប្អូនរួមអបអរពិត
ហើយរួមប្រជាជនយ៉ាងជិតស្និទ្ធ    កសាងជនបទថ្មីសម្បូរឯក។
ចិត្តកូននឹកម៉ែនោះក៏នឹក    តែកូនសូមទុកការនឹកមួយប៉ែក
ព្រោះជាតិមាតុភូមិដង្ហើយហៅស្រែក    បុត្រធីតាល្អឯកត្រូវតែឆ្លើយ។
ហេតុនេះកូនសូមផ្ញើអក្ខរា    ផ្ញើក្តីស្នេហាផ្ញើក្តីអាល័យ
សូមពុកម៉ែជ្រាបជាសេចក្តី    ហើយកក់ក្តៅរីករាយណាអ្នកណា។
កូនសូមគោរពជូនពរពីចម្ងាយ    ឱពុកម៉ែអើយសូមមានជោគជយា
មានអាយុយឺនយូរចូលរួមស្ថាបនា    សុភមង្គលថ្លៃថ្លាប្រជាជនយើង
មានអាយុយឺនយូរចូលរួមស្ថាបនា    សុភមង្គលថ្លៃថ្លាសមូហភាពអើយ។





ប្រទេស។ កេរដំណែលនៃអំពើហិង្សា និងឃោរឃៅពីរបបខ្មែរក្រហមជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់ប្រជាជន និងសង្គមកម្ពុជានាពេលបច្ចុប្បន្ន។

កាលពីឆ្នាំ២០០៣ កន្លងទៅ មជ្ឈមណ្ឌលឯកសារកម្ពុជា បានសហការជាមួយ សមាគមអ្នកនិពន្ធខ្មែរ បង្កើត «វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ» ក្នុងគោលបំណងលើកទឹកចិត្តប្រជាជនកម្ពុជាក្នុងការថែរក្សាប្រវត្តិសាស្ត្រសម្រាប់មនុស្សជំនាន់ក្រោយ, ការរំសាយកំហឹងចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត ដែលជនរងគ្រោះបានឆ្លងកាត់, ការចងចាំដែលជាវិធីសាស្ត្រអហិង្សាក្នុងការទប់ស្កាត់មិនឲ្យរបបនេះកើតឡើងម្តងទៀត និងជំរុញដល់ការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតក្នុងរបប៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។

តមកនៅក្នុងឆ្នាំ២០១៩ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយសមាគមអ្នកនិពន្ធខ្មែរ បានរៀបចំការប្រកួតជ្រើសរើសស្នាដៃតែងនិពន្ធរឿងខ្លីក្រោមប្រធានបទ «ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត» ក្នុងគោលបំណង៖ លើកកម្ពស់ការស្រាវជ្រាវ និងតែងនិពន្ធអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត និងដើម្បីរួមចំណែករក្សាឯកសារប្រវត្តិសាស្ត្រនៃជីវិត មនុស្សជាតិដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈស្នាដៃតែងនិពន្ធរបស់អ្នកនិពន្ធខ្មែរ អ្នកដែលនៅរស់រានមានជីវិត និងអ្នកដែលធ្លាប់បានដឹងឮរឿងរ៉ាវដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត។

ការទទួលស្នាដៃតែងនិពន្ធរឿងខ្លី គឺបានចាប់ផ្តើមពីខែតុលា ដល់ ចុងខែធ្នូ ឆ្នាំ ២០១៩ ដែលទទួលបានរឿងខ្លីសរុបចំនួន ៦៧រឿង។ ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០២០ ស្នាដៃរឿងខ្លីចំនួន៩ រួមមានរឿង ១) បាយក្តាំង ២) ពេលម៉ែឃ្លាតទៅ ៣) ស្នាមដំបៅ ៤) ក្រោមមេឃតែមួយ ៥) ព្រះអាទិត្យឥតពន្លឺ ៦) មួយថ្ងៃមួយយប់ ៧) ជើងមេឃពណ៌ក្រហម ៨) មិនព្រមរៀបការ និង ៩) អាប់សែ ត្រូវបានគណៈកម្មាធិការវាយតម្លៃ និងកំណែជ្រើសរើសយកដើម្បីទទួលជ័យលាភី។ ទោះបីយ៉ាងណា ការរៀបចំកម្មវិធីប្រគល់វិញ្ញាបនបត្រពានរង្វាន់ ត្រូវបានពន្យារពេលដោយសារការផ្ទុះឡើងនូវជំងឺកូវីដ-១៩ កាលពីអំឡុងចុងឆ្នាំ២០១៩ នៅទីក្រុងវូហាន ប្រទេសចិន និងបានរីករាលដាលយ៉ាងឆាប់រហ័សនៅទូទាំងសកលលោក និងប្រទេសកម្ពុជា។



លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា ប្រគល់វិញ្ញាបនបត្រ និងពានរង្វាន់ ដល់ម្ចាស់ជ័យលាភី ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០។
(សន ប៊ុនស៊ុម/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មកដល់ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២០ ពិធីប្រគល់វិញ្ញាបនបត្រ និងពានរង្វាន់ដល់អ្នកជាប់ជ័យលាភីទាំង៩រូបខាងលើ ត្រូវបានរៀបចំឡើងជាផ្លូវការ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីនេះត្រូវបានសមាគមអ្នកនិពន្ធខ្មែរ និងមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំឡើងយ៉ាងប្រុងប្រយ័ត្ន ដោយគោរពទៅតាមគោលការណ៍ណែនាំពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺវាស់កម្តៅ ពាក់ម៉ាស់ការពារ លាងសម្អាតដៃជាមួយទឹកអាល់កុល រក្សាគម្លាតសុវត្ថិភាព កំណត់សមាសភាព និងកំណត់ចំនួនអ្នកចូលរួមឲ្យនៅតិចបំផុត។

ក្រៅពីវិញ្ញាបនបត្រ និងពានរង្វាន់ គណៈអធិបតីក៏មានការចែកជូននូវសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, ឧប្បត្តិហេតុហាំបាលី, នៅពេលសង្គ្រាមរលត់ទៅរបស់អ្នកនិពន្ធឈ្មោះ អេលីហ្សាប៊ែត ប៊េកខ័រ,



ពានរង្វាន់សម្រាប់ម្ចាស់ស្នាដៃទាំង៩រូប ដែលជាប់ជ័យលាភីក្នុងការប្រកួតតែងនិពន្ធរឿងខ្លីពានរង្វាន់អក្សរសិល្ប៍ស៊ីករីត លើកទី១ ឆ្នាំ២០២០ ក្រោមប្រធានបទ «ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត» ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០។ (សន ប៊ុនស៊ីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បូជាភ្លើង, ដំណើរឆ្ពោះទៅកាន់សេរីភាព, ទស្សនាវដ្ដីស្វែងរកការពិត និងសៀវភៅជាច្រើនក្បាលទៀតដល់អ្នកនិពន្ធដើម្បីអាន និងទទួលចំណេះដឹងកាន់តែទូលំទូលាយអំពីប្រវត្តិសាស្ត្រ និងដើម្បីពង្រឹងសមត្ថភាពផ្នែកតែងនិពន្ធឲ្យកាន់តែល្អប្រសើរឡើង។

អ្នកនិពន្ធ អ៊ុច សំណាង មកពីស្រុកពញាឮ ខេត្តកណ្ដាល ដែលជាប់ជ័យលាភីលេខ១ នៅក្នុងពានរង្វាន់អក្សរសិល្ប៍ស៊ីករីតលើកទី១ ឆ្នាំ២០២០ នេះ បានរៀបរាប់ថា «រឿងបាយក្ដាំង» គឺបានសរសេរចេញពីរឿងរ៉ាវពិតនៅពេលដែលយោធាខ្មែរក្រហមបានជម្លៀសគាត់ និងក្រុមគ្រួសារទៅរស់នៅខេត្តបាត់ដំបង តំបន់៤ ភូមិភាគពាយ័ព្យ។ នៅទីនោះគាត់បានលាក់បាយក្ដាំងដែលប្រធានរោងបាយចែកឲ្យគាត់ ដើម្បីយកទៅចែកឲ្យបងប្អូនដែលជម្លៀសមកពីស្រុកកំណើតជាមួយគ្នាហូប។ ប៉ុន្តែគាត់ស្ទើរតែបាត់បង់អាយុជីវិតដោយសារបាយក្ដាំងនៅពេលនោះ ព្រោះគាត់ត្រូវបានកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមឈ្មោះ ហន ដែលគ្រប់គ្រងនៅការដ្ឋានសំណង់អាងទប់ទឹកត្រាំកងចោទប្រកាន់ថា «ក្បត់សមូហភាព»។ ប៉ុន្តែសំណាងល្អគាត់ត្រូវបានផ្ដល់ឱកាសឲ្យកែប្រែកំហុស និងលត់ដំខ្លួនម្ដងទៀត។ ទោះបីយ៉ាងណា នៅសម័យនោះគាត់ទទួលបានការស្រឡាញ់រាប់អានពីប្រធានរោងបាយដែលជាប្រជាជនមូលដ្ឋានរស់នៅតំបន់នោះដែរ។ ដូច្នេះគាត់មិនមានអារម្មណ៍ឯកោ ដូចប្រជាជនមួយចំនួនដែលជម្លៀសទៅជាមួយគាត់ឡើយ។ គាត់មានរឿងរ៉ាវជាច្រើនទៀតដែលគាត់បានជួបប្រទះ និងមិនបានសរសេររៀបរាប់អស់ឡើយ។ គាត់ចង់ឲ្យក្មេងជំនាន់ក្រោយបានដឹងរឿងរ៉ាវរបស់គាត់ ដើម្បីឲ្យក្មេងទាំងនោះយល់កាន់តែច្បាស់ពីរបបកម្ពុជាប្រជាធិបតេយ្យ និងដឹងថាមានរឿងអ្វីខ្លះបានកើតឡើងចំពោះប្រជាជន។

កម្មវិធីប្រកួតជ្រើសរើសស្នាដៃសរសេររឿងខ្លីពីរបបខ្មែរក្រហម នឹងជំរុញធ្វើឲ្យមានការចងចាំ និងការសិក្សាស្រាវជ្រាវកាន់តែស៊ីជម្រៅពីរបបនេះ។ ស្នាដៃទាំងនេះនឹងត្រូវប្រែសម្រួលជាភាសាអង់គ្លេស និងបោះពុម្ពនៅពេលខាងមុខ ដែលលោកគ្រូអ្នកគ្រូបង្រៀនអាចយកធ្វើជាឯកសារយោងសម្រាប់បង្រៀនដល់សិស្ស និងក្មេងជំនាន់ក្រោយឲ្យមានការយល់ដឹងពីប្រវត្តិសាស្ត្រ និងជួយទប់ស្កាត់មិនឲ្យរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) កើតមានម្ដងទៀត ហើយធានាថារឿងរ៉ាវដែលបានកើតនៅក្នុងរបបនោះនៅតែត្រូវបានសរសេរក្រង និងលើកមកនិយាយ។





# ទិត ឈន់ ហៅ យ៉ាត់ លេខាស្រុកជាំក្សាន្ត តំបន់ព្រះវិហារ

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D00៤២៩

ដារ៉ារដ្ឋ មេត្តា



កងចល័តកំពុងជីកប្រឡាយ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបាទឈ្មោះ ទិត ឈន់ ហៅ យ៉ាត់ ភេទប្រុស អាយុ៤២ឆ្នាំ ។ ខ្ញុំមានទីកន្លែងកំណើត នៅភូមិខ្វាង ឃុំបាត់ក្ដោង (បច្ចុប្បន្នឃុំរបៀប) ស្រុករវៀង ខេត្តព្រះវិហារ។ ខ្ញុំមានប្រពន្ធឈ្មោះ វណ្ណ សារេន មានកូនចំនួនប្រាំពីរនាក់ គឺប្រុសប្រាំ និងស្រីពីរនាក់។ កូនរបស់ខ្ញុំឈ្មោះ យ៉ាត់ ឈឿន ត្រូវបានអង្គការបញ្ជូនទៅខេត្តឧត្ដរមានជ័យ ចំណែកកូនៗផ្សេងៗទៀតនៅមន្ទីរឃុំឃាំងជាមួយប្រពន្ធខ្ញុំ។ ខ្ញុំមានឪពុកឈ្មោះ សូ ទិត (ស្លាប់) និងម្ដាយឈ្មោះ សោម រដ្ឋ មានមុខរបរធ្វើស្រែចម្ការ។ ខ្ញុំគឺជាកូនប្រុសតែម្នាក់នៅក្នុងគ្រួសារ។ មុនពេលកើតមានរដ្ឋប្រហារនៅឆ្នាំ១៩៧០ ខ្ញុំមានអាយុ១៥ឆ្នាំ។ ខ្ញុំធ្លាប់បួសជាព្រះសង្ឃនៅវត្តខ្វាវបានរយៈពេលប្រាំឆ្នាំខ្ញុំក៏បានសឹកមកជួយធ្វើស្រែឪពុកម្ដាយ។

នៅខែមិថុនា ឆ្នាំ១៩៧០ ខ្ញុំចូលបដិវត្តន៍ខ្មែរក្រហម នៅភូមិដូង ដោយចូលក្រុមឃោសនាដើរឃោសនាប្រាប់ប្រជាជនៗ នៅខែកក្កដា ឆ្នាំ១៩៧២ បងហង់ (លេខាតំបន់ ១០៣ និងជាលេខាគណៈមជ្ឈិមបក្សពលករ) ចាត់តាំងខ្ញុំឲ្យធ្វើជាលេខាស្រុកជាំក្សាន្តៗ ក្រោយមកនៅខែកញ្ញា ឆ្នាំ១៩៧២ បន្ទាប់ពីខ្ញុំទទួលផ្នែកពាណិជ្ជកម្ម ក៏មានការប្រជុំមួយដោយ អាន់ (ប្រធានវប្បធម៌តំបន់) ជាអ្នកដឹកនាំ រួមជាមួយ ហ្វា។ អ្នកទាំងពីរបានហៅ ខ្ញុំ, ថង, ភាព (អនុប្រធានកងចល័តសហករណ៍ព្រីងធំ), យ៉ាន (អនុប្រធានភូមិចលនា), ថុន (គណៈភូមិសង្គមនិយម) និង ពឿន មកបញ្ចូលជាសមាជិកបក្សពលករស្របច្បាប់ ដោយយកបក្សកុម្មុយនីស្តកម្ពុជាធ្វើជាឆ្នាក់ៗ នៅខែតុលា ឆ្នាំ១៩៧២ ដដែល មានការប្រជុំរៀនសូត្រ ពេលនោះ បងហង់ និង អាន់បានចាត់តាំងខ្ញុំឲ្យធ្វើជាអនុប្រធានស្រុកត្បែងមានជ័យ និងទទួលខុសត្រូវលើឃុំឈានមុខរហូតដល់ឆ្នាំ១៩៧៥ៗ

នៅខែធ្នូ ឆ្នាំ១៩៧៣ មានបើកការរៀនសូត្រមួយនៅតំបន់ ១០៣ ស្តីពីសភាពការណ៍នៅក្នុងប្រទេសៗ នៅពេលនោះមាន បងហង់ ជាអ្នកដឹកនាំ និងមានអ្នកចូលរួមផ្សេងទៀតរួមមាន ផែន (លេខាស្រុកជ័យសែន), កុក (នៅឡក្បៀង ស្រុកគូលែន), រិន (សមាជិកសហករណ៍តំបន់), ខែត, ឡៃ, ធិន (ប្រធានប៣១), ភាព, ថង, សាង, ឡុត, ធឿន, ពឿន (ប្រធានមន្ទីរតំបន់ផ្នែក២៨), សិទ្ធ (ប្រធាននារីឃុំសាមគ្គី), សារ៉ែន, ខុន (មន្ទីរតំបន់ផ្នែក៧៨), មេង (លេខាស្រុកកំពង់ស្រឡៅ), មី, មិន, បួរ, ដុន, សុរ, សាទ, ណាន, វ៉េត, យ៉ា, រិត (ប្រធានពាណិជ្ជកម្មតំបន់), ហ្វា, ពេញ (អនុប្រធានពាណិជ្ជកម្មភូមិភាគ), ហ៊ាន, ស្រួច, ផង់ (សមាជិកតំបន់), មួន និងមួយចំនួនទៀតដែលខ្ញុំមិនចាំឈ្មោះៗ នៅក្នុងការប្រជុំនោះ ហង់ បានលើកឡើងអំពីសភាពការណ៍វៀតណាម ដែលបានដកទ័ពចេញពីប្រទេសកម្ពុជា ហើយប្រទេសកម្ពុជាក៏មិនព្រមចរចាជាមួយវៀតណាម ដែលមិនអំណោយផលដល់យើងឡើយៗ

នៅខែធ្នូ ឆ្នាំ១៩៧៤ មានការប្រជុំមួយនៅវត្តខ្វាង ក្នុងឃុំសាមគ្គី ស្រុករវៀង ខេត្តព្រះវិហារៗ ការប្រជុំនោះគឺបានចាត់តាំង ភាពធ្វើជាលេខាស្រុកវិរភាព, ប៉ាង ធ្វើជាសមាជិកស្រុកត្បែងមានជ័យ, ប៉ុង (អនុលេខាស្រុកជាំក្សាន្ត), ខ្ញុំធ្វើជាអនុប្រធានស្រុកត្បែងមានជ័យៗ បន្ទាប់ពីចាត់តាំងរួចហើយ អាន់ បានអប់រំថា ឥឡូវនេះសភាពការណ៍បដិវត្តន៍ កាន់តែអំណោយផលដល់យើងក្នុងការយកជ័យជម្នះលើ លន់ នល់ ក្នុងឆ្នាំ ១៩៧៥ និងអាចឈានដល់ការយកជ័យជម្នះលើរដ្ឋអំណាចមិនខានៗ យើងត្រូវដឹកនាំកម្លាំងឲ្យបានច្រើនសម្រាប់ជាកម្លាំងស្នូលរបស់យើងៗ ខ្ញុំបានទទួលខុសត្រូវស្រុកត្បែងមានជ័យគឺ ទទួលឃុំឈានមុខៗ ខ្ញុំបានធ្វើសកម្មភាពជាមួយប្រជាជន ដោយធ្វើឲ្យប្រជាជនអត់បាយ ហើយមិនបានគិតគូរចំពោះជីវភាពប្រជាជន និងមិនគិតពីផលប្រយោជន៍ប្រជាជន ថែមទាំងធ្វើយ៉ាងណាឲ្យប្រជាជនអស់ជំនឿលើបដិវត្តន៍ៗ

ក្រោយមកនៅឆ្នាំ ១៩៧៥ ខ្ញុំក៏បានរៀបការៗ នៅខែមករា មានការប្រជុំនៅស្រុកត្បែងមានជ័យ ដែលមានអាន់ គឺជាអ្នកដឹកនាំប្រជុំៗ ការប្រជុំនោះគឺ តម្រូវធ្វើយ៉ាងណាសម្រចផែនការសហព័ន្ធឥណ្ឌូចិនៗ នៅខែមេសា ឆ្នាំ១៩៧៥ ក្រោយពីរំដោះប្រទេសរួចមានការប្រជុំមួយនៅស្រុកត្បែងមានជ័យ ដោយមានបង ហង់ជាប្រធានៗ បងហង់ បានលើកឡើងពីជ័យជម្នះនៅថ្ងៃទី ១៧ ខែមេសា លើក្រុម លន់ នល់ ហើយយើងបានមើលឃើញពីសភាពការណ៍ថ្មី គឺទំនាស់រវាងបក្សពលករ និងបក្សកុម្មុយនីស្តកម្ពុជាៗ បក្សកុម្មុនីស្តកម្ពុជាមិនចាយលុយ ហើយធ្វើខុសបដិវត្តន៍ទាំងអស់នៅក្នុងសកលលោកៗ នៅខែកក្កដា បងហង់បានចាត់តាំងខ្ញុំឲ្យទៅទទួលធ្វើជាលេខាស្រុកជាំក្សាន្តៗ

នៅឆ្នាំ១៩៧៦ ឈ្មោះ ឃៀន គឺជាលេខាតំបន់ ១០៣ បានធ្វើសន្និបាតផ្នែកក១ ដែលមានអ្នកចូលរួម៖ ឃៀន, ផែន, ខ្ញុំ, ប៉ុង, ធា (នារី ), ហាប់ (អនុប្រធានសហករណ៍ប្រមី), ជា, ហាន, អេន (អនុប្រធានសហករណ៍រំដោះស្រែប្រចាំភូមិតើល), ឃុត (ប្រធានវប្បធម៌ស្រុករវៀង), ហួន (ប្រធានពាណិជ្ជកម្មស្រុកជាំក្សាន្ត), ធៀន, រិធ, ស៊ុន, ណាន, តាំង, ថន, មាំ, អេង, ឃឿន, យ៉ាន, សាត, ពត់, ចំរើន, មេង, ខំ និងឈ្មោះមួយចំនួនទៀតដែលខ្ញុំចាំមិនអស់ៗ នៅក្នុងសន្និបាតផ្នែក (ក) នេះគឺសុទ្ធតែតំណាងបក្សពលករកម្ពុជាទាំងអស់ៗ នៅពេលសន្និបាតនោះឈ្មោះ ឃៀង គឺជាអ្នកឡើងនិយាយអំពីការងារដែលធ្វើយ៉ាងណាឲ្យស្របតាមបក្សកុម្មុយនីស្តកម្ពុជាៗ ឃៀន បានលើកពីសភាពការនៅក្នុងប្រទេស និងក្រៅប្រទេសៗ សភាពការណ៍នៅក្នុងប្រទេស គឺមាត៏របដិវត្តន៍កម្ពុជាដើរខុសមាត៏ក្នុងពិភពលោក និងសភាពការណ៍ក្រៅប្រទេសវៀតណាមជារៀមច្បងកំពុងតែត្រៀមវាយលុកកម្ពុជាដើម្បីយកជ័យជន្នះពីរដ្ឋអំណាចបក្សកុម្មុយនីស្តកម្ពុជាៗ

នៅខែមីនា ក្នុងឆ្នាំ១៩៧៧ មានការប្រជុំមួយនៅតំបន់ព្រះវិហារ នៅក្នុងស្រុករវៀងៗ អ្នកមកប្រជុំមាន ឃៀន, ផែន, សុន, មី, ស្វ, ស៊ុម, ផង់ និងមនុស្សជាច្រើនរូបទៀតដែលខ្ញុំមិនស្គាល់ឈ្មោះៗ នៅក្នុងការប្រជុំបានលើកអំពីផែនការសម្រាប់ឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ រំឭកអំពីផែនការនេះសារឡើងវិញៗ ហង់បានលើកឡើងអំពីបក្សកុម្មុយនីស្តកម្ពុជាមានការប្រែប្រួល ព្រោះបងៗមួយចំនួនត្រូវបានអង្គការចាប់ខ្លួន ដូចជា នៅភូមិភាគឧត្តរ សុត (លេខាតំបន់១០៦ សៀមរាប), បង យ៉ា (លេខាបក្សពលករកម្ពុជា) និង កែវ មាស (អនុលេខាបក្សពលករ), នន សួន (សមាជិកបក្សពលករ) រួមទាំងបក្ខពួកមួយចំនួនទៀតនៅទូទាំងប្រទេសកម្ពុជាក៏ត្រូវចាប់ខ្លួនដែរៗ ចំណែក ចក្រី ដែលជាប្រធានកងទ័ពមជ្ឈិមនៅខាងបូព៌ា ដែលជាកម្លាំងត្រៀមវាយបក្សកុម្មុយនីស្តកម្ពុជាក៏ត្រូវចាប់ខ្លួនដែរៗ បងហង់បានបន្ថែមថា យើងត្រូវត្រៀមស្រូវ អង្ករទុកនៅតំបន់ណាដែលងាយស្រួលដឹកជញ្ជូនៗ នៅខែកញ្ញា មានការប្រជុំនៅព្រះវិហារ មន្ទីរត្រលាប់ ដោយមានបងហង់ជាអ្នកដឹកនាំៗ បងហង់បានលើកឡើងពីការដណ្តើមជ័យជម្នះឲ្យបានមុនឆ្នាំ ១៩៧៨ ៗ តំបន់ព្រះវិហារស្ទុយ៉ត មិនចូលក្នុងភូមិភាគណាមួយឡើយ គឺគ្រាន់តែរាយការណ៍ដល់លេខាបក្សកុម្មុនីស្តកម្ពុជានៅភ្នំពេញៗ បន្ទាប់មកទៀត ខ្ញុំឃើញអង្គការចាប់បក្ខពួកខ្ញុំអស់មួយចំនួនទៀត ដូច្នេះ ខ្ញុំក៏បានរត់ទៅរកបក្ខពួករបស់ខ្ញុំធ្លាប់ធ្វើសកម្មភាពរួមគ្នា ក្នុងគោលបំណងប្រមូលកម្លាំងដែលនៅសេសសល់ដែលអង្គការមិនទាន់ចាប់ៗ បើយើងប្រឆាំងជាមួយបក្សកុម្មុនីស្តកម្ពុជាមិនឈ្នះ គឺនាំបក្ខពួករត់ទៅសៀម ដើម្បីទាក់ទងជាមួយ អ៊ិន តាំ ប៉ុន្តែនៅពេលរត់គេចខ្លួន ខ្ញុំក៏បានជួបប្រជាជនដែលកំពុងដាំដំណាំនៅចម្ការៗ ពេលនោះប្រជាជន ក៏បានចាប់ខ្លួនខ្ញុំយកមកដាក់នៅមន្ទីរឃុំឃាំងៗ

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ ទិត ឈន់ ហៅ យ៉ាត់ ពិតប្តុយ៉ាងណានោះទេៗ



កងចល័តយុវជនដើរនៅលើភ្លឺស្រែៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យឹម សំបាត់ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ បន្ទាប់ពីសង្ស័យរួមគំនិតបោកគ្រាប់បែក

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D00១៥១

*ដារ៉ារដ្ឋ មេត្តា*



*បន្ទប់ឃុំឃាំងអ្នកទោស នៅអតីតមន្ទីរសន្តិសុខស-២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ យឹម សំបាត់ ភេទប្រុស អាយុ២៥ឆ្នាំ (ឆ្នាំ១៩៧៦)។ ខ្ញុំមានទីកន្លែងកំណើត នៅភូមិព្រែកដំបូក ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ យឹម ហោ ឬ យឹម ឈឺន គឺជាអតីតប៉ូលីស (បច្ចុប្បន្ន យានដ្ឋានពាណិជ្ជកម្មទួលគោក) នៅខេត្តមណ្ឌលគិរី និងម្តាយឈ្មោះ អ៊ិន ពៅ រស់នៅស្រុកកំណើត និងមានបងស្រីម្នាក់ឈ្មោះ យឹម សារិន មានគ្រួសារ។

នៅខែធ្នូ ឆ្នាំ១៩៧០ ខ្ញុំបានចូលបម្រើបដិវត្តន៍មានអ្នកខទ្វេសនាមឈ្មោះ យិន (ប្រធានក្រុម១ អនុសេនាធំលេខ៩) និងបានចូលជាសមាជិកយុវកក (សម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា) នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧១ ដោយមានអ្នកខទ្វេសនាមឈ្មោះ តូច សឿន (ប្រធានយោធា អនុសេនាធំលេខ៣) និង ឡុង រី (អតីតប៉ូលីសនៅមណ្ឌលគិរី)។ ខ្ញុំមានតួនាទីជាប្រធានកងអនុសេនាតូចលេខ១ អនុសេនាធំលេខ៤១ វរសេនាតូចលេខ ៧៣២ វរសេនាធំ១៧៣។





នៅខែកុម្ភៈ ឆ្នាំ១៩៧៦ មិត្តសារិន (កម្មាភិបាលអនុសេនាធំលេខ ៤១) បានចាត់តាំងពេទ្យ ថន នៅកងអនុសេនាតូចលេខ ២, មិត្តណាត់ ប្រធានក្រុមក្នុងកងអនុសេនាតូចលេខ ២ ឲ្យចូលទៅបាញ់រះ នៅក្នុងសាលារចនា និងបាចខិត្តប័ណ្ណ ប៉ុន្តែ ខ្ញុំមិនបានចូលរួមនៅក្នុងសកម្មភាពនេះទេ។ បន្ទាប់ពីព្រឹត្តិការណ៍បាញ់រះនៅសាលារចនា កងវរសេនាតូចបានចាប់ពេទ្យថន និង មិត្តណាត់ បញ្ជូនទៅកងវរសេនាធំ រួចវរសេនាធំផ្សព្វផ្សាយថា ពីរនាក់នោះត្រូវបានអង្គការកម្ទេចចោល។ អង្គការក៏បានដកកម្លាំង ៤ នាក់បន្ថែម ទៅមន្ទីរវរសេនាធំ គឺមាន៖ យន់ (ប្រធានវរសេនាតូចលេ១១៣), ចំរើន (ប្រធាននយោបាយអនុសេនាធំលេខ ២៣), លឿន (ប្រធានយោធាអនុសេនាធំ លេខ២៣) និង សាំង (អនុនយោបាយកងអនុសេនាធំលេខ២១)។

នៅខែមីនា ឆ្នាំ ១៩៧៦ មានយុទ្ធជនម្នាក់នៅក្នុងកងអនុសេនាតូចលេខ២ រើសបានគ្រាប់បែកផ្លែទៀបមួយគ្រាប់ នៅពេលរៀបចំផ្ទះដើម្បីសម្រាក។ បន្ទាប់ពីយុទ្ធជនរើសបានគ្រាប់បែកផ្លែទៀបហើយ ក៏បានយកទៅប្រគល់ឲ្យមិត្តឈ្មោះ ថន ដែលជាកម្មាភិបាលកងអនុសេនាតូចលេខ២ ក្នុងអនុសេនាធំលេខ៤១។ មិត្ត ថន ក៏បានយកគ្រាប់បែក ហើយបានរាយការណ៍ជូនមិត្ត សារិន ។ មិត្តសារិន ក៏បានបញ្ជាឲ្យមិត្ត ថន យកគ្រាប់បែកដែលរើសបានទៅកប់ទុកមួយកន្លែងសិន។ នៅចុងខែមីនា យុទ្ធជនម្នាក់ទៀតនៅក្នុងក្រុម ទី២ កងអនុសេនាតូចទី២ រើសបានកាំភ្លើង អ៊ែរកែង មួយដើម និងគ្រាប់បែកមួយចំនួនទៀត ហើយក៏បានយកទៅឲ្យមិត្ត ថន ដដែល។ មិត្ត ថនបានទៅរាយការណ៍ឲ្យមិត្ត សារិន ហើយមិត្ត សារិន ឆ្លើយថា ឲ្យយកទុកមួយកន្លែងសិន ចាំមានវិធានការបន្តទៀត។

នៅដើមខែ មេសា ឆ្នាំ១៩៧៦ មិត្ត សារិន បានឲ្យមិត្តថន យកគ្រាប់បែកទៅបោកនៅក្រោយវាំង។ មុនពេលបោកគ្រាប់បែកទាំងនោះ មិត្តថន បានរៀបចំឲ្យ មិត្ត មុីសារុន (ក្រុម ទីពីរ អនុសេនាតូច១ អនុសេនាធំ៤១ កងពល ១៧០) និង មិត្ត អ៊ុក យុនទី (អនុក្រុម ទីពីរ អនុសេនាតូច ១ អនុសេនាធំ ៤១ កងពល ១៧០) យាមនៅតាមផ្លូវក្រោយវាំងបែរមុខទៅទិសខាងលិច ដោយបន្ទំធ្វើជាអ្នកបោសសម្អាតនៅក្បែរនោះ។ ចំណែកខ្ញុំ បន្ទំធ្វើជាអ្នកបោសសំរាមនៅរោងយាមជិតនោះដែរ។ នៅពេលរៀបចំហើយមិត្តថន បានចូលទៅបោកគ្រាប់បែក។ គោលបំណងនៃការបោកគ្រាប់បែកនេះគឺនៅក្នុងវាំង ប៉ុន្តែពេលបោះគ្រាប់បែកនោះទៅបែរជាប៉ះខ្សែភ្លើង និងបានធ្លាក់មកជិតអ្នកយាមទៅវិញ។ ព្រឹត្តិការណ៍បានកើតឡើងនៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ ម៉ោង៨ និង៣៥នាទីទៀបភ្លឺ។ បន្ទាប់ពីបោកគ្រាប់បែកហើយ មិត្តថន បានរត់ចេញមកវិញ ហើយដើរគេចតាមផ្ទះដែលមានធុងសាំងត្រឡប់ទៅផ្ទះរបស់គាត់វិញ។ ១០នាទី ក្រោយមកកង១៨០ បានមកកាន់ទីកន្លែងដែលបានកើតហេតុ និងទាក់ទងអ៊ុក យុនទី និងរាយការណ៍ថា មានខ្មាំងបោកគ្រាប់បែក។ បន្តិចក្រោយមក សារិន និង មិត្ត ថន ក៏បានដើរចេញមកមើលដែរ ដោយធ្វើហាក់ដូចជាមិនបានដឹងអ្វីដែលបានកើតឡើង។ ក្រោយមក មិត្តសារិន ក៏បានដើរចូលទៅក្នុងបន្ទន់បត់ជើង ទន្ទឹមនឹងនោះ មានមិត្តមកពីកង ១៨០ ម្នាក់ក៏បានដើរចូលជាមួយដែរ។ ក្រោយពី សារិន បត់ជើងរួចមិត្តមកពីកង ១៨០ បានរើសបានសំបុត្រមួយច្បាប់សរសេរថា «មិត្តយើងខាង១៨០ ជិហរឹងដែរ តែកាំភ្លើងសេកាសេ មិនអាចយកឈ្នះកាំភ្លើងអាកាបានទេ» នៅមានន័យច្រើនជាងនេះទៀត ប៉ុន្តែខ្ញុំចាំមិនបាន។ ពេលនោះមិត្តសារិនបានហៅខ្ញុំ, អ៊ុក យុនទី, មុី សារុន, នុប សារិត (ប្រធានក្រុម១ សេនាតូច១ អនុសេនាធំ៤១ កងពល ១៧០), ស្រ៊ី គិត (យុទ្ធជន អនុក្រុម ទីពីរ អនុសេនាតូច១ អនុសេនាធំ ៤១ កងពល ១៧០) និង ខែម សំអាត (អនុក្រុម ទីបី អនុសេនាតូច ១ អនុសេនាធំ ៤១ កងពល ១៧០) ទៅណែនាំថា «ឲ្យមិត្តយើងរាយការណ៍តាមមិត្តយើងឃើញ តែកុំបង្កាច់បង្ខូចមិត្តខាងកង ១៨០ គឺយើងរាយការណ៍ដើម្បីយុត្តិធម៌»។ មួយថ្ងៃក្រោយពីរាយការណ៍ឲ្យគណៈងហើយ បងសារិន បានចាត់តាំងឲ្យខ្ញុំមកជួបគណៈកងពលទៀត។ បន្ទាប់ពីខ្ញុំរាយការណ៍ជូនគណៈកងពលរួចហើយ កងពលក៏បានបញ្ជូនខ្ញុំមកទីនេះតែម្តង។

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ យឹម សំបាត់ ពិតប្រាកដណានោះទេ។

# វិញ មិញចូវ អនុសេនីយ៍ផ្កាយពីរកងទ័ពជើងទឹក

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J០៧១៣៣

**អ៊ុន សុជាទី**

វិញ មិញចូវ គឺជាអនុសេនីយ៍ផ្កាយពីរកងទ័ពជើងទឹក ត្រូវបានចាប់ខ្លួនមកឃុំឃាំងនៅក្នុងគុកទួលស្លែង នៅយប់ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៨។ វិញ មិញចូវ ត្រូវបានសួរចម្លើយដោយឈ្មោះ ម៉េង។ ខាងក្រោមនេះ គឺជាចម្លើយសារភាពរបស់ វិញ មិញចូវ ដែលបានផ្តល់ឲ្យកងសួរចម្លើយនៅមន្ទីរសន្តិសុខស-២១។

ខ្ញុំឈ្មោះ វិញ មិញចូវ អាយុ៣០ឆ្នាំ មានឋានន្តរសក្តិជាអនុសេនីយ៍ផ្កាយពីរកងទ័ពជើងទឹក។ ខ្ញុំ មានតួនាទីជាប្រធានកប៉ាល់លេខ ០៩១៩ និងប្រធានអនុសេនាតូចកប៉ាល់ អនុសេនាធំលេខ៤។

ខ្ញុំមានស្រុកកំណើតនៅ វាំងទុង សង្កាត់យិនថាំង ក្រុងក្រមួនស។ នៅក្នុងឆ្នាំ ១៩៦៤ ខ្ញុំបានចូលបដិវត្តន៍នៅវៀតណាមខាងត្បូង។ ខ្ញុំបានចូលក្រុមយុវជនរំដោះវៀតណាមខាងត្បូងនៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ១៩៧២ និងចូលជាសមាជិកបក្សពលករ វៀតណាម នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៧៣។ រហូតដល់ឆ្នាំ១៩៧៥ ក្រោយរំដោះខ្ញុំមានឋានន្តរសក្តិជាអនុសេនីយ៍ផ្កាយមួយ និងក្តាប់សន្តិសុខនៅក្រមួនស។ នៅឆ្នាំ១៩៧៧ ខ្ញុំបានឡើងជាអនុសេនីយ៍ផ្កាយពីរ នៅពេលដែលខ្ញុំត្រូវមកកាន់ការងារខាងកងទ័ពជើងទឹក។ នៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៨ លោកអនុសេនីយ៍ផ្កាយ ៤ ឈ្មោះ ត្រាន់ យ៉ាងអ៊ុក ហៅ អ៊ុកអ៊ូ បានទទួលបញ្ជាពីថ្នាក់លើមកថា «តាមផែនការរួមរបស់បក្ស វៀតណាម អង្គភាពរបស់ខ្ញុំមានមុខសញ្ញាទទួលបន្ទុកស៊ើបពិនិត្យក្តាប់សភាពការណ៍តាមសមុទ្រកម្ពុជា និងតាមឆ្នេរសមុទ្រកម្ពុជា ដើម្បីនាំទ័ពចូលជាលើកទី ២»។ ផែនការរបស់យើងមានដូចជា៖



ជនជាតិវៀតណាមដែលជាប់ឃុំឃាំងនៅមន្ទីរស-២១
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផែនការស៊ើបការណ៍នេះ កំណត់រយៈពេល១៥ថ្ងៃ ត្រូវយកការណ៍ឲ្យបានសម្រេចទាំងអស់ ដើម្បីបម្រើផែនការរួមទូទាំងប្រទេសឲ្យបាន។ ផែនការរបស់យើងត្រូវតែវាយយកកម្ពុជា និងបង្ខំឲ្យកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិន ដើម្បីឲ្យកម្ពុជាដើរតាមមាគ៌ានយោបាយរបស់បក្សយើង។ កាលបើយើងវាយសង្គ្រប់ខាងនយោបាយបានហើយ





ពេលនោះយើងនឹងកាន់កាប់កម្ពុជា ដោយចាត់តាំងរដ្ឋអំណាចមួយថ្មីឲ្យកម្ពុជានៅក្រោមការដឹកនាំរបស់បក្សកុម្មុយនីសឥណ្ឌូចិន។ ពេលនោះរដ្ឋអំណាចរបស់យើងមានពេញទូទាំងឥណ្ឌូចិន។ ប្រទេសវៀតណាមយើងនឹងក្លាយទៅជាមហាអំណាចមួយនៅអាស៊ីអាគ្នេយ៍ដោយគ្មាននរណាហ៊ានប្រឆាំងយើងទៀតទេ។ បច្ចុប្បន្ននេះបក្សរបស់យើង មានយុទ្ធវិធីមួយល្អលើមាគ៌ានយោបាយអន្តរជាតិ គឺបញ្ហាប្រកាសផ្សាយតាមវិទ្យុអំពីបញ្ហាចរចាសន្តិភាព។ យើងផ្សាយយ៉ាងដូច្នេះ ដើម្បីឲ្យសកលលោកជឿថា វៀតណាមយើងមានទឹកចិត្តល្អ ស្វែងរកសន្តិភាព ស្វែងរកមិត្ត និងដើម្បីទម្លាក់កំហុសទៅលើកម្ពុជា។ ម្យ៉ាងវិញទៀត តាមមាគ៌ាយុទ្ធសាស្ត្ររបស់បក្សវៀតណាម គឺយើងនឹងវាយគាប វាយលុកចូលតាមគ្រប់មុខសញ្ញា សង្កត់យកឲ្យឈ្នះតែម្តង។ ពេលនោះសកលលោកក៏មិនភ្ញាក់ផ្អើលថា យើងមានផែនការធំវាយប្រទេសកម្ពុជាដែរ ព្រោះយើងបានផ្សាយជាសកលរួចហើយអំពីបញ្ហាចរចាសន្តិភាពនេះ។ ដូច្នេះយើងត្រូវតែពង្រីងជិហរ ដើម្បីឲ្យបានសម្រេចតាមសំណូមពរយុទ្ធសាស្ត្ររបស់ ហូ ជីមិញ គឺគ្រប់គ្រងប្រទេសកម្ពុជា និងគ្រប់គ្រងឥណ្ឌូចិន។ កាលណាភារកិច្ចសម្រេចបានល្អ គឺយើងអាចបង្ខំឲ្យប្រទេសកម្ពុជាចូលក្នុងសហព័ន្ធឥណ្ឌូចិនបានយ៉ាងងាយស្រួល។ ប៉ុន្តែទោះបីជាយ៉ាងណា យើងត្រូវតែយកប្រទេសកម្ពុជាឲ្យនៅក្រោមការគ្រប់គ្រងរបស់យើងឲ្យបាន។ ប្រទេសកម្ពុជាគឺជាប្រទេសតូចមួយ ប៉ុន្តែសម្បូរទៅដោយសេដ្ឋកិច្ចព្រៃឈើ និងស្រូវស្រែ។ យើងវាយយកប្រទេសកម្ពុជាបានបានន័យថា បក្សយើងអាចដោះស្រាយជីវភាពឲ្យប្រជាជនវៀតណាមយើងបានមួយចំនួនធំ។ សព្វថ្ងៃនេះអង្ករថ្លៃណាស់ ហើយម្ហូបអាហារក៏ថ្លៃទៀត។ នៅពេលដែលយើងទទួលបានជ័យជម្នះ យើងនឹងអាចដោះស្រាយជីវភាពរបស់ប្រជាជនយើងបានថែមមួយកម្រិតទៀត។ នេះជាទិសអនាគតរបស់បក្សកុម្មុយនីស្តវៀតណាម។ យើងទាំងអស់គ្នាត្រូវតែពុះពារឲ្យបានសម្រេចភារកិច្ចរបស់យើង ដើម្បីរួមផែនការខែខាងមុខនេះ។ យើងមិនត្រូវនៅរារែក ខ្លាចមុខខ្លាចក្រោយនោះទេ។ ការជាប់ជំពាក់នឹងប្រពន្ធកូនឪពុកម្តាយ គឺជាបញ្ហាផ្ទាល់ខ្លួនដែលមានគ្រប់គ្នា មិនមែនមានតែម្នាក់ឯងនោះទេ។ ប៉ុន្តែប្រសិនបើយើងមិនទៅ គឺខុសនឹងច្បាប់អាជ្ញាសឹកបទបញ្ជារបស់រដ្ឋ ហើយប្រពន្ធកូន និងក្រុមគ្រួសារត្រូវជាប់គុកព្រោះទោសក្បត់។ រដ្ឋាភិបាលបានផ្សាយជាទូទៅ ហើយសូម្បីតែប្រជាជនក៏ត្រូវច្បាប់អាជ្ញាសឹកនេះសង្កត់ដែរព្រោះថាបើមិនឲ្យកូនទៅធ្វើទ័ពទេគឺចាប់ដាក់គុក។

នៅយប់ថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៨ ខ្ញុំត្រូវចេញដំណើរមកតាមដែនសមុទ្ររបស់ប្រទេសកម្ពុជាដោយទឹកចិត្តក្រៀមក្រំជាទីបំផុត។ ក្នុងចិត្តរបស់ខ្ញុំ គឺមិនចង់ទៅទេ។ ក្នុងពេលធ្វើដំណើរមកដល់សមុទ្រប្រទេសកម្ពុជាពិតមែន ប៉ុន្តែខ្ញុំនៅតែរារែក ប៉ុន្តែខ្ញុំបានខិតខំបំពេញភារកិច្ចនេះ។ខ្ញុំបានបើកការណូត នេសាទត្រីបណ្តើរ និងក្តាប់សភាពការណ៍ក្នុងដែនសមុទ្រកម្ពុជាបណ្តើរ ដល់ម៉ោងប្រមាណម៉ោង២ទៀបភ្លឺ។ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨ កប៉ាល់របស់ខ្ញុំបានចូលដល់កោះអង្ក្រងរបស់ប្រទេសកម្ពុជា ហើយខ្ញុំក៏ត្រូវចាប់ខ្លួនតែម្តង។

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ វិញ មិញចូវ ពិតប្រាកដយ៉ាងណានោះទេ។

**ពាក្យស្លោកបដិវត្តន៍ខ្មែរក្រហម**
**ប្តេជ្ញាជាច់ខាត បន្តធ្វើបដិវត្តន៍សង្គមនិយម ឱ្យជ្រាលជ្រៅនិងជាប់ជានិច្ច នៅក្នុងបក្ស**
**កងទ័ពបដិវត្តន៍ ក្នុងជួរបដិវត្តន៍ទាំងអស់ ក្នុងប្រជាជន**
**និងក្នុងសង្គមជាតិទាំងមូល។**

# ហួយ ទូច ទទួលខុសត្រូវ អង្គរពាណិជ្ជកម្មភូមិភាគពាយ័ព្យ

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00២០៥

សុខ ចាន់ណៃ



មិត្តនារីនៅរោងម៉ាស៊ីនកិនស្រូវតំបន់ស្អាង កោះធំ កំពុងវែងអង្ករយកទៅឧបត្ថម្ភការដ្ឋានប្រព័ន្ធសំណង់ចាត់ចែងទឹក ការដ្ឋានស្រែប្រាំង និងខត្តម្ភសមរភូមិមុខៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហួយ ទូច ភេទប្រុស អាយុ២៧ឆ្នាំ។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិព្រៃម្លូ ស្រុកបាកាន ខេត្តពោធិ៍-សាត់។ ខ្ញុំបានចូលរៀននៅក្នុងឆ្នាំ ១៩៦២។ នៅក្នុងឆ្នាំ ១៩៦៩ ខ្ញុំបានរៀនដល់ថ្នាក់ទី៦ ហើយក៏ឈប់រៀនមកជួយធ្វើស្រែឪពុកម្តាយ។ នៅខែឧសភា ឆ្នាំ១៩៧០ ខ្ញុំបានចូលបដិវត្តន៍ដោយធ្វើការងារនៅក្នុងកងចល័ត។ នៅក្នុងខែមេសា ខ្ញុំមានជំងឺគ្រុនចាញ់ ខ្ញុំបានឈប់ពីការងារកងចល័តមកធ្វើជាគ្រូបង្រៀនកុមារនៅភូមិបឹងភ្នៅ។ ពេលនោះខ្ញុំបានរាប់អាន និងជិតស្និទ្ធជាមួយឈ្មោះ ម៉ុស (ប្រធានភូមិបុស្សស្រីក្រាំង)។ នៅខែកញ្ញា ឆ្នាំដដែល ខ្ញុំបានទទួលការអប់រំពីឈ្មោះ ម៉ុស ចំនួនពីរលើក។ លើកទី១) ម៉ុស បានអប់រំខ្ញុំដោយលើកឡើងពីបដិវត្តន៍ដែលបង្កប់ស៊ីរូងផ្ទៃក្នុង ដែលមិនមែនជាសង្រ្គាមប្រជាជន ដូច្នេះប្រយ័ត្នដើរលើផ្លូវខុស។ លើកទី២) ម៉ុស ឲ្យខ្ញុំរក្សាការសម្ងាត់ និងចាត់តាំងកម្លាំងឲ្យទៅបង្កប់ដើម្បីវាយរំលំបដិវត្តន៍។

នៅខែមេសា ឆ្នាំ១៩៧១ ម៉ុស បានចាត់តាំងខ្ញុំឲ្យទៅនៅជាមួយ ប៉ូច (ប្រធានការដ្ឋាន) និងបានធ្វើសកម្មភាពកសាងកម្លាំងបានចំនួន ៣នាក់ នៅក្នុងមន្ទីរ រួមមាន៖ មិត្តយ៉ាត, សាម៉ន និង ផាត ដោយបានយកខ្លឹមសារអប់រំរបស់ ម៉ុស ទៅអប់រំអ្នកទាំងនោះ។ នៅខែសីហា ម៉ុស បានចាត់តាំងខ្ញុំឲ្យធ្វើសកម្មភាពជាមួយឈ្មោះ ផែន (ប្រធានឈ្លបឃុំបុស្សស្រីក្រាំង) ដើម្បីឲ្យ ផែន បើកផ្លូវបញ្ចេញសត្វជ្រូក ៥០ក្បាលទៅតំបន់ខ្មាំង និងទាក់ទងបន្ទាយស្វាយប្រហោង ឈ្មោះ ញ៉ាក់ ឲ្យកៀរប្រជាជនចេញពីភូមិ។

នៅខែមិថុនា ឆ្នាំ១៩៧២ ម៉ុស បានចាត់តាំងខ្ញុំឲ្យទៅនៅពាណិជ្ជកម្មស្រុកបាកាន លើតាមការស្នើសុំរបស់ឈ្មោះ ខាន (ប្រធានសេដ្ឋកិច្ចស្រុក)។ ពេលនោះខ្ញុំក៏បានភ្ជាប់ទំនាក់ទំនងជាមួយខ្សែចាស់ឡើងវិញ។ នៅខែតុលា បងផែនបានចាត់តាំងខ្ញុំឲ្យយកដែនទី (មន្ទីរភូមិរហាលទឹលដែលមានទ័ពសម្រាកនៅទីនោះ) ទៅឲ្យឈ្មោះ សន (បន្ទាយត្រពាំង) តាមរយៈឈ្មោះ នាង និង នួន ដើម្បីឲ្យយន្តហោះទម្លាក់គ្រាប់បែកនៅមន្ទីរភូមិរហាលទឹលនេះ។

នៅខែមីនា ឆ្នាំ១៩៧៣ ឈ្មោះ ខាន (ប្រធានសេដ្ឋកិច្ចស្រុកបាកាន) បានចាត់តាំង ទូច ធ្វើជាប្រធានមន្ទីរសិប្បកម្មធ្វើផាល, ឈ្មោះ ហ៊ាង ជាអនុប្រធាន និងឈ្មោះ ហាន ជាសមាជិក។ ក្រោយមក ម៉ុស បានហៅបក្ខពួកមកប្រជុំនៅភូមិស្វាយ រួមមាន៖ ប៉ូច, ផែន និង មួន។ នៅក្នុងការប្រជុំនោះ ផែន និង មួន បានត្រៀមកម្លាំងធ្វើសកម្មភាពបន្តទៀត ដោយឲ្យខ្ញុំយកការណ៍ពីមន្ទីរកងទ័ពឲ្យខ្មាំងតាមរយៈឈ្មោះ មួន ដែលជាអ្នករាយការណ៍ឲ្យខ្មាំង។

នៅខែមិថុនា ឆ្នាំ១៩៧៤ ឈ្មោះ ខានបានចាត់តាំង ទូច ទៅនៅពាណិជ្ជកម្មភាគពាយ័ព្យ តាមការស្នើរបស់ យ៉េង (ប្រធានប្រកពាណិជ្ជកម្មពាយ័ព្យ) និងប្រចាំមន្ទីរនៅស្រុកមោងឫស្សីក្រោម (តំបន់៤)។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យដឹកអង្ករជូនប្រជាជននៅក្នុងតំបន់៤។ ក្រោយមកអង្គការបានផ្លាស់ខ្ញុំឲ្យទៅធ្វើការជាមួយបង យ៉េត នៅប៉ោយប៉ែតវិញ។ នៅពេលខ្ញុំជួបបង យ៉េត។ បានអប់រំខ្ញុំអំពីកម្លាំងប្រឆាំងបដិវត្តន៍ដែលចាប់ពីថ្នាក់លើដល់ថ្នាក់ក្រោម គឺជាខ្សែបង្កប់។ នៅខែសីហា ខ្ញុំបានទៅជួបជាមួយ ម៉ុស នៅភូមិបុស្សស្រីក្រាំង ដើម្បីពិភាក្សាជាមួយគាត់អំពីបញ្ហាភ្ជាប់ការទាក់ទងគ្នាវិញ។ ប៉ុន្តែការទាក់ទងនេះមិនបានសម្រេចទេព្រោះនៅឆ្ងាយពីគ្នាខ្លាំងពេក។

នៅឆ្នាំ១៩៧៦ យ៉េង បានហៅបក្ខពួកប្រជុំ មានខ្ញុំ, យាន និង អិន។ ខ្លឹមសារនៃការប្រជុំពិនិត្យពីការកសាងកម្លាំង, រក្សាការសម្ងាត់ និងបន្តពង្រឹងភារកិច្ចដែលខ្លួនត្រូវធ្វើ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងខ្ញុំឲ្យទទួលខុសត្រូវផ្នែកបើកបរ និងដឹកជញ្ជូន ពាណិជ្ជកម្មភូមិភាគពាយ័ព្យ។ នៅខែវិច្ឆិកា ខ្ញុំបានជួបជាមួយ ពុំ ម្តងទៀត ដោយពេលនោះគាត់បានយកការណែនាំរបស់ យ៉េង មកប្រាប់ ទូច ឲ្យពិនិត្យ និងកសាងកម្លាំងនៅប្រកប៉ោយប៉ែត ហើយប្រាប់ខ្ញុំថា នៅខែធ្នូ ឆ្នាំ១៩៧៦ ឲ្យខ្ញុំទៅប្រជុំនៅបាត់ដំបង ប៉ុន្តែខ្ញុំមិនបានទៅប្រជុំទេ ព្រោះខ្ញុំត្រូវមករៀនវគ្គខ្លីនៅភ្នំពេញ។

នៅឆ្នាំ១៩៧៧ យ៉េន បានហៅខ្ញុំប្រជុំនៅបាត់ដំបង ដោយមានអ្នកចូលរួមប្រជុំមាន យ៉េង (ប្រមូលផលតំបន់៣), ហ៊ូ (ប្រមូលផលតំបន់៤), ពុំ (ប្រមូលផលតំបន់៥), យាន (ប្រធានឃ្លាំង) និង ខ្ញុំ។ ខ្លឹមសារប្រជុំនោះទាក់ទងនឹងការកសាងកម្លាំង និងភ្ជាប់ទំនាក់ទំនងខ្សែចាស់ឲ្យជាប់។ នៅខែឧសភា អង្គការបានចាត់តាំងខ្ញុំ, ពុំ ឲ្យទៅប្រមូលផលស្រូវនៅស្វាយស៊ីសុផុន និងនៅថ្មពួក។ ទៅទីនោះ ខ្ញុំកសាងកម្លាំងបានចំនួន ៥នាក់ មាន៖ វិន (កម្មករចាស់រោងចក្រម៉ាស៊ីនស្រូវ), ផុង (កម្មករចាស់រោងចក្រម៉ាស៊ីនស្រូវ), ប្រាក់ (កម្មករបើកបរសង្គមចាស់), យឹម (កម្មករបើកបរសង្គមចាស់), អុល (កម្មករបើកបរសង្គមចាស់)។

នៅថ្ងៃទី៥ និង ៦ ខែមិថុនា ឆ្នាំ១៩៧៧ អង្គការបានដកខ្ញុំឲ្យមកមើលអង្ករតាមរោងម៉ាស៊ីនកិនស្រូវ ពេលនោះខ្ញុំ និង ហ៊ូ កសាងបានកម្លាំងមួយចំនួន រួមមាន៖ ស៊ិន (ប្រធានកិនស្រូវបាត់ដំបង), វៃន (នៅរោងម៉ាស៊ីនកិនស្រូវ) និង កើត (នៅរោងម៉ាស៊ីនកិនស្រូវ) រហូតដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនខ្ញុំតែម្តង។

កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ ហួយ ទូច ពិតប៉ុណ្ណាណនោះទេ។



ស្វែងរកការពិត-ផ្នែកឯកសារ លេខ២៤៨ ខែសីហា ឆ្នាំ២០២០

# រូបថតបង្ហាញពេលវេលានៃអំពើឧក្រិដ្ឋរបស់ខ្មែរក្រហម

សន ប៊ុនស៊ីម



រូបថតនេះបង្ហាញពីដំណើរជាជួរឆ្ពោះទៅមុខរបស់យុវជន៦រូប និងកុមារាម្នាក់ ក្នុងសម្លៀកបំពាក់ខ្មៅ ពាក់ស្បែកជើងកង់ឡាន បង់កក្រមា និងលីកាំភ្លើងៗ ពីឆ្វេងទៅស្តាំ៖ អុល អ៊ឹម ផេង អេា ញៀប (ហៅ សុខ) សាន្ត សុខ និង ដួចៗ (សាន្ត សុខ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតអំណោយរបស់លោក សាន្ត សុខ ជាដើមបណ្តឹងរដ្ឋប្បវេណី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាអតីតកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាល៧នាក់ក្នុងរូបថតនេះ ថតនៅឆ្នាំ ១៩៧២ ក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ។ រូបថតនេះ បង្ហាញពីដំណើរជាជួរឆ្ពោះទៅមុខរបស់យុវជន៦រូប និងកុមារាម្នាក់ ក្នុងសម្លៀកបំពាក់ខ្មៅ ពាក់ស្បែកជើងកង់ឡាន បង់កក្រមា និងលីកាំភ្លើងៗ ពីឆ្វេងទៅស្តាំ៖ អុល អ៊ឹម ផេង អេា ញៀប (ហៅ សុខ) សាន្ត សុខ និងដួចៗ

នៅខាងខ្នងរូបថតសខ្មៅមួយសន្លឹកនេះ មានអក្សរពណ៌ខៀវសរសេរថា «សាន្ត សុខ រួមចលនាតស៊ូបដិវត្តន៍ជាមួយប្អូនៗ - បុគ្គលិកអង្គភាពគណៈកម្មាធិការទទួលប្រជាជនជម្លៀសស្រុកព្រៃកប្បាស (ស្រុក ៥៥) ថតឆ្នាំ ១៩៧២ នៅចម្ការដំឡូងជិតមន្ទីរអំពិលរៀង»។ សំណេរខ្ទីសរសេរដោយដៃមួយឃ្លានេះ បង្ហាញឲ្យឃើញពីការជម្លៀសប្រជាជននៅខេត្តតាកែវ ដែលបានចាប់ផ្តើមឡើងយ៉ាងហោចណាស់៣ឆ្នាំមុន ថ្ងៃជ័យជម្នះរបស់ខ្មែរក្រហមទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលសកម្មភាពនេះ ត្រូវបានមើលឃើញថា ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏ជូរចត់មួយ សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍ឆ្នាំ ១៩៧០។ ចាប់តាំងពីថ្ងៃជ័យជម្នះរបស់ខ្មែរក្រហមក្នុងខែមេសា ឆ្នាំ១៩៧៥ ពិភពលោកបានកត់សម្គាល់ឃើញថា ខ្មែរក្រហមបានបង្កើតឲ្យមានព្រឹត្តិការណ៍ជម្លៀសប្រជាជនដោយបង្ខំជាបីដំណាក់កាលធំៗ គឺនៅភ្លាមៗបន្ទាប់ពីថ្ងៃជ័យជម្នះ ១៧មេសា ១៩៧៥ នៅចុងឆ្នាំ ១៩៧៥ និងនៅចុងឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨។ ក្នុងពេលដែលបណ្តាប្រទេសលើពិភពលោក ធ្វើការជម្លៀសប្រជាជនចេញពីកន្លែងអសុវត្ថិភាពទៅកាន់កន្លែងសុវត្ថិភាព ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីកន្លែងសុវត្ថិភាពទៅកាន់តំបន់ដាច់ស្រយាល និងគ្មានសុវត្ថិភាពដើម្បីធ្វើការងារស្រែចម្ការ ដោយមិនបានប្រាប់ដំណឹងជាមុន ឬទុកពេលវេលាសម្រាប់ការត្រៀមខ្លួន និងរៀបចំអីវ៉ាន់ឡើយ។ ក្នុងរយៈពេលនៃការជម្លៀស និងការស្នាក់នៅទីជនបទដាច់ស្រយាល ប្រជាជនជួបប្រទះការហូបចុកមិនគ្រប់គ្រាន់ បង្ខំឲ្យធ្វើការហួសកម្លាំង គ្មានថ្នាំសង្កូវសម្រាប់ព្យាបាល និងធ្វើទារុណកម្មៗ នៅក្នុងគម្រោងផែនការបួនឆ្នាំរបស់ខ្លួន ខ្មែរក្រហមបានដាក់ការដាំដុះស្រូវជាអាទិភាពចម្បងរបស់ជាតិ បន្ទាប់ពីបញ្ហាសន្តិសុខជាតិ។ នៅពេលដែលរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាប្រមាណពី ១លាន៧សែននាក់ទៅ ២លាន ២សែននាក់ ត្រូវបានរកឃើញថាបានស្លាប់ និងសម្លាប់ក្រោមហេតុផលអភិវឌ្ឍប្រទេសតាមរបៀប «មហាលោតផ្លោះ មហាអស្ចារ្យ» ដែលផ្តោតលើការស្តារហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្ម ដើម្បីឈានដល់ការសម្រេចបំណងប្រែក្លាយប្រទេសកម្ពុជាឲ្យក្លាយជាប្រទេសជឿនលឿនផ្នែកកសិកម្មរបស់ ប៉ុល ពត។

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ សាលក្រមសំណុំរឿង ០០២/០២ របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាត់ទុកការជម្លៀសប្រជាជនក្នុងរបបខ្មែរក្រហម គឺជាគោល



នៅខាងខ្នងរូបថតសខ្មៅមួយសន្លឹកនេះ មានអក្សរពណ៌ខៀវសរសេរថា «សាន្ត សុខ រួមចលនាតស៊ូបដិវត្តន៍ជាមួយប្អូនៗ - បុគ្គលិកអង្គភាពគណៈកម្មាធិការទទួលប្រជាជនជម្លៀសស្រុកព្រៃកប្បាស (ស្រុក៥៥) ថតឆ្នាំ១៩៧២ នៅចម្ការដំឡូងជិតមន្ទីរអំពិលរៀង»។ (សាន្ត សុខ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នយោបាយដែលមានលក្ខណៈឧក្រិដ្ឋ។ គោលនយោបាយនេះ ជាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំង ៥របស់ខ្មែរក្រហម ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយល់ឃើញថា ជាគោលនយោបាយដែលមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងគោលបំណងរួម ដែលឈានដល់ការប្រព្រឹត្តបទឧក្រិដ្ឋ។ គោលនយោបាយទាំងនោះ រួមមាន៖ ១). ការផ្លាស់ទីលំនៅប្រជាជនម្តងហើយម្តងទៀតពីទីប្រជុំជន និងទីក្រុងទៅកាន់តំបន់ជនបទ ព្រមទាំងពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត។ ២). ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ។ ៣). ការបង្កើត និងដំណើរការមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួនដាក់ឲ្យនៅដោយឡែក និង «កម្ទេច» អ្នកដែលត្រូវបានគេចាត់ទុកថាជាប្រភេទខ្មាំងធ្ងន់ធ្ងរបំផុត និងដើម្បីអប់រំ «សមាសភាពមិនល្អ»។ ៤). ការកំណត់គោលដៅទៅលើក្រុមជាក់លាក់ រួមទាំងជនជាតិចាមនិងវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងអ្នករដ្ឋការស៊ីវិល ទាហាន និងក្រុមគ្រួសារ និង ៥). ការចេញបទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍។

រូបថតនេះ ត្រូវបានបោះពុម្ពជាផ្ទាំងពិព័រណ៍ធំមួយក្នុងចំណោមរូបថតពិព័រណ៍ជាច្រើនផ្ទាំងទៀត ដើម្បីដាក់តាំងនៅក្នុងបន្ទប់ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តតាកែវ» បង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈ-មណ្ឌលឯកសារកម្ពុជា ដែលទើបបើកសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ សម្រាប់ការទទួលបាននិងចែកចាយព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះនៃរបបខ្មែរក្រហម គ្រូបង្រៀន សិស្សានុសិស្ស និងយុវជនជំនាន់ក្រោយពីប្រវត្តិសាស្ត្រខ្មែរក្រហម។



គរុសិស្សចូលរួមសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តតាកែវ» នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ និងទស្សនាពិព័រណ៍រូបថតដែលដាក់តាំងបង្ហាញនៅក្នុងការិយាល័យនេះ។
(សន ប៊ុនស៊ីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)





# គង់ ច័ន្ទវ៉ាន់ណេង ម្ចាស់ជ័យលាភី រឿង «ព្រះអាទិត្យរះតពន្លឺ»

## និយាយពីប្រវត្តិឪពុកក្នុងរបបខ្មែរក្រហម

*សន ប៊ុនស៊ីម*




គង់ ច័ន្ទវ៉ាន់ណេង នៅក្នុងឱកាសទទួលវិញ្ញាបនបត្រ និងពានរង្វាន់ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០។
( សន ប៊ុនស៊ីម/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

« ខ្ញុំធំដឹងក្តីឡើង ខ្ញុំធ្លាប់ឮរឿងរ៉ាវអំពីរបប ប៉ុលពត។ ជាពិសេសពេលដែលខ្ញុំញុំាបាយ ហើយសល់បាយនៅនឹងចាន។ មានរឿងជាច្រើនដែលឪពុកម្តាយរបស់ខ្ញុំបាននិទានឲ្យខ្ញុំស្តាប់ ក៏ប្រហែលជាមិនខុសពីគ្រួសារផ្សេងៗទៀតនោះទេ គឺទាក់ទងនឹងការកាប់សម្លាប់ អត់ឃ្លាន និងព្រាត់ប្រាសជាដើម។ ឪពុកខ្ញុំបានបាត់បង់បងប្រុសបង្កើតម្នាក់។ ចំណែកម្តាយខ្ញុំបាត់បង់ទាំងឪពុកទាំងម្តាយ ហើយក្លាយខ្លួនជាក្មេងកំព្រាតាំងពីអាយុ ៧ឆ្នាំ ថែមទាំងវង្វេងបាត់បងប្រុសបង្កើតម្នាក់មកទល់សព្វថ្ងៃ។ រឿងមួយដែលខ្ញុំចងចាំជាងគេនោះគឺជារឿងដែលប៉ារបស់ខ្ញុំបានលួចស្រូវគេនៅសម័យនោះ។ បន្ទាប់ពីខ្ញុំស្តាប់រឿងរបស់គាត់ហើយខ្ញុំអាសូរក្នុងចិត្ត ដែលប៉ាខ្ញុំគឺជាសិស្សឆ្លាតម្នាក់នៅក្នុងសាលា តែត្រូវប្រើវិធីអ្វីក៏ដោយដែលគាត់អាចធ្វើបាននៅសម័យនោះទៅលួចស្រូវគេដើម្បីក្រពះ។ ខ្ញុំនឹកដល់រឿងនេះពេលណាក៏គួរឲ្យឈឺចិត្តដែរ ដោយសារយើងបានបាត់បង់ធនធានមនុស្សជាច្រើន ដែលជាស្នូលសម្រាប់អភិវឌ្ឍប្រទេសនៅក្នុងសម័យខ្មែរក្រហម » ។

ច័ន្ទវ៉ាន់ណេង បានចងចាំសាច់រឿងរបស់ឪពុក និងក្រុមគ្រួសារយ៉ាងច្បាស់ ហើយបានយកប្រវត្តិរឿងរ៉ាវនេះមកបង្រួមជាសាច់រឿងខ្លីមួយដោយដាក់ចំណងជើងថា "ព្រះអាទិត្យឥតពន្លឺ" រួចបានផ្ញើមកចូលរួមប្រកួតប្រជែងជ្រើសរើសស្នាដៃពានរង្វាន់អក្សរសិល្ប៍ស្ទឹកតែ លើកទី១ ឆ្នាំ២០២០ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសមាគមអ្នកនិពន្ធខ្មែរ។ សាច់រឿងខ្លីនេះ រៀបរាប់ពីដំណើរជីវិតពិតរបស់គ្រួសារមួយរស់នៅក្នុងខេត្តតាកែវ ដែលសមាជិកនៃគ្រួសារនោះគឺជាជីតាជីដូន អ៊ំ និងឪពុករបស់ ច័ន្ទវ៉ាន់ណេង ឆ្លងកាត់របបខ្មែរក្រហម។ តាមរយៈអត្ថន័យនៃសាច់រឿងខ្លីនេះ អ្នកនិពន្ធវ័យ ២៨ឆ្នាំ ច័ន្ទវ៉ាន់ណេង បង្ហាញពីភាពខ្មៅងងឹតនៃជីវិតរស់នៅក្នុងរបបខ្មែរក្រហម ដែលមិនមានសង្ឃឹមសោះឡើយថានឹងអាចវិលត្រឡប់ជាមានពន្លឺវិញបាន។

នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ ជាថ្ងៃប្រកាសជ័យលាភីពានរង្វាន់ ច័ន្ទវ៉ាន់ណេង ត្រូវបានប្រកាសថាកម្រងសាច់រឿងខ្លីរបស់ខ្លួនទទួលបានជ័យលាភីលេខ៤ ក្នុងចំណោមម្ចាស់ជ័យលាភីទាំង ៩រូប។ ក្នុងជំនួបជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាក្រោយពីការទទួលពានរង្វាន់រួច ច័ន្ទវ៉ាន់ណេង បានប្រាប់ពីការប្ដេជ្ញាចិត្តក្នុងការតាក់តែងនិងសរសេរសាច់រឿងរបស់គ្រួសារខ្លួន ដើម្បីដាស់តឿនដល់ក្មេងៗជំនាន់ក្រោយឲ្យយកចិត្តទុកដាក់ពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមរបស់ក្រុមគ្រួសារ ក្នុងគោលបំណងចែករំលែកផ្សព្វផ្សាយឲ្យកាន់តែទូលាយ និងបង្រៀនដល់ក្មេងៗជំនាន់ក្រោយពីទុក្ខវេទនារបស់ឪពុកម្ដាយ ជីដូន ជីតា និងសាច់ញាតិរបស់ខ្លួន ក្នុងគោលបំណងផ្សះផ្សាសង្គមកម្ពុជា និងចូលរួមទប់ស្កាត់ការវិលត្រឡប់នៃអំពើឃោរឃៅនេះជាថ្មីម្ដងទៀត។ កញ្ញា ច័ន្ទវ៉ាន់ណេង បាននិយាយថា៖ **«ការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រដ៏ឈឺចាប់មួយនេះ នឹងជួយឲ្យអ្នកមើល អ្នកអានជំនាន់ក្រោយដែលជាអនាគតអ្នកដឹកនាំប្រទេសបានរៀនសូត្រ ថ្លឹងថ្លែងពីសេចក្ដីឈឺចាប់របស់ប្រជាជនខ្មែរ ការបាត់បង់ធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធទៅនឹងគោលនយោបាយដែលខ្លួនចង់ប្រកាន់យក។ សូមឲ្យប្រវត្តិសាស្ត្រមួយនេះ ក្លាយជាប្រវត្តិសាស្ត្រសោកសៅចុងក្រោយបំផុតដែលកូនខ្មែរត្រូវរៀនសូត្រទៅចុះ»។**



រូបទីពរាប់ពីស្ដាំ គង់ ច័ន្ទវ៉ាន់ណេង នៅថ្ងៃទទួលវិញ្ញាបនបត្រ និងពានរង្វាន់ ពីលោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០។ (សន ប៊ុនស៊ីម/ មជ្ឈមណ្ឌលឯកសារកម្ពុជា)





# អៀ ហុកនីម៖ ម្ចាស់ជ័យលាភីរឿង «ពេលម៉ែឃ្លាតទៅ»

***សន ប៊ុនស៊ីម***



លោកជំទាវ ទន់ សាអ៊ីម (ឆ្វេង) និង លោក អៀ ហុកនីម (ស្ដាំ) នៅក្នុងពិធីប្រគល់រង្វាន់ជូនជ័យលាភីទាំង៩រូប នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០២០ (សន ប៊ុនស៊ីម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)។

អៀ ហុកនីម បានរៀបរាប់ថា៖ «សាច់រឿងនេះគឺជារឿងចាស់សម្រាប់អ្នកដែលបានឆ្លងកាត់ តែវាជារឿងថ្មីសម្រាប់អ្នកជំនាន់ក្រោយ។ គ្រប់យ៉ាងដែលបានកើតឡើងនៅសម័យខ្មែរក្រហម វាហួសពីការថ្លែង និងធ្វើឲ្យមនុស្សជំនាន់ក្រោយស្ទើរតែមិនជឿ។ នេះជារឿងពិតដែលខ្ញុំបានឆ្លងកាត់ផ្ទាល់តាំងពីដើមដល់ចប់។ គ្រប់យ៉ាងខ្ញុំមិនអាចបំភ្លេចបានទេ។ ខ្ញុំត្រូវរំឭកពីភាពខ្លោចផ្សារការតស៊ូ ភាពស្រេកឃ្លានដែលមិនអាចទ្រាំបាន និងការនឿយហត់នឹងការងារ ដើម្បីជាចំណែកមួយក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍»។

ហុកនីម បានសរសេរអំពីដំណើរជីវិតខ្លួនឯងដោយដាក់ឈ្មោះឲ្យតួអង្គនោះថា កុមារា ភា ។ សាច់រឿងនេះផ្ដើមចេញពីស្ថានភាពកងកម្លាំងខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញ ភាពស្រពេចស្រពិលនៃដំណើរជីវិតរបស់គ្រួសារមួយនៅពេលជម្លៀសតាមផ្លូវ និងការសម្របខ្លួនដើម្បីរក្សាជីវិតនៅពេលរស់នៅសហករណ៍។ មានអាយុត្រឹមតែ ៨ ឆ្នាំ ភា ត្រូវទទួលបន្ទុកមើលថែរក្សាប្អូនតូចៗ ពេលឪពុកម្ដាយត្រូវអង្គការបញ្ជូនឲ្យទៅឈរជើងសមរភូមិមុខ។ ពេលនោះហើយដែល ភា លែងបានសប្បាយនឹងកុមារភាពតទៅទៀត ដោយជំនួសមកវិញនូវបន្ទុកធ្វើជាបងប្រុសផង ជាម្ដាយផង និងជាឪពុកផង។ ភា ត្រូវរៀនសូត្រគ្រប់បែបយ៉ាងរាប់ចាប់ពីការរកក្ដាម និងរកខ្យងតាមវាលស្រែ ជាពិសេស ការប្រថុយអាយុជីវិតដើម្បីឲ្យប្អូនៗបានអាហារហូបចុក។ រឿង«ពេលម្ដាយឃ្លាតទៅ» នឹងបកស្រាយចម្ងល់មិត្តអាន ថាតើ ភា អាចដោះស្រាយឧបសគ្គទាំងនោះដោយរបៀបណា។

គួររំឭកថា នៅក្រោមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ឬ របបខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ប្រជាជនកម្ពុជាប្រមាណ ២ លាននាក់បានស្លាប់បាត់បង់ជីវិតដោយសារការបង្ខំឲ្យធ្វើការហួសកម្លាំង បង្អត់អាហារ ទារុណកម្ម និង សម្លាប់។ បុគ្គលដែលមានការចេះដឹងទាំងឡាយ រួមទាំងអ្នកនិពន្ធផង សុទ្ធតែជាមុខសញ្ញាដែលអង្គការត្រូវកម្ទេចចោល ដោយចោទថាជាខ្មាំង។ កវីនិពន្ធ អ្នកចម្រៀង តួសម្ដែង និងសិល្បៈករជាច្រើននាក់បានបាត់បង់ជីវិតនៅសម័យនោះ។

នៅក្រោមការដឹកនាំរបស់ ប៉ុល ពត ចំណេះដឹងគឺជាបទឧក្រិដ្ឋ ហើយអាចជាហេតុផលគ្រប់គ្រាន់ដែលកម្មាភិបាលខ្មែរក្រហមយកអ្នកចេះដឹងទាំងឡាយ ទៅសម្លាប់ចោលដោយប្រើពាក្យថា «យកទៅអប់រំ» ឬ «យកទៅកសាង» ជាដើម។

៤១ឆ្នាំក្រោយរបបខ្មែរក្រហមដួលរលំ ហុក នឹម នៅតែចងចាំទិដ្ឋភាពនៅពេលនោះ ដោយស្តែងឲ្យឃើញតាមរយៈទឹកដៃរបស់លោក។ រឿងខ្លីនេះ អាចឲ្យអ្នកអានមើលឃើញដំណើររបស់គ្រួសាររបស់លោកក្នុងពេលជម្លៀសពីភ្នំពេញទៅជនបទ ស្តាប់ឮពាក្យពេចន៍សន្ទនារវាងប្រជាជនចាស់ និងប្រជាជនថ្មី និងយល់ច្បាស់អំពីមនោសញ្ចេតនាដ៏ជ្រាលជ្រៅដែលបងប្រុសមានចំពោះប្អូនតូចៗនៅក្នុងទំព័រខ្មៅងងឹតនៃប្រវត្តិសាស្ត្រខ្មែរ។

សម្រាប់ ហុកនឹម សូម្បីតែការលួចដុតខ្យងឲ្យប្អូនហូបក៏ត្រូវយកជីវិតទៅប្តូរដែរ។ ការដុតខ្យងនេះ មានទោសប្រសិនបើត្រូវខ្មែរក្រហមចាប់បាន ព្រោះខ្មែរក្រហមយល់ថា ប៉ះពាល់ប្រយោជន៍រួមជាសមូហភាព។ ទោសនេះអាចត្រូវជាប់ចោទថាជាខ្មាំងប្រឆាំងនឹងបដិវត្តន៍ ហើយអាចនឹងត្រូវយកទៅសម្លាប់ចោល ដោយមិនមានប្រព័ន្ធតុលាការណាមកវិនិច្ឆ័យទោសកំហុសនោះឡើយ។

គួរបញ្ជាក់ថា អៀ ហុកនឹម កើតនៅឆ្នាំ១៩៦៦ នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ។ សាច់រឿងរបស់លោកដែលមានចំណងជើងថា «ពេលម៉ែឃ្លាតទៅ» ជាប់ជ័យលាភីលេខ១ស្មូន នៅក្នុងកម្មវិធីអក្សរសិល្ប៍ស្មីករិតលើកទី១ ឆ្នាំ ២០២០ ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសមាគមអ្នកនិពន្ធខ្មែរ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណចំពោះអ្នករស់រានមានជីវិតប្រមាណ៥លាននាក់ ដែលបានបន្តកត់ត្រាសាច់រឿង និងនិទានរឿងរ៉ាវទាំងនោះ ដើម្បីជាឯកសារសម្រាប់មនុស្សជំនាន់ក្រោយបានសិក្សាស្វែងយល់ដើម្បីការពារខ្លួនឯង និងសង្ឃឹមកុំឲ្យធ្លាក់ទៅក្នុងមនោគមវិជ្ជាជ្រុលនិយម ការស្អប់ខ្ពើម ការប្រកាន់ការរើសអើងជាតិសាសន៍ និងការចងកំហឹង ដែលសុទ្ធសឹងជាហេតុផលអាចនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍។

**ចម្រៀងបដិវត្តន៍ខ្មែរក្រហម**
**សូមជូនពរចំពោះបងប្អូនតំបន់ព្រះវិហារ**

| | |
|---|---|
| តំបន់ព្រះវិហារ | តំបន់ខ្លាំងក្លា ជាប់ភ្នំដងរែក មានស្រុក១៤ ល្អល្អះប្លែកៗ<br>ចម្រើនគ្រប់ផ្នែក បង្អែកបដិវត្តន៍។ |
| ពីល្បាក្រសាំង | វាលស្នាចរវៀង កោះពោនកំពត សាមគ្គីជោគជ័យ ឆ្នាត់ម្លូ ឡឥដ្ឋ<br>ជ័យសែនភ្ញាប្រាច់ មុីនរាជភូមិថ្មី។ |
| ពើបទួលពុទ្រា | សង្គមថ្មីជា ប្រសៀនទួលត្រី ស្រណោះភ្នំត្បែង គូលែនត្រពាំងបី<br>ខ្ទមពរថ្មី ជាំក្សាន្តភ្នំមិត្ត។ |
| វីរភាពតស៊ូ | ជាប់កំពង់ពោធិ៍ និងស្រឡៅពិត ជិតព្រះរំកិល ដូនទុនប្រាកដ<br>ថា ឡាបវីវត សៀមបូកគោព្រះ។ |
| បងប្អូនប្រយុទ្ធ | អង់អាចមោះមុត ជម្នះឧបសគ្គ តាំងពីសង្គ្រាម ជាបង្អែកជាក់<br>ខ្លាំងក្លាយអនគ្ឃ សមរភូមិមុខ។ |
| ក្រោយថ្ងៃ១៧ | មេសាជោគជ័យ បងប្អូនសម្រុក បង្កើនផលា ខ្លាំងពេញបន្ទុក<br>ស្រួចស្រាវទៅមុខ ឥតបីស្រាកស្រាន្ត |
| យើងខ្ញុំជូនពរ | សួស្តីបវរ បងប្អូនគ្រប់ប្រាណ តំបន់ព្រះវិហារ ចម្រើនថ្កើងថ្កាន<br>សូមបងប្អូនមាន សុខភាពបរិបូរណ៍។ |
| បងប្អូនសម្រុក | លើកភ្លឺទំនប់ កាន់តែសន្ធោ សម្រេចជោគជ័យ រួមសាងនគរ<br>កម្ពុជាបវរ ប្រជាធិបតេយ្យអើយ។ |





# បូជាភ្លើង

## សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប

រហឺ ប្រាយ

(តពីលេខមុន)




ពិព័រណ៍រូបថតនៅសារមន្ទីរស្តុតថូហ្វ ក្នុងទីក្រុងដាស្ក័នៃប្រទេសប៉ូឡូញ។ (សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

### "តើសាលារៀនអាចជួយយើងឱ្យជៀសផុតពីរឿងដែលស្រដៀងនេះបានយ៉ាងដូចម្តេច?"

សំណួរមួយដែលខ្ញុំត្រូវបានសួរជាញឹកញាប់គឺថា «តើយើងអាចជៀសវាងពីការកើតឡើងនូវរឿងនេះម្តងទៀតបានយ៉ាងដូចម្តេច?» ខ្ញុំអាចគិតឃើញអំពីវិធីមួយប៉ុណ្ណោះ។ វាគឺតាមរយៈការប្រៀនប្រដៅកូនៗរបស់យើង។ ការប្រៀនប្រដៅទូទៅ និងការអប់រំជាពិសេសនៅតាមសាលារៀន គឺដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចនូវអ្វីដែលអាចនឹងកើតឡើងនៅថ្ងៃស្អែកបាន។ មិនមែនកុមារគ្រប់រូបទាំងអស់ធំធាត់ឡើងនៅក្នុងផ្ទះដែលមានសីលធម៌រឹងមាំនោះទេ។ កុមារទាំងនេះមានឱកាសក្នុងការជួបប្រទះពិភពមួយផ្សេងទៀត ដូចជានៅក្នុងសាលារៀនពួកគេអាចជួបជាមួយគ្រូបង្រៀនដែលអាចលើកឡើងនូវសំណួរមួយចំនួនដែលពួកគេមិនដែលគិតចង់សាកសួរ។

វានឹងមិនគ្រប់គ្រាន់នោះទេដែលចំណាយពេលមួយម៉ោងឬពីរម៉ោងនៅក្នុងថ្នាក់ប្រវត្តិសាស្ត្រដើម្បីរៀនអំពីហូឡូខសត៍។ ការបង្រៀនគឺត្រូវតែចាប់ផ្តើមឲ្យបានឆាប់ជាងនេះដូចជានៅក្នុងថ្នាក់មត្តេយ្យជាដើម។ សូម្បីតែ

ក្មេងតូចៗក៏អាចយល់អំពីរឿងអយុត្តិធម៌ និងការរើសអើងបានដែរ ប្រសិនបើយើងបង្រៀនស្របតាមកម្រិតដែលពួកគេអាចទទួលយកបាន។ កុមារដែលមានអាយុចាប់ពី១០ទៅ១២ឆ្នាំ ជាធម្មតា គឺជាអ្នកគាំទ្រធំបំផុតនៅពេលដែលខ្ញុំទៅបង្រៀននៅសាលារៀន។ កុមារទាំងនោះចង់ដឹងចង់ឃើញហើយចង់រៀន និងមានសំណួរសួរច្រើនទៀតផង ដែលខុសគ្នាពីក្មេងជំទង់ដែលពេលខ្លះមានការពិបាកក្នុងការសួរសំណួរ។ ហូឡូ-ខូស្ត៍ បានកើតឡើងហើយប្រសិនបើត្រូវបានបំភ្លេចចោលរឿងនេះអាចនឹងកើតឡើងម្តងទៀត។ នោះហើយជាមូលហេតុដែលសាលារៀនត្រូវប្រាកដប្រជាថាក្មេងៗបានដឹងអំពីប្រវត្តិសាស្ត្រយ៉ាងលម្អិតចំពោះរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសអាល្លឺម៉ង់ចាប់ពីឆ្នាំ១៩២០ ដល់ ឆ្នាំ១៩៤៥។ មេរៀនប្រវត្តិសាស្ត្រត្រូវតែបង្រៀនអំពីអ្វីដែលបានកើតឡើង ហើយទៅតាមរបៀបមួយដែលអាចជិតជាប់ក្នុងអារម្មណ៍របស់កុមារទាំងនោះ។ អស់រយៈពេលជាច្រើនឆ្នាំ ដែលមនុស្សជាច្រើនបានគិតថា គឺមានសារសំខាន់ណាស់ដែលកុមារត្រូវរៀនអំពីកាលបរិច្ឆេទ និងឈ្មោះសំខាន់ៗនៃសមរភូមិ។ កុមារត្រូវបានបង្រៀនតាមរបៀប «រៀនយ៉ាងរ៉ក់រ៉ី»។ សិស្សទាំងនោះបានក្លាយទៅជាអ្នកស្ម័យប្រវត្តិកម្មដែលអាចរៀបរាប់បានអំពីព្រឹត្តិការណ៍ដែលបានកើតឡើងដោយមិនបានយល់ដឹងច្បាស់អំពីអ្វីទាំងអស់ ។

ដើម្បីសម្រេចបាននូវការយល់ដឹងដ៏ត្រឹមត្រូវ និងជ្រៅជ្រះមួយ ការអប់រំត្រូវតែជ្រាបឲ្យដល់បេះដូងរបស់សិស្សទាំងនោះ។ វិធីបង្រៀនដែលមានតាមរយៈការបង្ហាញអំពីព្រឹត្តិការណ៍ធំៗ ដែលកើតឡើងនៅក្នុងពិភពលោកតូចមួយ ដោយយករឿងរ៉ាវជីវិតបុគ្គលម្នាក់ៗ ជាចំណុចចាប់ផ្តើមដើម្បីពណ៌នាអំពីសម័យកាលមួយ។ មេរៀនត្រូវតែចាប់ផ្តើមនៅក្នុងពេលឥឡូវនេះ។ ស្វែងរកព្រឹត្តិការណ៍ណាមួយដែលងាយស្រួលក្នុងការផ្សារភ្ជាប់ទៅនឹងអតីតកាល និងបង្កើនការយល់ដឹងចំពោះរឿងរ៉ាវដែលងាយនឹងកើតឡើងនៅពេលអនា-គតកាល។ មនុស្សម្នាក់ៗត្រូវតែចង្អុលបង្ហាញអំពីការទទួលខុសត្រូវរបស់បុគ្គលម្នាក់ចំពោះខ្លួនឯង និងសង្គមព្រមទាំងបង្ហាញថា តើវាមានគ្រោះថ្នាក់យ៉ាងណានៅពេលដែលយើងនៅស្ងៀមស្ងាត់។ គឺមានសារសំខាន់ខ្លាំងណាស់ដែលរឿងរ៉ាវ ហូឡូខូស្ត៍ ត្រូវបានដាក់បញ្ចូលនៅក្នុងគ្រប់មុខវិជ្ជាទាំងអស់ ចាប់ផ្តើមពីសាសនា និងភូមិសាស្ត្រ ការអប់រំកាយ និងគីមីវិទ្យា។ វាក៏មានសារសំខាន់ខ្លាំងណាស់ដែរដែលគ្រូបង្រៀនទាំងអស់ដឹង និងនិយាយប្រាប់សិស្សរបស់ខ្លួនថា តើមុខវិជ្ជារបស់ពួកគេត្រូវបានប៉ះពាល់ខ្លាំងយ៉ាងណា បន្ទាប់ពីអ្វីដែលបានកើតឡើងនៅពេលនោះ។ ការអប់រំក៏គួរតែកើតឡើងដោយ «ការធ្វើ»។ ឧទាហរណ៍ នៅក្នុងថ្នាក់សិល្បៈគួរតែមានឱកាសសម្រាប់ឲ្យសិស្សបង្ហាញអំពីអារម្មណ៍របស់ខ្លួន ពង្រឹងនូវអ្វីដែលពួកគេបានរៀន និងដឹងអំពីអារម្មណ៍របស់ពួកគេបន្ទាប់ពីរៀនមេរៀនរួច។ បន្ទាប់ពីអានសៀវភៅដែលសមស្របសិស្សអាចធ្វើសកម្មភាពជាមួយដីឥដ្ឋ គំនូរ រូបភាពរចនាដោយក្រដាសគំនូរសិល្បៈដែលទាក់ទាញអារម្មណ៍របស់ពួកគេ។

ជាទូទៅ គ្រូបង្រៀនតែងតែមានគំនិតច្នៃប្រឌិត ហើយការប្រជុំពិគ្រោះយោបល់អាចពង្រីកវិធីសាស្ត្របង្រៀនអំពីហូឡូខូស្ត៍បាន។ គ្រូបង្រៀនល្អអាចក្លាយទៅជាគំរូរបស់សិស្សបាន។ នៅក្នុងស្ថានភាពវិបត្តិដែលតែងតែមាននៅលើវិថីជីវិតរបស់មនុស្សគ្រប់រូប គ្រូបង្រៀនអាចធ្វើឲ្យមានការផ្លាស់ប្តូរដ៏ធំមួយបាន។

## "តើអ្នកមានទស្សនៈយ៉ាងណាចំពោះអនាគតកាល?"

ខ្ញុំមិនជឿថា ទស្សនៈរបស់ខ្ញុំខុសពីអ្នកដទៃនោះទេ នៅពេលដែលគិតអំពីពិភពលោកសព្វថ្ងៃនេះ។ ខ្ញុំមើលឃើញនយោបាយដែលវិលត្រឡប់ទៅរកការប្រឆាំងនឹងការកែទម្រង់ថ្មី ការកើនឡើងនៃការប្រឆាំងជនជាតិជ្វីហ្វ ការស្អប់ខ្ពើមជនបរទេស និងការបំផ្លិចបំផ្លាញបរិស្ថាន។ សម្រាប់ខ្ញុំ ការបើកទំព័រកាសែតអានជារៀងរាល់ពេលព្រឹក គឺជាបទពិសោធន៍ដ៏វេទនាមួយ។

ទោះបីជាបែបនេះហើយ ខ្ញុំនៅតែមានសេចក្តីសង្ឃឹម។ ក្រឡេកមើលទៅសតវត្សរ៍កន្លងមក ចាប់តាំងពីដើមដំបូងយើងឃើញថា សន្តិភាពនិងវិបុលភាព ជារឿយៗបានកើតឡើងបន្ទាប់ពីជម្លោះ។ មានន័យថា គឺមានដំណើរការទៅមុខ ក៏ប៉ុន្តែគឺទៅតាមរូបរាងដូចគូទខ្យង។ នៅពេលនេះយើងមិនស្ថិតនៅក្នុងកន្លែងដែលល្អនោះទេប៉ុន្តែអ្វីៗនឹងផ្លាស់ប្តូរហើយមិនយូរប៉ុន្មាន យើងនឹងមានដំណើរការទៅមុខម្តងទៀត។

នៅពេលដែលខ្ញុំមើលទៅយុវវ័យសព្វថ្ងៃនេះ ខ្ញុំមានអារម្មណ៍សុទិដ្ឋិនិយម។ ពួកគេបានក្លាយទៅជាមនុស្សដែលដឹងអំពីខ្លួនឯង និងមានចំណេះដឹងខ្ពស់ ហើយមានការចាប់អារម្មណ៍ច្រើនទៅលើពិភពលោកជាងពេលដែលយើងមានអាយុស្របាលពួកគេ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថាយុវវ័យសព្វថ្ងៃនេះមានឆន្ទៈ និងសក្តានុពលក្នុងការដោះស្រាយបញ្ហានាពេលបច្ចុប្បន្ននេះ។

នៅពេលដែលខ្ញុំជួបជាមួយយុវវ័យបច្ចុប្បន្ននេះ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះការផ្លាស់ប្តូររបស់ពួកគេក្នុងអំឡុងពេលជាច្រើនឆ្នាំដែលខ្ញុំបានបង្រៀន។ ពួកគេបានផ្លាស់ប្តូរពីការបង្ហាញចំណាប់អារម្មណ៍បន្តិចបន្តួចទៅជាការចាប់អារម្មណ៍កាន់តែច្រើនឡើងៗ។ ពួកគេចាប់ផ្តើមសួរសំណួរបន្ថែម និងទទួលយកចំណេះដឹងដែលជ្រាបដល់ស្មារតីព្រមទាំងបេះដូងរបស់ខ្លួន។ ការយល់ដឹងរបស់យុវវ័យទាំងនោះ គឺតាមរយៈបញ្ញា និងសតិអារម្មណ៍។

នាចុងបញ្ចប់នៃការបង្រៀនរបស់ខ្ញុំ មានសិស្សមួយចំនួនបានប្រាប់ខ្ញុំថា «កុំបារម្ភ យើងនឹងចែកចាយអំពីអ្វីដែលអ្នកបានប្រាប់យើង ពីព្រោះយើងមិនចង់ឲ្យវាកើតឡើងម្តងទៀតនោះទេ»។ ខ្ញុំក៏ជឿជាក់ដែរថា អ្នកគ្រប់គ្រងសាលារៀនបានចាប់ផ្តើមយល់អំពីសារសំខាន់ក្នុងការបន្តតស៊ូប្រឆាំងអំពីការបំភ្លេច ហើយនេះគឺជាសញ្ញាដ៏ល្អមួយ។ ប្រសិនបើ មនុស្សគ្រប់ពណ៌សម្បុរគ្រប់សាសនាជាតិសាសន៍ និងគ្រប់អាយុទាំងអស់ ក្រោកឈរឡើងប្រឆាំងនឹងអ្នកដែលមិនយល់ថា តើពួកគេរស់នៅដោយសុខសាន្តក្រោមលទ្ធិប្រជាធិបតេយ្យរបស់យើងយ៉ាងដូចម្តេចនោះ។ យើងនឹងអាចប្រកាន់បាននូវជំហរដែលយើងមាន។

## "តើយើងអាចរៀនសូត្របានអ្វីខ្លះអំពីហូឡូខូស្ត៍?"

ខ្ញុំបានឆ្លងកាត់រឿងរ៉ាវជាច្រើន ប៉ុន្តែនៅតែអាចមានជីវិតបានយូរហូតអាចឈានដល់វ័យចំណាស់។ ខ្ញុំនិពន្ធសៀវភៅ អត្ថបទកាសែត និងបានបង្រៀនអស់រយៈពេល៣០ឆ្នាំមកហើយ។ អ្វីដែលខ្ញុំតែងតែចង់និយាយ និងនៅតែធ្វើ គឺរៀនអំពីបទពិសោធន៍របស់ខ្ញុំនិងអ្នកដទៃ។ នេះគឺជាការលំបាក ប៉ុន្តែក៏ជាមធ្យោបាយតែមួយគត់ដើម្បីគេចផុតពីការឈឺចាប់ដែលយើងបានទទួលរងនៅក្នុងហូឡូខូស្ត៍។

ខេានទេស៍ម្នាក់ ដែលជាកូនស្រីរបស់ឯកអគ្គរដ្ឋទូតអេស្ប៉ាញ ដែលផ្ទះរបស់គាត់ធ្លាប់ជាកន្លែងជួបជុំរបស់គូប្រជែង ហ៊ីត្លែរ បាននិយាយនៅក្នុងឆ្នាំ ១៩៤៨ ថា ពិភពលោកមិនបានរៀនអ្វីសោះពីយាតករ ជនរងគ្រោះ ឬ អ្នកដែលបានត្រឹមតែឈរមើលបំណាំឡើយ។ ពេលវេលារបស់យើង គឺប្រៀបបានដូចជាការរាំរែកជាមួយនឹងសេចក្តីស្លាប់ ហើយមានមនុស្សតិចណាស់ដែលយល់ពីចង្វាក់ដ៏ចម្លែករបស់វា។

ពាក្យនេះ គឺត្រឹមត្រូវណាស់សម្រាប់ធ្វើការបកស្រាយអំពីស្ថានភាពសព្វថ្ងៃនេះ។ ប៉ុន្តែយើងមិនត្រូវទទួលយក ឬ អនុញ្ញាតឲ្យខ្លួនយើងរស់នៅសុខសាន្តជាមួយនឹងវាឡើយ។ យើងមិនត្រូវបោះបង់ចោលការតស៊ូនោះទេ យើងត្រូវតែបន្តផ្សព្វផ្សាយចំណេះដឹងដើម្បីជួយដល់យុវវ័យជំនាន់ថ្មីឲ្យយល់ដឹងច្បាស់អំពីចង្វាក់របស់វា ហើយជៀសវាងកំហុសឆ្គងរបស់មនុស្សកាលពីជំនាន់មុន។

តើចង្វាក់នេះគឺជាអ្វី? នោះគឺជាមេដឹកនាំដែលមានកលល្បិចទាញយកផលប្រយោជន៍ពីការមិនសប្បាយចិត្តរបស់ប្រជាជនជាមួយកាលៈទេសៈបច្ចុប្បន្ន មកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន។ មេដឹកនាំទាំងនោះផ្តល់ចម្លើយងាយៗចំពោះសំណួរស្មុគស្មាញ និងសន្យាឲ្យប្រជាជននូវអនាគតនៃសុភមង្គលជានិរន្តរដែលហួសវិស័យ។ ព្យាការីក្លែងក្លាយទាំងនេះងាយនឹងធ្វើឲ្យប្រជាជនជឿ ហើយធ្វើឲ្យមានភាពងាយស្រួលក្នុងការធ្លាក់ក្នុងអំពើអាក្រក់។ លុះយូរបន្តិចក្រោយមក ទើបមានអ្នកកត់

សម្គាល់ថា ការសន្យាទាំងនេះគឺមានផលអវិជ្ជមាន។ សេចក្តីសង្ឃឹមមិនត្រូវបានបំពេញហើយយើងបានបាត់បង់សេរីភាព និងផ្ទះរបស់ខ្លួន។ អ្វីដែលយើងមានអារម្មណ៍មិនពេញចិត្តជាមួយពីកាលដំបូងបានក្លាយទៅជាអ្វីមួយដែលយើងកំពុងតែចង់បានយ៉ាងខ្លាំង។

ប្រទេស អាល្លឺម៉ង់ បានផ្លាស់ប្តូរសាធារណរដ្ឋវៀម៉ា ដើម្បីក្តីសុបិនពាន់ឆ្នាំរបស់ហ៊ីត្លែរ ដែលនាំឲ្យប្រទេសនោះសល់តែភាពវិនាសហិនហោច។ ងាកត្រឡប់ទៅឆ្នាំ១៩១៨ វិញ យើងឃើញថាយុវជនវ័យក្មេងរបស់ប្រទេសអាល្លឺម៉ង់ និងប្រទេសបារាំងបានសម្រុកចូលទៅក្នុងភ្លក់ភ្លើងសង្គ្រាមយ៉ាងស៊ុតស្វាញ។ យុវជនវ័យក្មេងទាំងនោះវិលត្រឡប់មកវិញបន្ទាប់ពី ៤ឆ្នាំ មកក្នុងប្រទេសអឺរ៉ុបដែលខូចខាតខ្ទេចខ្ទាំជាមួយនឹងពាក្យវិប្បដិសារីថា «គ្មានសង្គ្រាមទៀតទេ»។ បច្ចុប្បន្ននេះជាថ្មីម្តងទៀតយើងមិនសប្បាយចិត្តជាមួយនឹងស្ថានភាពបច្ចុប្បន្ន។ តើវានឹងនាំយើងទៅរកអ្វី? តើវានិងចាប់ផ្តើមនៅទីណានិងពេលណា?

នៅពេលដែលយើងក្រឡេកមើលទៅក្រោយវិញ ខណៈពេលដែលប្រវត្តិសាស្ត្រចាប់ផ្តើមដំបូង។ យើងឃើញថា បន្ទាប់ពីសង្គ្រាម គឺតែងតែមានភាពស្ងៀមស្ងាត់ ជាពេលវេលាដែលភ្លើចែងចាំង បន្ទាប់មកក៏ងងឹតម្តងទៀត ហើយក៏បញ្ចប់នៅក្នុងភ្លើងសង្គ្រាមមួយទៀត។ តើយើងរកឃើញប្រភពដើមនៃគំរូនេះទេ?

ខ្ញុំគិតថា វាបានចាប់ផ្តើមនៅពេលដែលមានហេតុផលដំបូងក្នុងការប្រើប្រាស់ទស្សនវិស័យនៃ «ពួកយើង» និង «ពួកគេ»។

ជាមួយនឹងទស្សនៈនេះ យើងសាកល្បងវិលត្រឡប់ទៅមនុស្សយុគសម័យដំបូងដែលបានបង្កើតសហគមន៍កសិកម្មដំបូងបង្អស់។ ក្រុមគ្រួសារនីមួយៗ រស់នៅដាច់ដោយឡែកពីគ្នាដោយគ្មានទំនាក់ទំនងអ្វីទាំងអស់ ហើយនៅពេលដែលសមាជិកគ្រួសាររបស់ខ្លួនកើនឡើង និងចាប់ផ្តើមមានអារម្មណ៍ថា ត្រូវការទីធ្លាបន្ថែម ពួកគេបានក្រឡេកមើលទៅសហគមន៍ជិតខាង។ ដោយការយកឈ្នះលើដីរបស់ «ពួកគេ» «ពួកយើង» មានទីធ្លាដើម្បីដកដង្ហើម ហើយមានភាពស្ងប់ស្ងាត់មួយគ្រាមុនពេលដែលសង្គមចាប់ផ្តើមរីកចម្រើនសារជាថ្មីម្តងទៀត។ មនុស្សមាននិស្ស័យអាត្មានិយម ដែលដំបូងឡើងមាន «ខ្ញុំ» បន្ទាប់មកមាន «យើង» ហើយអ្នកផ្សេងទៀតគឺ «គេ» ព្រមទាំងជនបរទេសដែលយើងមិនស្គាល់ និងអ្នកដែលគ្មានអ្វីពាក់ព័ន្ធជាមួយយើង។

ច្រើនឆ្នាំកន្លងផុតទៅ ចំនួនប្រជាជននៅលើផែនដីបានកើនឡើង ហើយស្របពេលដែលខួរក្បាលរបស់មនុស្សបានវិវឌ្ឍន៍ ឥរិយាបថរបស់យើង គឺនៅតែដូចដើម។ ជាមួយនឹងពេលវេលា ការកើនឡើងនូវតម្រូវការនៃកន្លែងរស់នៅ បានធ្វើឲ្យមានអាណានិគមនិយមដែលរីករាលដាលកាន់តែច្រើនឡើងៗ។ ដើម្បីសម្រួលមនសិការរបស់ជនជាតិស្បែកសចំពោះការដាក់អាណានិគម ទ្រឹស្តីនៃពូជសាសន៍បានផ្សព្វផ្សាយ ដែលក្នុងនោះ យើងអាចយកដំណើរស្វែងរករបស់អ្នកវិទូឈ្មោះដាវីន អំពីក្រុមសត្វមកធ្វើជាគំរូដើម្បីបកស្រាយ។

តើខ្ញុំបានរៀនអំពីអ្វីខ្លះដែលខ្ញុំចង់ចែករំលែកបន្ត? ដំបូងនិងសំខាន់បំផុតនោះ មនុស្សគឺដូចគ្នាទាំងអស់។



ពិព័រណ៌រូបថតនៅសារមន្ទីរស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ។ (សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)







ពិព័រណ៌រូបថតនៅសារមន្ទីរស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ។ (សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបានរៀនអំពីវាតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន។ ពេលដែលខ្ញុំនៅក្មេង សម្រាប់ខ្ញុំ គឺជារឿងធម្មតាដែលមានអ្នកអភិជននិងអ្នកបម្រើ។ យើងមិនមែនជាអ្នកមានស្តុកស្តម្ភទេ ប៉ុន្តែយើងក៏មានអ្នកបម្រើដែលចាំជួយធ្វើការងារផ្ទះដែរ។ អ្នកបម្រើរបស់យើង តែងតែក្រោកពីព្រលឹមដើម្បីបង្កាត់ភ្លើង ដើម្បីកុំឲ្យយើងរងារនៅពេលបរិភោគអាហារពេលព្រឹក។ ខ្ញុំនៅតែអាចស្រមៃឃើញទឹកកកនៅលើបង្អួចដែលចាប់ផ្តើមរលាយសន្សឹមៗ ខណៈពេលដែលអ្នកបម្រើស្លៀកពាក់ឲ្យខ្ញុំយ៉ាងទន់ភ្លន់។ ខ្ញុំនៅតែបន្តប្រើនាងដដែល ទោះបីជាខ្ញុំបានក្លាយទៅជាក្មេងជំទង់ហើយយ៉ាងណាក៏ដោយ។ ពេលវេលានៅក្នុងជំរំបានបង្រៀនខ្ញុំថា នេះគឺជាទង្វើមួយដែលខុសឆ្គង ហើយយើងមិនត្រូវឲ្យវាកើតឡើងម្តងទៀតនោះទេ។ គ្មាននរណាម្នាក់គួរមានអំណាចទៅលើមនុស្សម្នាក់ទៀតទេ ហើយលុយ និងពូជសាសន៍ ក៏មិនមែនជាហេតុផលសមស្របមួយក្នុងការធ្វើទង្វើមិនល្អទៅលើមនុស្សដទៃទៀតដែរ។ ជាច្រើនសតវត្សរ៍កន្លងមកមនុស្សមួយចំនួនបានទិញដីបន្ថែម ដែលធ្វើឲ្យពួកគេមានអំណាចកាន់តែខ្លាំងឡើងៗ។ អ្នកមានអំណាចត្រួតត្រាលើអ្នកក្រីក្រ និងអ្នកទន់ខ្សោយជាង ហើយជាលទ្ធផល មនុស្សត្រូវបានគេបែងចែកតាមប្រភេទដែលប្រសើរជាងនិងអន់ជាង។ នៅដើមសតវត្សរ៍ទី ១៩ ការយល់ច្រឡំថា ដែលមនុស្សជាតិអាចបែងចែកបានទៅតាមជាតិសាសន៍ខុសៗគ្នា បានចាប់ផ្តើមរីករាលដាល។ នេះបានក្លាយទៅជាបុរេវិនិច្ឆ័យមួយដែលនៅតែឃើញមានសព្វថ្ងៃនេះ។ បុរេវិនិច្ឆ័យ គឺពិបាកក្នុងការប្រយុទ្ធប្រឆាំង ហើយភាពអាត្មានិយមរបស់មនុស្សមានន័យថា យើងទាំងអស់គ្នាចង់មានអារម្មណ៍ថាខ្លួនឯងល្អប្រសើរជាងអ្នកដទៃ។ មានជនជាតិ ស៊ុយអែត ជាច្រើនដែលមានមោទកភាពក្នុងការចាត់ទុកខ្លួនឯងជាពួកអារីយ៉ាន នៅពេលដែល ហ៊ីត្លែរ បានអះអាងថា សាសន៍ណ័រឌីក-អាល្លឺម៉ង់គឺល្អស្អាតជាងសាសន៍ដទៃទៀត។

ជនជាតិជ្វីហ្វ និងជនជាតិរ៉ូម ត្រូវបានគេប្រកាន់ពូជសាសន៍ចាប់តាំងពីការចាប់ផ្តើមនៃពេលវេលាដំបូង។ ធំធាត់ឡើងខ្ញុំត្រូវតែរស់នៅជាមួយការប្រកាន់ពូជសាសន៍ដែលប្រឆាំងនឹងជនជាតិជ្វីហ្វ ហើយនៅពេលជាមួយគ្នានោះដែរ វាក៏ជារឿងធម្មតាសម្រាប់ខ្ញុំដែលជនជាតិ

(តនៅលេខក្រោយ)

# ព្រលឹងប្តីខ្ញុំនៅវិលវល់

អ៊ុន សុជាទី



គំនរឆ្អឹងជនរងគ្រោះពីរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃមួយនៅក្នុងខ្ទម កូនប្រុសច្បងរបស់ខ្ញុំបានស្រែកហៅខ្ញុំខ្លាំងៗថា «ម៉ែៗ! ឪមកវិញហើយ!»។ អារម្មណ៍របស់ខ្ញុំវិលវល់នៅពេលឮពាក្យនេះ។ ខ្ញុំដើរប្រញាប់ប្រញាល់សំដៅទៅខ្ទម ដោយក្នុងចិត្តនឹកគិតថា ប្តីរបស់ខ្ញុំប្រហែលជានៅមានជីវិតរស់នៅឡើយ។ ខ្ញុំបានសួរកូនខ្ញុំថា «ឯណា! ម៉ែមិនឃើញឪពុកកូន»។ កូនរបស់ខ្ញុំបានស្ងាត់មាត់មួយរយៈ ហើយបានរៀបរាប់ថា «ខ្ញុំបានឃើញឪឈរនៅក្រោមដើមស្វាយ ខាងមុខផ្ទះនេះ។ ឪស្លៀកខោក្រឡាត្រឹមភ្លៅ ដោះអាវ ហើយថែមទាំងញញឹមដាក់ខ្ញុំទៀត»។ ឮកូននិយាយដូច្នេះ ខ្ញុំបានស្រែកយំខ្លាំងៗ និងមិនបាននិយាយស្តីទៀតឡើយ។ ខ្ញុំមិនបានឃើញប្តីរបស់ខ្ញុំនៅក្រោមដើមស្វាយនោះទេ។ ថ្ងៃនោះគឺជាគម្រប់ ៧ថ្ងៃរបស់ប្តីខ្ញុំ បន្ទាប់ពីខ្មែរក្រហមបានយកគាត់ចេញទៅ។ ខ្ញុំគិតថា ព្រលឹងរបស់ប្តីខ្ញុំនៅវិលវល់ ហើយបានតាមមករកកូន និងប្រពន្ធ។

ខ្ញុំឈ្មោះ អ៊ូ សាវ៉ាន់ ហៅ នាង សព្វថ្ងៃនេះមានអាយុ ៦២ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិ ត្រពាំងភ្លោះ ឃុំជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង។ ខ្ញុំគឺជាអតីតពេទ្យឆ្មបដែលទើបតែចូលនិវត្តន៍។ ប្តីរបស់ខ្ញុំឈ្មោះ ចាន់ សុវណ្ណ។ ខ្ញុំមានបងប្អូនចំនួន ៧នាក់ ស្រី៤នាក់ និងប្រុស៣នាក់។ ឪពុករបស់ ខ្ញុំគឺជាអតីត អ្នកលេងភ្លេងការនៅក្នុងសម័យសង្គមចាស់។ ក្រោយមក ក្រុមគ្រួសាររបស់ខ្ញុំបានផ្លាស់ប្តូរ ទីលំនៅទៅរស់នៅក្នុងខេត្តកំពង់ចាម។ នៅក្នុងរបបខ្មែរក្រហម ឪពុកខ្ញុំគឺជាប្រធានសហករណ៍ក្នុងខេត្តកំពង់ចាម រីឯម្តាយខ្ញុំវិញគឺជាកសិករ។ ឪពុកខ្ញុំត្រូវខ្មែរក្រហមវាយសម្លាប់នៅឯខេត្តកំពង់ចាម។ រីឯ ម្តាយខ្ញុំវិញ មានជំងឺរេងរាំង ហើយក្រោយមកក៏ឈឺស្លាប់ដែរ។ បងប្រុស ២នាក់របស់ខ្ញុំគឺជាយោធានៅខេត្តស្វាយរៀង ហើយត្រូវខ្មែរក្រហមសម្លាប់ និងប្អូនប្រុសម្នាក់ទៀត គឺជាអ្នកដឹកជញ្ជូនគ្រាប់រំសេវបាន ក្រឡាប់រទេះស្លាប់ដែរ។

ខ្ញុំរៀបការនៅក្នុងសម័យសង្គមរាស្ត្រនិយម និងមានកូនប្រុស ២នាក់។ នៅពេលដែលខ្មែរក្រហម ចូលមកកាន់កាប់ខេត្តស្វាយរៀងបានទាំងស្រុង ខ្ញុំនិងប្តី ដែលចេះវិជ្ជាពេទ្យតាំងពីដើម ត្រូវបានខ្មែរក្រហមចាត់ឲ្យខ្ញុំបន្តធ្វើជាពេទ្យឆ្មប ហើយប្តីខ្ញុំជាពេទ្យផ្នែកដាក់ថ្នាំសណ្តំ។ រស់នៅទីនោះ ខ្ញុំបានជួយបង្កើតកូនឲ្យស្ត្រីជាច្រើននាក់ ហើយមិនដែលជួបប្រទះនឹងគ្រោះថ្នាក់អ្វីឡើយ។ ខ្ញុំបានប្រើប្រាស់ថ្នាំម៉្យាងដែលមាន ឈ្មោះថា អុកស៊ីតូស៊ីនជួយដល់អ្នកឆ្លងទន្លេទាំងអស់នោះ។ រស់នៅក្នុងឃុំជ្រៃធំ ខ្ញុំមិនសូវជួបប្រទះនឹងការលំបាកខ្លាំងទេ ប៉ុន្តែនៅពេលដែលខ្មែរក្រហមភូមិភាគនិរតីចូលមកកាន់កាប់ប្រជាជននៅទីនេះ ត្រូវបានជម្លៀសចេញពីភូមិ និងប្រជាជនមូលដ្ឋានខ្លះត្រូវបានចោទប្រកាន់ថាក្បត់ និងយកទៅសម្លាប់ចោល។

នៅអំឡុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ នៅទីកន្លែងដែលខ្ញុំរស់នៅចាប់ផ្តើមមានភាពវឹកវរ។ ខ្ញុំឃើញមានខ្មែរក្រហមពីភូមិភាគនិរតីចូលមកគ្រប់គ្រង និងចាប់ផ្តើមមានជម្លោះនៅក្នុងតំបន់ ដោយមានការប្រយុទ្ធគ្នា ជារឿយៗ។ ប្រជាជនត្រូវបានជម្លៀសចេញពីភូមិទាំងអស់ដែលភាគច្រើនជម្លៀសទៅរស់នៅ ភូមិភាគពាយ័ព្យ រួមមាន ខេត្តកំពង់ឆ្នាំង បាត់ដំបង និង ពោធិ៍សាត់ជាដើម។ ខ្ញុំ ប្តី និងប្អូនស្រី ក៏ត្រូវជម្លៀសចេញពីភូមិដែរ។ ពេលនោះ ខ្ញុំកំពុងតែមានផ្ទៃពោះកូនប្រុស ទី២ របស់ខ្ញុំដែលហៀបនឹងកើតទៅ ហើយ។ យើងធ្វើដំណើរដោយថ្មើរជើងមកដល់ភ្នំឈើកាច់ ខ្មែរក្រហមក៏ឲ្យយើងស្នាក់នៅទីនោះ។ នៅភ្នំឈើកាច់មានសភាពស្ងាត់ជ្រងំ គ្មានផ្ទះ គ្មានមនុស្សរស់នៅឡើយ។ ខ្មែរក្រហមបានឲ្យយើងរស់នៅទីនោះមួយរយៈសិន។ ខ្ញុំបានធ្វើស្រែ និងលីសែងបាវស្រូវតាមតែអ្វីដែលខ្មែរក្រហមបញ្ជា។ ប្តីរបស់ខ្ញុំចេញទៅធ្វើការងារនៅតាមចម្ការ។ ចំណែកកូនៗរបស់ខ្ញុំត្រូវយកទៅផ្ញើយាយៗឲ្យមើលថែរក្សា។ មិនយូរប៉ុន្មាន ខ្ញុំក៏បានបង្កើតកូនប្រុស ទី ២របស់ខ្ញុំ។ នៅពេលនោះ ប្តីរបស់ខ្ញុំនិងអ្នកជិតខាងបានជួយបង្កើតកូនឲ្យខ្ញុំ។ រដូវវស្សាបានមកដល់ ទឹកក៏ចាប់ផ្តើមឡើងខ្លាំង។ យើងមិនអាចរស់នៅទីនោះបានទៀតទេ ព្រោះទឹកលិចគ្រប់ទីកន្លែងនៅជុំវិញខ្លួន។ ខ្មែរក្រហម បានជម្លៀសប្រជាជនចេញពីភ្នំឈើកាច់ឲ្យទៅកាន់ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ ខ្ញុំ ប្តី និង កូន បានធ្វើដំណើរទៅទៅដល់ខេត្តពោធិ៍សាត់។ នៅតាមផ្លូវ យើងដើរឆ្លងទឹកដែលមានជម្រៅត្រឹមដើមទ្រូង។ ប្តីរបស់ខ្ញុំបានលើកកូនប្រុសច្បងដាក់នៅលើស្មា ចំណែកខ្ញុំបីកូនប្រុសពៅដែលទើបនឹងកើត។ យើងបានដើរទៅមុខរហូតដល់ភូមិអូរតាប៉ោង ឃុំបឹងខ្នា ស្រុកបាកានលើ ខេត្តពោធិ៍សាត់។ យើងបានរស់ និងធ្វើការងារយ៉ាងលំបាកនៅទីនោះ។ យើងមិនដែលទទួលបានរបបអាហារគ្រប់គ្រាន់ឡើយ។ ប្តីរបស់ខ្ញុំនិងខ្ញុំ បានលាក់ប្រវត្តិរូបជាគ្រូពេទ្យ។ ប៉ុន្តែថ្ងៃមួយ នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានស៊ើបដឹងថាប្តីរបស់ខ្ញុំ គឺជាគ្រូពេទ្យមកពីខាងបូព៌ា។ ខ្មែរក្រហម បានយកប្តីខ្ញុំទៅវាយទម្លាក់ចូលទៅក្នុងរណ្តៅមួយនៅក្នុងវត្តបឹងខ្នារនៅក្នុងភូមិដែលខ្ញុំរស់នៅ។ ខ្ញុំបានដឹងរឿងនេះតាមរយៈបុរសម្នាក់ដែលជាអ្នកឡើងត្នោតប្រាប់ខ្ញុំថា នៅថ្ងៃនោះ ពេលគាត់កំពុងតែឡើងយកទឹកត្នោតនៅក្បែរវត្ត គាត់ក៏បានឃើញខ្មែរក្រហមចាប់ប្តីរបស់ខ្ញុំ និងមនុស្សប្រហែល ១០ នាក់ទៀតចង និងវាយសម្លាប់ទម្លាក់ចូលក្នុងរណ្តៅក្បែរនោះ។ បុរសនោះបានអះអាងថា រណ្តៅសាកសពនោះជ្រៅណាស់ និងមានសាកសពជាច្រើន។ គាត់ភ័យតក់ស្លុតយ៉ាងខ្លាំងនៅពេលឃើញការសម្លាប់យ៉ាងសាហាវឃោរឃៅបែបនេះ។ នៅថ្ងៃសម្លាប់នោះមេកងឈ្មោះ ដួន និងខ្មែរក្រហមម្នាក់ទៀតដែលខ្ញុំមិនស្គាល់ឈ្មោះ បានមកហៅប្តីខ្ញុំថាឲ្យទៅលីអំបិលនៅលើភ្នំ។ ប្រសិនបើខ្ញុំដឹងថា ខ្មែរក្រហមយកប្តីខ្ញុំទៅសម្លាប់យ៉ាងហោចណាស់ក៏យើងបាននិយាយលាគ្នាជាលើកចុងក្រោយដែរ។

បន្ទាប់ពីខ្មែរក្រហម យកប្តីខ្ញុំទៅសម្លាប់បានរយៈពេលពាថ្ងៃ កងទ័ពវៀតណាមក៏ចូលមកដល់ខេត្តពោធិ៍សាត់។ កម្មាភិបាល និងយោធាខ្មែរក្រហម ចាប់ផ្តើមគេចខ្លួនចូលទៅក្នុងព្រៃ។ ឃើញដូច្នេះ ខ្ញុំក៏បានរត់គេចចេញពីភូមិដែរ ព្រោះខ្ញុំគិតថា ខ្មែរក្រហមនឹងសម្លាប់ខ្ញុំទៀតនៅពេលដែលដឹងថា ខ្ញុំគឺជាគ្រូពេទ្យ។ ខ្ញុំបានទូលបង្វេចខោអាវនិងចានឆ្នាំង ចំណែកដៃម្ខាងរបស់ខ្ញុំពរកូន និងដៃម្ខាងទៀតដឹកដៃកូនច្បង ព្រោះខ្ញុំខ្លាចវង្វេងគ្នា។ ខ្ញុំដើរសំដៅមកស្រុកកំណើតវិញ។ ខ្ញុំមិនហ៊ានដើរនៅតាមផ្លូវជាតិទេ ព្រោះខ្លាចជួបកងទ័ពខ្មែរក្រហម។ នៅតាមផ្លូវ ខ្ញុំបានសុំអាហារអ្នកដំណើរ ឬប្រជាជនដែលរស់នៅតាមភូមិឲ្យកូនរបស់ខ្ញុំហូប។ ជើងទាំងសងខាងរបស់ខ្ញុំដំបៅ និងចេញឈាម ដោយសារតែខ្ញុំដើរដោយជើងទទេ។ ខ្ញុំដើរស្ទើរតែមិនរួច ព្រោះខ្ញុំឈឺជើង និងអស់កម្លាំង។ ខ្ញុំដេកនៅតាមផ្លូវជាច្រើនថ្ងៃពេលធ្វើដំណើរ ហើយពេលខ្លះ ខ្ញុំបានដេកនៅក្នុងព្រៃ។ ខ្ញុំដើររហូតដល់ខេត្តកំពង់ឆ្នាំង ក៏បានជួបនឹងប្អូនស្រីទាំង ៣នាក់របស់ខ្ញុំ។ អារម្មណ៍ពេលនោះ គឺហាក់បីដូចជាខ្ញុំបានរស់ឡើងវិញម្តងទៀត។ ខ្ញុំមិនមានអារម្មណ៍ថារស់នៅម្នាក់ឯងទៀតឡើយ។ ប្អូនស្រីទាំង៣នាក់របស់ខ្ញុំ បានជួយពរកូន និងស្ពាយអីវ៉ាន់ខ្លះរបស់ខ្ញុំ រហូតមកដល់ស្រុកកំណើតវិញ។ នៅពេលដែលខ្ញុំមកដល់ស្រុកកំណើតភ្លាម ខ្ញុំគ្មានសេសសល់អ្វីឡើយ។ ខ្ញុំត្រូវទៅស៊ីឈ្នួលច្រូតស្រូវ ស្ទូងស្រូវ ដើម្បីប្តូរយកអង្ករមកដាំហូប។ ជួនពេលខ្លះខ្ញុំដើរសុំអង្ករប្រជាជននៅក្នុងភូមិដែរ។ ខ្ញុំតែងតែនឹកគិតថា ប្រសិនបើប្តីខ្ញុំនៅមានជីវិតខ្ញុំនិងកូនប្រហែលជាមិនលំបាកទេ។

ពេលវេលាចេះតែកន្លងទៅ ប៉ុន្តែខ្ញុំនៅតែចងចាំមិនភ្លេចពីអនុស្សាវរីយ៍ទាំងឡាយជាមួយនឹងប្តីរបស់ខ្ញុំ។ ក្តីអាណិតអាសូរ និងស្រណោះដល់ប្តីនិងសាច់ញាតិ បានជំរុញទឹកចិត្តខ្ញុំឲ្យចូលរួមដាក់ញត្តិប្តឹងទៅកាន់អង្គការសហប្រជាជាតិ ឲ្យដកខ្មែរក្រហមចេញពីអង្គការសហប្រជាជាតិ កាលពីទសវត្សរ៍ឆ្នាំ ៨០ ។ ក្រោយមកខ្ញុំក៏បានដាក់ពាក្យបណ្តឹងទៅកាន់តុលាការខ្មែរក្រហម តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីស្វែងរកយុត្តិធម៌ឲ្យប្តី ឪពុកម្តាយ និងសាច់ញាតិរបស់ខ្ញុំ។ គួរឲ្យសោកស្តាយខ្ញុំមិនធ្លាប់បានមកទស្សនាតុលាការខ្មែរក្រហមផ្ទាល់ទេ។ ខ្ញុំទទួលបានដំណឹងថា មេដឹកនាំខ្មែរក្រហមត្រូវបានដាក់ពន្ធធនាគារអស់មួយជីវិត។ សព្វថ្ងៃនេះ ខ្ញុំមានអារម្មណ៍ធូរស្បើយ នៅពេលដែលប្រទេសមានសន្តិភាព និងមិនមានអំពើឃោរឃៅបែបនេះកើតឡើងម្តងទៀត។

ទោះបីរឿងរ៉ាវដែលកើតឡើងទាំងអស់នេះ ធ្វើឲ្យខ្ញុំឈឺចាប់ ប៉ុន្តែខ្ញុំបានចែករំលែកវាទៅដល់កូនៗ និងក្មេងៗដទៃទៀតឲ្យបានដឹងពីប្រវត្តិរបស់គ្រួសារខ្ញុំ និងសម័យដ៏ឃោរឃៅរបស់ខ្មែរក្រហម ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ពេលដែលខ្ញុំនិយាយដល់រឿងប្តីរបស់ខ្ញុំ កូនៗរបស់ខ្ញុំ តែងតែទទូចឲ្យខ្ញុំទៅយកធាតុឪពុកមកស្រុកកំណើតវិញ។ ខ្ញុំមិនអាចធ្វើទៅបានទេ ព្រោះនៅក្នុងរណ្តៅនោះមានសាកសពច្រើនណាស់ ហើយរណ្តៅនោះ មានជម្រៅជ្រៅថែមទៀត។ អ្វីដែលខ្ញុំនិងគ្រួសារអាចធ្វើបាន គឺការធ្វើបុណ្យឧទ្ទិសកុសលជូនគាត់តែប៉ុណ្ណោះ។

សព្វថ្ងៃ ខ្ញុំលើសជាតិស្ករ ប៉ុន្តែខ្ញុំតែងតែដើរហាត់ប្រាណជាប្រចាំ។ សុខភាពខ្ញុំមិនមានអ្វីគួរឲ្យបារម្ភទេ។ ចំណែកឯការរស់នៅវិញ កូនៗរបស់ខ្ញុំ គឺជាអ្នកជួយផ្គត់ផ្គង់ដល់ខ្ញុំ។



រណ្តៅសាកសពជនរងគ្រោះពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)















# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!












# ហោរទាយថា ប្អូនប្រុសខ្ញុំកំពុងរស់នៅឯនាយសមុទ្រ

**អ៊ុន សុជាទី**



វង្ស អោក (សូត្រ អ៊ិល/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រយៈពេលប្រហែល ៥០ឆ្នាំ ដែលខ្ញុំបានបែកពីប្អូនប្រុសទីពារបស់ខ្ញុំ។ ចាប់តាំងពីក្រុមកុម្មុយនីស្តខ្មែរក្រហមឡើងកាន់កាប់អំណាចនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ១៩៧៥ មក ខ្ញុំមិនធ្លាប់បានទទួលដំណឹងពីប្អូនប្រុស ខ្ញុំទេ។ ប្អូនប្រុស ខ្ញុំឈ្មោះ វង្ស អោក ប្រសិនបើគាត់នៅរស់រានមានជីវិតដល់សព្វថ្ងៃនេះ គាត់ប្រហែលជាមានអាយុ ៧២ឆ្នាំហើយ។ អោក គឺជាកូនទី ៣ ក្នុងចំណោមបងប្អូន ៥នាក់នៅក្នុងគ្រួសារ។ អោក មានសម្បុរស្រអែម ខ្ពស់ និងមានធ្មេញដំពើសចូលទៅខាងក្នុងក្រអូមមាត់។ កាលនៅរៀន អោក ចូលចិត្តលេងកីឡាបាល់ទាត់។ អោក មានអត្តចរិតកាចជាងគេក្នុងចំណោមបងប្អូនទាំងអស់។ គាត់មិនចូលចិត្តធ្វើស្រែចម្ការនោះទេ។ ចំណែកឯការសិក្សាវិញ អោក រៀនអក្សរបានជ្រៅជ្រះជាងខ្ញុំ។ គាត់ធ្លាប់រៀននៅវិទ្យាល័យរស្មីសោភណ្ឌ។

នៅអំឡុងឆ្នាំ១៩៦៩ អោក បានសុំអនុញ្ញាតឪពុកម្តាយខ្ញុំឈប់រៀន ហើយទៅរកការងារធ្វើនៅឯខេត្តសៀមរាបជាមួយនឹងមិត្តភក្តិរបស់គាត់។ បើតាមអ្នកភូមិស្គាល់គ្នាម្នាក់ ដែលបានវិលត្រឡប់មករស់នៅក្នុងភូមិវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ បាននិយាយប្រាប់ខ្ញុំថា គាត់ធ្លាប់ឃើញ អោក រស់នៅឯខេត្តសៀមរាបពិតប្រាកដមែន និងធ្វើជាប៉ូលីសទៀតផង។ ក្រោយមកគាត់មិនដែលឃើញ អោក ទៀតទេ តាំងតែពី អោក បានចាកចេញពីខេត្តសៀមរាបមុនពេលដែលខ្មែរក្រហមចូលមកជម្លៀសប្រជាជនចេញពីភូមិ។ ទាំងខ្ញុំនិងសមាជិកក្រុមគ្រួសារ ទាំងអស់មិនដែលបានជួប និងទទួលដំណឹងពី អោក ឡើយតាំងពីឆ្នាំ ១៩៧៤ មកម្ល៉េះ។ ខ្ញុំដឹងតាមរយៈម្តាយខ្ញុំថា អោក ធ្លាប់មានប្រពន្ធនៅឯខេត្តសៀមរាប ប៉ុន្តែគ្មានកូនទេ។ នៅពេលដែលរបបខ្មែរក្រហមបានដួលរលំ ឪពុករបស់ខ្ញុំ ត្រូវបានខ្មែរក្រហមសម្លាប់ ហើយក្រុមគ្រួសាររបស់ខ្ញុំបានត្រឡប់មកជួបជុំគ្នាវិញ ដោយអវត្តមានតែ អោក។ យើងទាំងអស់គ្នានឹករឭកដល់ អោក ណាស់។ យើងនៅតែមានមន្ទិលសង្ស័យពីការបាត់ខ្លួនរបស់ អោក។ ថ្ងៃមួយ ម្តាយនិងប្អូនស្រីរបស់ខ្ញុំ បានទៅរកហោរម្នាក់ឲ្យធ្វើការទស្សន៍ទាយអំពីដំណើរជីវិតរបស់ អោក។ គ្រូទាយនោះប្រាប់ថា អោក មិនទាន់ស្លាប់ទេ ហើយកំពុងតែរស់នៅឯនាយសមុទ្រឆ្ងាយពីប្រទេសកម្ពុជា។





ដោយសារតែអបិយជំនឿ ដែលហោរបានប្រាប់យ៉ាងដូច្នេះ បានធ្វើឲ្យខ្ញុំកាន់តែចង់ស្វែងរកប្អូនប្រុសរបស់ខ្ញុំកាន់តែខ្លាំងឡើងៗ។ ខ្ញុំសង្ឃឹមថា បងប្អូនរបស់ខ្ញុំ នឹងបានជួបគ្នានៅក្នុងវ័យចាស់ជរានេះម្តងទៀត។ ទោះបីជាយ៉ាងណានៅក្នុងចិត្តរបស់ខ្ញុំ ក៏បានគិតដែរថា ប្រសិនបើ អោក នៅមានជីវិតរស់ តើហេតុអ្វីបានជាគាត់មិនវិលត្រឡប់មករកក្រុមគ្រួសារវិញ?

ខ្ញុំឈ្មោះ សូត្រ អ៊ិល ភេទប្រុស អាយុ ៧៥ ឆ្នាំ រស់នៅក្នុងឃុំបន្ទាយស្ទោង ឃុំបន្ទាយស្ទោង ស្រុកស្ទោង ខេត្តកំពង់ធំ។ ខ្ញុំរៀបការនៅក្នុងសម័យសង្គមរាស្ត្រនិយម។ ប្រពន្ធរបស់ខ្ញុំឈ្មោះ រិន រ៉ៃ។ ខ្ញុំមានកូនស្រីចំនួន ៣នាក់។ រស់នៅទីនេះ ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ។ ខ្ញុំក៏មានតួនាទីជាមេឃុំបន្ទាយស្ទោង ចាប់តាំងពីរបបខ្មែរក្រហមបានដួលរលំរហូតដល់សព្វថ្ងៃនេះ។ ខ្ញុំរស់នៅក្នុងឃុំបន្ទាយស្ទោងនេះរហូតតាំងពីខ្ញុំកើតមកដល់សព្វថ្ងៃនេះដោយមិនធ្លាប់ជម្លៀសទៅរស់នៅទីណាឡើយ។

នៅអំឡុងឆ្នាំ ១៩៦៩ ប្អូនប្រុសរបស់ខ្ញុំឈ្មោះ អោក បានចាកចេញពីផ្ទះទៅរកការងារធ្វើនៅឯខេត្តសៀមរាប។ មិនយូរប៉ុន្មាន ឪពុកម្តាយនិងប្អូនរបស់ខ្ញុំចំនួន ៣នាក់ទៀត បានផ្លាស់ទីលំនៅទៅរស់នៅក្នុងខេត្តកំពង់ឆ្នាំង។ ការផ្លាស់ទីលំនៅនោះ ព្រោះឪពុកខ្ញុំចង់លាក់ប្រវត្តិរូបរបស់គាត់ដែលធ្លាប់ធ្វើជាមេឃុំក្នុងសម័យ លន់ នល់។ ក្រោយមក ខ្ញុំក៏បានដឹងដែរថា ឪពុកម្តាយនិងប្អូនៗរបស់ខ្ញុំបានទំនាក់ទំនងជាមួយនឹង អោក ហើយបានផ្លាស់ទៅរស់នៅឯខេត្តសៀមរាបជាមួយគ្នា។ មុនពេលដែលខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីក្រុងសៀមរាប អោក បានចាកចេញពីក្រុងសៀមរាបមុនគេ។ មិនយូរប៉ុន្មាន ម្តាយឪពុកនិងប្អូនៗទាំង៣នាក់ផ្សេងទៀត បានចាកចេញពីក្រុងសៀមរាបទៅរស់នៅក្បែរភ្នំគូលេន ឬហៅថា តំបន់ស្រែវាល ក្នុងស្រុកសូត្រនិគម។ អោក បានបែកចេញ និងបាត់ដំណឹងសូន្យឈឹងចាប់តាំងពីពេលនោះមក។ យើងទាំងអស់គ្នាក៏លែងទទួលបានដំណឹងអ្វីពីគាត់ទាំងអស់។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានស៊ើបដឹងពីប្រវត្តិរូបរបស់ឪពុកខ្ញុំ ហើយក៏បានយកឪពុកខ្ញុំទៅសម្លាប់ចោល។ នៅថ្ងៃដដែលនោះ ខ្មែរក្រហមបានមកនាំឪពុកនិងប្អូនថ្លៃរបស់ខ្ញុំទៅសម្លាប់ជាមួយគ្នា។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំ ប្រពន្ធ និងកូនស្រីច្បងរស់នៅឯភូមិបន្ទាយស្ទោង ឃុំបន្ទាយស្ទោង ស្រុកស្ទោង ខេត្តកំពង់ធំ។ នៅពេលដែលខ្មែរក្រហមចូលមកដល់ក្នុងភូមិរបស់ខ្ញុំដំបូង គឺខ្មែរក្រហមមានអាកប្បកិរិយាស្លូតបូត។ អ្នកទាំងនោះស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ និងមានបងក្រមានៅនឹងកគ្រប់ៗគ្នា។ ខ្មែរក្រហមបានប្រើវិធីសាស្ត្រមកបញ្ឆោះបញ្ឆោលប្រជាជនឲ្យគាំទ្របដិវត្តន៍ដោយចោទថា អ្នកដឹកនាំនៅក្នុងសង្គមចាស់សុទ្ធតែជាអ្នកក្បត់ជាតិ ពុករលួយ ជិះជាន់ធ្វើបាបប្រជារាស្ត្រនិងប្រើប្រាស់អំណាចផ្តាច់ការ។ នៅពេលនោះ ប្រជាជនម្នាក់ៗគ្មានជម្រើសទេ។ ប្រសិនបើ ប្រជាជនមិនគាំទ្រខ្មែរក្រហមទេ នោះខ្មែរក្រហមនឹងសម្លាប់ប្រជាជនទាំងអស់នោះវិញ។ ប្រជាពលរដ្ឋមួយចំនួនដែលធ្លាប់ជួបប្រទះនឹងភាពក្រខ្សត់ និងទទួលរងការជិះជាន់ ក៏នាំគ្នាគាំទ្រក្រុមខ្មែរក្រហមយ៉ាងខ្លាំង។ គ្មាននរណាហ៊ានប្រកែកតវ៉ាឡើយ។ ចូលដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមប្រមែប្រមូលទ្រព្យសម្បត្តិរបស់ប្រជាជនយកមកដាក់ជាសមូហភាព។ ប្រជាជនចាប់ផ្តើមប្រឈមនឹងភាពលំបាក។ នៅទីនេះ ខ្មែរក្រហម បានធ្វើបាប និងសម្លាប់មនុស្សជាច្រើននាក់។

ខ្ញុំគឺជាប្រជាជនត្រៀម។ ខ្ញុំត្រូវទៅធ្វើស្រែចម្ការ និងដឹកស្បៀងអាហារយកទៅដាក់នៅតាមការដ្ឋាននីមួយៗ



សូត្រ អ៊ិល (សូត្រ អ៊ិល/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅតាមសហករណ៍។ ប្រពន្ធរបស់ខ្ញុំធ្វើស្រែ រីឯកូនទៅរស់នៅក្នុងកុមារ។ ការរស់នៅពេលនោះ គឺលំបាកណាស់។ យើងត្រូវធ្វើការងារទាំងយប់ទាំងថ្ងៃ តាមបញ្ជារបស់អង្គការ ដោយមិនហ៊ាននិយាយស្តីប្រកែកតវ៉ាឡើយ។ ខ្ញុំព្យាយាមបត់បែនតាមសភាពការណ៍រហូត មិនហ៊ាននិយាយរីករាយ ឬកខុសរកត្រូវឡើយ។ កាលណាហូបមិនឆ្អែត ក៏មិនហ៊ានរអ៊ូដែរ ហើយបើហូបមិនឆ្ងាញ់ ក៏ត្រូវឆ្លើយថាហូបឆ្ងាញ់ដែរ។ នៅទីនោះ ខ្មែរក្រហមបានចាត់ប្រជាជនតាមប្រភេទ គឺមានប្រជាជនមូលដ្ឋាន ប្រជាជនត្រៀម និងប្រជាជនបញ្ញើ គឺជាប្រជាជនដែលជាប់និន្នាការនយោបាយ។ ខ្មែរក្រហម បានធ្វើបាបប្រជាជនបញ្ញើ ដោយឲ្យធ្វើការងារធ្ងន់ជាងប្រជាជនមូលដ្ឋាន ហើយភាគច្រើនប្រជាជនបញ្ញើត្រូវខ្មែរក្រហមយកទៅសម្លាប់។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំគ្មានពេល ឬឱកាសជួបជុំ ឬ សួរដំណឹងពីគ្នានោះទេ។



រូបខាងស្តាំ៖ វង្ស អោក និង មិត្តភក្តិរបស់គាត់។ (សូត្រ អ៊ុល/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កងទ័ព វៀតណាម វាយចូលមកប្រទេសកម្ពុជា នៅក្នុងឆ្នាំ ១៩៧៩ ។ កងទ័ពវៀតណាមបានប្រមូលផ្តុំប្រជាជនទៅដាក់នៅក្នុងវត្តបន្ទាយស្មោង។ ចំណែកខ្មែរក្រហមបានរត់បែកគ្នាអស់។ ខ្ញុំនិងក្រុមគ្រួសារក៏នាំគ្នារត់ដែរ ព្រោះយើងមិនទាន់ដឹងថា តើកងទ័ពវៀតណាមចូលមកក្នុងគោលបំណងអ្វីនោះទេ។ នៅពេលដែលកងទ័ពវៀតណាមរស់នៅក្នុងតំបន់ខ្ញុំបានយូរបន្តិច ទើបយើងហ៊ានសហការគ្នា។ កងទ័ពវៀតណាមមកផ្សព្វផ្សាយប្រជុំជាមួយប្រជាជន ដោយពេលនោះ មានខ្មែរយើងអមមកជាមួយ និងធ្វើការជាមួយកងទ័ពវៀតណាម។ ប្រជាជនមួយចំនួនរង់ចាំរាប់ខែ រហូតទាល់តែមានការជឿជាក់ទៅលើកងទ័ពវៀតណាម ទើបបានមកចូលរួមជាមួយ។

បន្ទាប់ពីខ្មែរក្រហមដួលរលំមក ខ្ញុំនិងក្រុមគ្រួសាររស់នៅក្នុងភូមិនេះដដែល។ ខ្ញុំត្រូវប្រជាជនគាំទ្រឲ្យធ្វើជាមេឃុំតាំងពីពេលនោះមក។ រដ្ឋអំណាចបានបែងចែកដីធ្លីទៅតាមសមាជិកគ្រួសារ។ ប្រជាជនទាំងអស់បានសហការគ្នាជាក្រុមធ្វើស្រែចម្ការប្រវាស់ដៃ និងជួយគ្នាទៅវិញទៅមក ព្រមទាំងជួយដល់អ្នកក្រខ្សត់ដែលខ្វះលទ្ធភាព។

នៅក្នុងឆ្នាំ ១៩៨៣ ខ្ញុំបានដាក់ញត្តិទៅកាន់អង្គការសហប្រជាជាតិ។ នេះដោយសារតែ ខ្ញុំមានការឈឺចាប់ចំពោះការបាត់បង់គ្រួសារ។ ក្នុងនាមខ្ញុំ ជារដ្ឋអំណាចឃុំម្នាក់ ដោយមើលឃើញពីភាពលំបាក និងទំហំនៃការបាត់បង់របស់ប្រជាជន ខ្ញុំក៏សម្រេចដាក់ញត្តិឲ្យអង្គការសហប្រជាជាតិឈប់គាំទ្រមេដឹកនាំខ្មែរក្រហមបន្តទៅទៀត។ ខ្ញុំធ្វើនេះក៏ជាគំរូមួយដល់ប្រជាជនឯទៀតឲ្យរួមសហការគ្នាក្នុងការផ្តួលរលំរបបខ្មែរក្រហមដែលនៅសេសសល់។

ក្រោយមក ខ្ញុំក៏បានដាក់ពាក្យបណ្តឹងទៅកាន់តុលាការខ្មែរក្រហមម្តងទៀត តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលចុះមកធ្វើការនៅក្នុងភូមិបន្ទាយស្មោង។ ការដាក់ពាក្យបណ្តឹងនេះគឺ ១) ដើម្បីស្វែងរកយុត្តិធម៌ ២) មានការបាត់បង់សមាជិកគ្រួសារ ៣) មើលឃើញពីអំពើដ៏សាហាវឃោរឃៅរបស់ក្រុមខ្មែរក្រហមដែលប្រព្រឹត្តមកលើប្រជាជនខ្មែរ។ ខ្ញុំធ្លាប់មកចូលរួមស្តាប់ការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរ។ ខ្ញុំយល់ឃើញថាការកាត់ទោសនេះ គឺត្រឹមត្រូវហើយ។ ច្បាប់របស់ប្រទេសយើងគ្មានការកាប់សម្លាប់នោះ ដូច្នេះ យើងត្រូវគោរពតាមច្បាប់របស់ប្រទេសយើង។

ក្រៅពីការចូលរួមនេះ ខ្ញុំក៏ធ្លាប់បានផ្សព្វផ្សាយពីប្រវត្តិសាស្ត្រខ្មែរក្រហមកន្លងមកតាមរយៈទស្សនាវដ្តីស្វែងរកការពិតដល់ប្រជាជន និងក្មេងៗជំនាន់ក្រោយ។ ខ្ញុំផ្សព្វផ្សាយប្រវត្តិសាស្ត្រខ្មែរក្រហមទៅដល់ប្រជាជននៅពេលមានការប្រជុំ ដោយខ្ញុំបានអាន និងជម្រាបជូនឲ្យប្រជាជនបានដឹង។

សព្វថ្ងៃនេះ ខ្ញុំមានជំងឺក្រពះ និងចុករោយដៃជើង។ ខ្ញុំមិនដែលបានទៅព្យាបាលនៅមន្ទីរពេទ្យទេ គឺខ្ញុំទិញថ្នាំយកមកលេប។ ខ្ញុំលេបថ្នាំខ្មែរខ្លះ ដើម្បីព្យាបាលជំងឺរបស់ខ្ញុំ។ ខ្ញុំចង់ឲ្យមានការពិនិត្យសុខភាពជូនជនរងគ្រោះ ហើយខ្ញុំពេញចិត្តគាំទ្រដល់ដំណើរការនេះ។





# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ជារ៉ាវដ្ឋ មេគ្គា

(តពីលេខមុន)



រូបទីមួយរាប់ពីស្តាំ៖ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ, អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស និង វ៉ន វ៉េត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចឈរគោរពភ្លេងជាតិនៅក្នុងមហាសន្និបាតរបស់បក្សកុម្មុយនីស្តកម្ពុជានៅស្តាតអូឡាំពិក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយអ្នកផ្តល់ចម្លើយដទៃទៀត។

**២.៥.៦.៧.៣.** ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍ក្នុងកម្ពុជានៅលើទឹកដីវៀត ណាម

**១៤៩.** អនុលោមតាមដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ មេធាវីការពារក្តី ខៀវ សំផនបានលើកឡើងថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដី វៀតណាម មិនស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ឡើយ។ ហេតុដូច្នេះ ភស្តុតាងណាមួយនៃអំពើឧក្រិដ្ឋកម្មនេះ ដែលបានលើកឡើងក្នុងសវនាការ ដូចជា សក្ខីកម្មរបស់ Stephen Morris នៅលើចំណុចនេះត្រូវតែដកចេញពីការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះ។

១៩០. អង្គជំនុំជម្រះរំឭកថា យោងតាមសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម ក្នុងសំណុំរឿង ០០២ របស់អង្គជំនុំជម្រះ អង្គហេតុទាំងអស់នេះមានបែងចែកនៅក្នុងកថាខណ្ឌ ៨៣២-៨៤០ នៃដីកាដំណោះស្រាយមិនមាននៅក្នុងសំណុំរឿង ០០២/០២ នេះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចដាក់ឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌដល់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មដោយផ្អែកលើអង្គហេតុទាំងអស់ឡើយ។ ភ័ស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងផ្អែកលើអង្គហេតុទាំអស់នេះឡើយ។ ភ័ស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង ដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីនៃប្រទេសវៀតណាម រួមទាំងផ្នែកខ្លះនៃសកម្មភាពរបស់ Stephen MoRRIS ទាក់ទងនឹងការលុកលុយនៅក្នុងទឹកដីនៃប្រទេសវៀតណាម អង្គជំនុំជម្រះនឹងមិនយកមកពិចារណាឡើយ នៅពេលវាយតម្លៃទៅលើបទចោទនៅក្នុងសំណុំរឿងនេះ។ អង្គហេតុទាំងនេះអាចត្រូវបានពិចារណាដោយអង្គជំនុំជម្រះចំពោះគោលបំណងដទៃទៀត រួមទាំង ការវាយតម្លៃលើភាពអាចជឿជាក់បានរបស់សាក្សី ការយល់ដឹងអំពីបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ឬបទចោទនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទាក់ទងនឹងប្រជាជនស៊ីវិល ឬទាហាន ដែលបាត់បង់ សមត្ថភាពប្រយុទ្ធ ដែលត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលប៉ះទង្គិចខាងអាវុធ នៅលើប្រទេសវៀតណាម ហើយដែលត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខស-២១ នៅពេលក្រោយមក។

## ៣. បរិបទប្រវត្តិសាស្ត្រ

១៩១. ព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាំបាច់ត្រូវតែពិនិត្យដោយគិតទៅលើបរិបទនៃការអភិវឌ្ឍ ដែលកើតមានឡើងមុនពេលនៃការបង្កើតរបបនេះ។ នៅក្នុងផ្នែកនេះ អង្គជំនុំជម្រះបង្ហាញពីបរិបទប្រវត្តិសាស្ត្រនៃព្រឹត្តិការណ៍ផ្សេងៗ ទៀតដែលកើតមាននៅ ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

### ៣.១ ការបង្កើតបក្សកុម្មុយនីសកម្ពុជា

១៩២. នៅក្នុងការកំណត់ពីការបង្កើត ប.ក.ក. អង្គជំនុំជម្រះបានពឹងផ្អែកជាចម្បងលើសក្ខីកម្ម និងឯកសារបោះពុម្ពផ្សាយផ្សេងៗរបស់ជនជាប់ចោទ និងអ្នកជំនាញដែលបានរួមគ្នាបង្ហាញពីការវាយតម្លៃលម្អិតទៅលើអំឡុងពេលមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

១៩៣. ជាពិសេស អង្គជំនុំជម្រះបានយោងយ៉ាងច្រើនទៅលើសំណេរនិងសក្ខីកម្មរបស់ នួន ជា អំពីប្រវត្តិរបស់ ប.ក.ក ដែលអង្គជំនុំជម្រះយល់ឃើញថា មានភាពស៊ីចង្វាក់គ្នាច្រើន ទាំងសក្ខីកម្មរបស់គាត់នៅក្នុងសវនាការ និងភ័ស្តុតាងផ្សេងទៀតក្នុងសំណុំរឿង។ ហេតុដូច្នេះប្រភពទាំងនេះ គឺជាមូលដ្ឋានដែលអាចឲ្យជឿជាក់បានសម្រាប់គាំទ្រដល់សំអាងហេតុ។ លើសពីនេះទៀត អង្គជំនុំជម្រះបានពឹងផ្អែកទៅលើកិច្ចសម្ភាសន៍រវាង នួន ជា និង ខែម ងុន។ ទោះបីជា នួន ជា ព្យាយាមបន្ទុចកិត្តិយសអ្នកសម្ភាសន៍ នៅពេលដែលគាត់ត្រូវបានគេសួរនៅក្នុងតុលាការក្តី អង្គជំនុំជម្រះយល់ឃើញថា ចម្លើយរបស់គាត់នៅក្នុងកិច្ចសម្ភាសន៍នេះ ស៊ីចង្វាក់គ្នាជាមួយនឹងចម្លើយផ្សេងៗទៀត របស់គាត់រួមទាំងចម្លើយនៅក្នុងតុលាការផងដែរ។ ជាក់ស្តែង នួន ជា បានទទួលស្គាល់ថា «ភាគច្រើន» គាត់បានប្រាប់ការពិតដល់ ខែម ងុន នៅក្នុងកិច្ចសម្ភាសន៍នេះ ដោយលើកឡើងត្រឹមថា គាត់អាចលាក់ទុកព័ត៌មានខ្លះមិនប្រាប់ ខែម ងុន ឡើយ។ ដោយហេតុថា បញ្ហានៅទីនេះ គឺត្រង់ខ្លឹមសារពិតប្រាកដនៃកិច្ចសម្ភាសន៍ មិនមែនភាពគួរទុកចិត្តបាននៃកំណត់ហេតុនៃកិច្ចសម្ភាសន៍នេះ គឺជាមូលដ្ឋានមួយដែលអាចទុកចិត្តបានសម្រាប់ធ្វើជាសំអាងហេតុ។

១៩៤. អង្គជំនុំជម្រះយល់ឃើញថាសក្ខីកម្មរបស់ ខៀវ សំផន មានអត្ថប្រយោជន៍សម្រាប់ព្រឹត្តិការណ៍ដែលបានកើតឡើងនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ហើយអង្គជំនុំជម្រះបានពឹងផ្អែក ទៅលើសក្ខីកម្មទាំងនេះដោយមានការប្រុងប្រយ័ត្ន និងពិនិត្យទៅលើភ័ស្តុតាងគាំទ្រផ្សេងៗផងដែរ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះបានពឹងផ្អែកទៅលើឯកសារបោះពុម្ពផ្សាយរបស់គាត់ដែលមានចំណងជើងថា ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើម រហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យនៅក្នុងកម្រិតកំណត់មួយប៉ុណ្ណោះ ដោយកត់សម្គាល់អំពីការយោងយ៉ាងច្រើននៅក្នុងឯកសារនេះ ទៅលើការស្រាវជ្រាវរបស់ Philip SHORT និងអ្នកនិពន្ធផ្សេងទៀត។ អង្គជំនុំជម្រះបានយោងទៅលើឯកសារនេះតែត្រង់ចំណុចដែលឯកសារនេះផ្តល់ព័ត៌មានអំពីប្រវត្តិសាស្ត្រដែលមិនធ្លាប់ត្រូវបានទទួលស្គាល់ពីមុន និងជាព័ត៌មានប្រវត្តិសាស្ត្រពិសេសរបស់ជនជាប់ចោទ ឬ ជាព័ត៌មានដែលគាំទ្រដល់ព័ត៌មាន ដែលអាចជឿជាក់បានដទៃទៀតដែលមាននៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះ។

១៩៥. ក្នុងការពិនិត្យលើភាពអាចជឿជាក់បានរួមនៃព័ត៌មានប្រវត្តិសាស្ត្រទាំងនេះ អង្គជំនុំជម្រះបានស្វែងរកការបញ្ជាក់ពីឯកសារនាសម័យនោះ និងភ័ស្តុតាងដទៃទៀតដែលមាននៅចំពោះមុខអង្គជំនុំជម្រះដោយផ្តល់ទម្ងន់ខ្លាំងទៅលើសក្ខីកម្មដែលបានស្តាប់នៅក្នុងតុលាការ និងឯកសារដែលអ្នកពាក់ព័ន្ធ ឬ អ្នកនិពន្ធដែលភាគីនានាអាចសួរដេញដោលបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះបាន ពឹងផ្អែកជាពិសេសទៅលើឯកសារ និងសក្ខីកម្មរបស់អ្នកជំនាញ Elizabeth BECKER (ដែលជាអ្នកឆ្លើយឆ្លងព័ត៌មានអំពីសង្គ្រាមនៅកម្ពុជា នៅដើមទសវត្សរ៍ ១៩៧០ និងអាចផ្តល់រឿងរ៉ាវដែលគាត់បានឃើញជាក់ស្តែង បន្ទាប់ពីគាត់បានធ្វើដំណើរទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ ១៩៧៨) និង Philip SHORT និង David CHANDLER។ ដោយអនុវត្តស្របច្បាប់តាមវិធីសាស្ត្ររបស់ខ្លួនក្នុងការវាយតម្លៃជារួមលើភ័ស្តុតាង អង្គជំនុំជម្រះបានធ្វើការពិចារណាបន្ថែមលើការរៀបរាប់ទូទៅភាពលម្អៀង កំហុសក្នុងការចងចាំ និងមូលហេតុជំនាញនៅពេលត្រូតពិនិត្យវាយតម្លៃទៅលើភាពត្រឹមត្រូវនៃភ័ស្តុតាងប្រវត្តិសាស្ត្រទាំងអស់។

#### ៣.១.១ ឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៧០៖ ការចាប់កំណើតនៃការតស៊ូប្រដាប់អាវុធ

១៩៦. ចលនាកុម្មុយនីស្តកម្ពុជាបានចាប់កំណើតពីការ



កងទ័ពបដិវត្តន៍ និងកម្មាភិបាលខ្មែរក្រហមចូលរួមមហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជា នៅស្តាតអូឡាំពិក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



រូបមូរដើងខោះ នួន ជា ប្រធានសភាជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យចុះពិនិត្យការដ្ឋានការងារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បង្កើតបក្សកុម្មុយនីស្តវៀតណាម នៅក្នុងខែមករា ឆ្នាំ ១៩៣០ ដោយ ហូ ជីមិញ។ បក្សត្រូវបានប្តូរឈ្មោះទៅ ជាបក្សកុម្មុយនីស្តឥណ្ឌូចិន។ នៅចុងឆ្នាំនេះ តាមការ ណែនាំរបស់បក្សកុម្មុយនីស្តអន្តរជាតិ ដើម្បីឆ្លុះបញ្ចាំងពី គោលដៅរបស់ចលនានេះ ក្នុងការលើកកម្ពស់អន្តរជាតិ និយមនៃវណ្ណៈអធន នៅក្នុងដែនដីឥណ្ឌូចិនសំខាន់ៗ ដែល មានប្រទេសវៀតណាម កម្ពុជា ឡាវ បច្ចុប្បន្ននេះ។ ទោះបីជាបក្សនេះមានឈ្មោះបែបនេះក្តី តែបក្សកុម្មុយ នីស្តឥណ្ឌូចិន កាលពីដំបូងមិនមានសមាជិកកម្ពុជា បុ ឡាវនោះឡើយ ហើយបក្សនេះ នៅតែមិនមានសកម្មភាព នៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ។

**១៩៧.** នៅក្នុងឆ្នាំ ១៩៤១ ក្រុមប្រឹក្សានាយកនៃបក្ស កុម្មុយនីស្តឥណ្ឌូចិន ដែលមានមូលដ្ឋាននៅក្នុងក្រុង ហាណូយ បានបង្កើតក្រុមវៀតមិញ ដែលជារណសិរ្សជាតិ និយមប្រឆាំងនឹងចក្រពត្តិនិយម។ នៅពេលបង្កើត មូលដ្ឋាននៅប្រទេសកម្ពុជា ក្រុមវៀតមិញបានជ្រើសរើស ជនជាតិខ្មែរជាបន្តបន្ទាប់ ក្នុងគោលបំណងដើម្បីបង្កប់ ខ្លួនចូលក្នុងបណ្តាញខ្មែរឥស្សរៈ ដែលគ្មានសណ្ឋាន ច្បាស់លាស់ជា ចលនាតស៊ូវាយប្រយុទ្ធប្រឆាំងនឹង អាជ្ញាធរអាណានិគមនិយមបារាំង។ ក្រុមឥស្សរៈដែល រួមមានទាំងផ្នែកកុម្មុយនីស្ត និងផ្នែកមិនមែនកុម្មុយនីស្ត បានចូលរួមក្នុងការតស៊ូប្រដាប់ដោយអាវុធប្រឆាំងនឹង បារាំងនៅប្រទេសកម្ពុជា ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៤០ ដែលក្នុងចំណោមនោះរួមមាន កែ ពក, សោ ភឹម, មូល សំបាត់ហៅ ញឹមរស់, ឈិតជឿនហៅ តាម៉ុក, ណៃ សារ៉ាន់ ហៅ យ៉ា, អាចារ្យ សុខ ហៅ ទូសាមុត និង ស៊ីវ ហេង។ ក្នុងខែមេសា ឆ្នាំ១៩៥០ វៀតមិញ និងខ្មែរឥស្សរៈ បាន រៀបចំពួកគេទៅជារណសិរ្សរួបរួមជា ឥស្សរៈ ដែលមាន រចនាសម្ព័ន្ធមិនច្បាស់លាស់នៅ «សមាជជាតិលើកទីមួយ របស់អ្នកតស៊ូខ្មែរ» ដែលក្រុមវៀតមិញ មានសមាជិក វៀតណាមភាគច្រើននោះ បានគ្រប់គ្រងលើរណសិរ្ស នោះ។ ដោយបានជ្រួតជ្រាបអំពីចលនាខ្មែរឥស្សរៈបក្ស កុម្មុយនីស្តឥណ្ឌូចិនដែលនៅពេលនោះរួមមាន ជូ ជេត ហៅ ស៊ី និងកែវមាស ព្រមទាំងអតីតសមាជិកបក្សកុម្មុយ នីស្តថៃ ដែល នួន ជា បានបង្កើតចលនាមួយនៅកម្ពុជា ដោយជោគជ័យ ក្រោមទម្រង់ជារណសិរ្សតស៊ូរំដោះជាតិ ខ្មែរឥស្សរៈ, បក្សកុម្មុយនីស្តកម្ពុជាឥណ្ឌូចិនដែលដឹក នាំដោយសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិនរួមមាន ចាន់ សម័យ, ស៊ីវ ហេង និង ទូ សាមុត។ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៥០ សឺង ង៉ុកមិញ បានប្រកាសជាផ្លូវ ការអំពីឯករាជ្យភាពរបស់ប្រទេសកម្ពុជា ក្នុងនាម ជា គណៈកម្មាធិការមជ្ឈិមរំដោះប្រជាជន ដោយអះ អាងថា រណសិរ្សរួបរួមឥស្សរៈនេះបានគ្រប់គ្រងប្រទេស មួយភាគបី។

**១៩៨.** បក្សកុម្មុយនីស្តបានរៀបចំខ្លួនឡើងវិញ នៅក្នុង សមាជនាឆ្នាំ ១៩៥១ ដោយមានការចូលរួមពី នួន ជា ដោយបានបង្កើតចលនាជាតិរបស់ខ្លួនទៅជាបក្សកុម្មុយ នីស្តដើមដំបូង ដោយចេតនារបស់កម្ពុជាត្រូវបានផ្លាស់ ឈ្មោះទៅជាបក្សប្រជាជនបដិវត្តន៍ខ្មែរ។ ទោះជាយ៉ាង នេះក្តី បក្សប្រជាជនបដិវត្តន៍ខ្មែរសម្ងាត់នេះ នៅតែជា ការចម្លងតាមបក្សកុម្មុយនីស្តកម្ពុជាឥណ្ឌូចិន ដោយ លក្ខន្តិកបក្ស ត្រូវបានសរសេរជាភាសាវៀតណាម ហើយរចនាសម្ព័ន្ធថ្នាក់ដឹកនាំរបស់រណសិរ្សរួបរួម ឥស្សរៈ សឺង ង៉ុកមិញ, ទូ សាមុត និង ស៊ីវ ហេង ត្រូវបាន រក្សាទុកដដែល។ នៅពេលក្រោយមក នួន ជា បាន អះអាងថា ដោយសារតែប្រភពកំណើតជាកម្ពុជា ក្រោមរបស់មេដឹកនាំ ទើបធ្វើឲ្យបក្សប្រជាជនបដិវត្តន៍ ខ្មែរមិនអាចឯករាជ្យភាពពីប្រទេសវៀតណាម។ បក្សប្រជាជនបដិវត្តន៍ខ្មែរក៏បានរក្សាការប្រឆាំងផ្នែក មនោគមន៍វិជ្ជាជាមួយនឹងគូប្រជែងនយោបាយ ដូចជា គណបក្សប្រជាធិបតេយ្យ និងសម្តេច នរោត្តម សីហនុ ដោយចាត់ទុកពួកគេទាំងនោះថាជា «អាយ៉ងរបស់ បរទេស»។

**១៩៩.** នៅក្នុងឆ្នាំ១៩៥២ សម្តេច នរោត្តម សីហនុបាន ធ្វើ «ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ» បន្ទាប់ពីព្រះ អង្គបានបណ្តេញគណបក្សប្រជាធិបតេយ្យចេញពី រដ្ឋាភិបាល ហើយព្រះអង្គបានចាប់ផ្តើមធ្វើដំណើរ ទស្សនកិច្ចនៅលើពិភពលោកជាសាធារណៈទាមទារ ឲ្យប្រគល់អំណាចរបស់អាណានិគមបារាំងមករាជា ធិបតេយ្យវិញ។ នៅចុងឆ្នាំ១៩៥៣ កិច្ចផ្តួចផ្តើមនេះ ទទួលបានជោគជ័យ ហើយបារាំងបានប្រគល់អំណាច យោធា និងតុលាការឲ្យមកសម្តេច សីហនុ។ កម្ពុជាទទួល បានអធិបតេយ្យភាព និងស្វ័យភាពឡើងវិញ បន្ទាប់ពី មានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ នៅក្នុងខែឧសភា ឆ្នាំ១៩៥៤ ជាកិច្ចព្រមព្រៀងដែលបានបញ្ចប់ការ បះបោរប្រឆាំងនឹងបារាំងនៅក្នុងឥណ្ឌូចិន ហើយជំរុញឲ្យ មានការបោះឆ្នោតដោយសេរីនៅក្នុងប្រទេសកម្ពុជា។ ខុសពីប្រទេសវៀតណាម និងប្រទេសឡាវ ពួកកុម្មុយនីស្ត កម្ពុជាមិនត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងការចរចា នៅទីក្រុងហ្សឺណែវឡើយ។ ក្រុមឥស្សរៈត្រូវបានឲ្យធ្វើ សមាហរណកម្មចូលនៅក្នុងសមាគមជាតិតាមលក្ខខណ្ឌ នៃកិច្ចព្រមព្រៀង ចំណែកកងកម្លាំងបរទេស ត្រូវបាន តម្រូវឲ្យដកចេញពីទឹកដីកម្ពុជា។ ជាលទ្ធផល ក្រុម ឥស្សរៈបានគាំទ្រសម្តេច នរោត្តម សីហនុ ហើយកម្លាំង មួយចំនួនរបស់ពួកកុម្មុយនីស្ត ដែលមានមូលដ្ឋាននៅ ក្នុងប្រទេសកម្ពុជា និងពួកវៀតមិញ បានដកថយចូល ទៅក្នុងទឹកដីវៀតណាម រួមជាមួយ សឺង ង៉ុកមិញ និង ស៊ីវ ហេង ដែលស្ទើរតែធ្វើឲ្យបក្សប្រជាជនបដិវត្តន៍ខ្មែររលាយ។ ទោះបីជានៅពេលក្រោយមក ខៀវ សំផន បានអះអាង ថា បក្សបាន «រលាយទាំងស្រុង» នៅពេលនោះក៏ដោយ ប៉ុន្តែផ្អែកលើព័ត៌មានខាងក្រោមនេះ មានភាពច្បាស់ លាស់ណាស់ថា សមាសភាពរបស់គណបក្សប្រជាជន បដិវត្តន៍ខ្មែរ រួមទាំងសមាជិក និង រចនាសម្ព័ន្ធរបស់គណ-បក្សនេះនៅតែមានបន្តនៅក្រោយឆ្នាំ ១៩៥៤។

**២០០.** នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥៥ សម្តេច នរោត្តម សីហនុ បានដាក់រាជសម្បត្តិ ហើយចាប់ផ្តើម ការបោះ ឆ្នោតជាសកល អនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ ដោយឈរឈ្មោះសម្រាប់តំណែង ជាប្រមុខរដ្ឋាភិបាល ជាបេក្ខជនរបស់គណបក្សថ្មីរបស់ ព្រះអង្គ គឺគណបក្សសង្គមរាស្ត្រនិយម។ នៅក្នុងពេល នេះដែរ គណបក្សប្រជាជនបដិវត្តន៍ខ្មែរបានបង្កើតក្រុម ប្រជាជនដើម្បីក្លាយជាកម្លាំងចលកររបស់បក្ស ក្នុង

ការចូលរួមផ្នែកនយោបាយ ហើយនឹងដើរតួនាទីជាតួអង្គសាធារណៈសម្រាប់ចលនាបដិវត្តន៍សម្ងាត់ៗ ក្រុមប្រជាជនដើម្បីក្លាយជាកម្លាំងចលកររបស់បក្ស ក្នុងការចូលរួមផ្នែកនយោបាយ ហើយនឹងដើរតួនាទីជាតួអង្គសាធារណៈសម្រាប់ចលនាបដិវត្តន៍សម្ងាត់ៗ ក្រុមប្រជាជនក្រោមការដឹកនាំរបស់ កែវ មាស ហើយដំណើរការដោយសាធារណៈដោយ សោ ភឹម, នៃ សារ៉ាន់ និង ជូ ជេត រួមជាមួយបុគ្គលផ្សេងមួយចំនួនទៀតៗ បន្ទាប់ពីយុទ្ធនាការឃោសនាបោះឆ្នោតដែលមានការបង្ក្រាបដោយកងកម្លាំងនគរបាល និងយោធាទៅលើបក្សប្រឆាំងរួចមក គណបក្សសង្គមរាស្ត្រនិយមបានយកជ័យជម្នះលើក្រុមប្រជាជនៗ រដ្ឋាភិបាលថ្មីបានអនុវត្តគោលនយោបាយការបរទេស ដែលមានអព្យាក្រឹតភាព និងមិនចូលបក្សសម្ព័ន្ធជាមួយអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ ដែលគ្រប់គ្រងដោយសហរដ្ឋអាមេរិក បន្ទាប់ពីបោះឆ្នោត នោះរួចមកៗ

**២០១.** នៅចុងឆ្នាំ១៩៥៥ គណបក្សប្រជាជនបដិវត្តន៍ខ្មែរបានរៀបចំឡើងវិញ ក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិមដែលមានសមាជិកប្រាំរូបគឺ ស៊ីវ ហេង ជាលេខា (នៅទីក្រុងសៃហ្គន នាពេលនោះ) ទូ សាមុត ជាលេខាធិការរង សឺង ង៉ុកមិញ (នៅទីក្រុងហាណូយ នាពេលនោះ) សោ ភឹម និង រស់ ញឹមៗ អនុលេខាធិការ ទូ សាមុត ដែលជាសមាជិកតែម្នាក់គត់នៃថ្នាក់ដឹកនាំបក្សប្រជាជនបដិវត្តន៍ខ្មែរ ដើមដំបូងដែលបន្តស្នាក់នៅទីក្រុងភ្នំពេញ ទទួលបានការជួយគាំទ្រនៅក្នុងគណៈកម្មាធិការបក្សប្រចាំទីក្រុងដោយ នួន ជា និង សាឡុត ស ហៅ ប៉ុល ពត ។ ប៉ុល ពត ត្រូវបាន ទូ សាមុត ចាប់អារម្មណ៍យ៉ាងខ្លាំង បន្ទាប់ពីគាត់ត្រឡប់មកពីទីក្រុងប៉ារីស និងការធ្វើការជាមួយគ្នាក្នុងរយៈពេលខ្លីមួយនៅព្រៃម៉ាគីជាមួយនឹងវៀតមិញៗ បើទោះបីជាសកម្មភាពរបស់បក្សហាក់ ដូចជា ស្ងប់ស្ងាត់នៅបណ្តាលឆ្នាំបន្ទាប់ៗមកទៀតក្តី ក៏ក្រុមប្រជាជនបានចូលរួមប្រកួតប្រជែង ប៉ុន្តែបានចាញ់ការបោះឆ្នោតនៅឆ្នាំ១៩៥៨ៗ ទោះបីជាចាញ់ការបោះឆ្នោតក្តី ប៉ុន្តែក្រុមប្រជាជននៅតែជាជម្រើសនយោបាយតែមួយគត់ ក្រៅពីសង្គមរាស្ត្រនិយមនៅក្នុងឆាកនយោបាយកម្ពុជា បន្ទាប់ពីការរំលាយបក្សប្រជាធិបតេយ្យកាលពីមួយឆ្នាំមុនៗ នៅក្នុងអំឡុងពេលនោះ សម្តេច នរោត្តម សីហនុ បានបង្កើតពាក្យ «ខ្មែរក្រហម» ដែលសំដៅទៅរកក្រុមប្រជាជនជាឈ្មោះមួយ ដែលសមាជិកចលនាកុម្មុយនីស្តមិនដែលធ្លាប់ប្រើទាល់តែសោះ ក្នុងការរៀបរាប់ពីខ្លួនៗ

**២០២.** នៅចុងឆ្នាំ ១៩៥៩ ថ្នាក់ដឹកនាំសម្ងាត់របស់បក្សនៅទីក្រុងភ្នំពេញ បានចាប់ផ្តើមដំណើរការបង្កើតគណបក្សម៉ាក្សលេនីននិយមពិតប្រាកដមួយដែលមិនទទួលរងឥទ្ធិពលពីវៀតណាមៗ ប៉ុល ពត និង នួន ជា បានរៀបចំសេចក្តីព្រាងលក្ខន្តិកបក្ស និងមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធី តាមបញ្ជារបស់ ទូ សាមុត ដែលបានក្លាយជាមេដឹកនាំបក្ស បន្ទាប់ពី ស៊ីវ ហេង បានផ្តាច់ខ្លួនចុះចូលជាមួយសម្តេច នរោត្តម សីហនុ ឬ ក៏អាចតាមការផ្តួចផ្តើមគំនិតរបស់ពួកគេផ្ទាល់ៗ បើតាម នួន ជា មាគ៌ាយុទ្ធសាស្ត្រ គឺផ្អែកលើការវិភាគសង្គមទៅលើសង្គមកម្ពុជា ដែលត្រូវបានចាត់ទុកជា អាណានិគមថ្មី និងពាក់កណ្តាលសក្តិភូមិនិយមៗ កិច្ចការដំបូងដែលត្រូវធ្វើគឺដើម្បីសម្រេចឲ្យបានបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដើម្បីលុបបំបាត់សក្តិភូមិនិយម ពួកប្រតិកិរិយាម្ចាស់ដី ចក្រពត្តិនិយម និងបរិវាររបស់ពួកវា ដើម្បីរំដោះកម្មករ កសិកររបស់ប្រទេសជាតិៗ ទាល់តែសម្រេចចំណុចនេះបាន ទើបអាចឈានទៅដល់បដិវត្តន៍សង្គមនិយមៗ

**២០៣.** ចាប់ពីថ្ងៃទី ៣០ ខែកញ្ញា ដល់ថ្ងៃទី ០២ តុលា ឆ្នាំ ១៩៦០ សន្និបាតបក្សលើកទីមួយត្រូវបានធ្វើឡើងជាសម្ងាត់នៅទីក្រុងភ្នំពេញ ដោយក្នុងសន្និបាតនោះមានការអនុម័តលក្ខន្តិក និងជ្រើសរើសតាំងគណៈកម្មាធិការដឹកនាំមួយៗ ទូ សាមុត ត្រូវបានជ្រើសរើសតាំងជាលេខាបក្ស ហើយ នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាៗ ពួកគេទាំងពីររូបក៏ត្រូវបានតែងតាំងជាសមាជិកពេញសិទ្ធិនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ រួមជាមួយនឹង ប៉ុល ពត ផងដែរ ចំណែក អៀង សារី ជាសមាជិកបម្រុងៗ សុន សេន, សោ ភឹម និង តាម៉ុក ក៏បានចូលក្នុងសន្និបាតនោះដែរ ហើយ សុន សេន និង សោ ភឹម ត្រូវបានចាត់តាំងដោយសមាជិកបម្រុងនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរៗ កែវ មាស, វ៉ន វ៉េត, ម៉ា ម៉ង់ និង ប្រសិទ្ធិ ហៅ ចុង ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការមជ្ឈិមនៃគណបក្សប្រជាជនបដិវត្តន៍ខ្មែរជាមួយនឹង សឺង ង៉ុកមិញ (ដែលអវត្តមាន) បន្ថែមពីលើ ទូ សាមុត, នួន ជា, ប៉ុល ពត, អៀង សារី, និង សុន សេនៗ មហាសន្និបាតបង្កើតនិមិត្តរូបនៃការចូលរួបរួមគ្នា នៅក្រោមឋានានុក្រមនៃចលនាបដិវត្តន៍របស់អតីតសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន និងឥស្សរជាមួយនឹង «និស្សិតដែលត្រឡប់មកវិញ» ឬ«បញ្ញវន្ត» រួមមាន ប៉ុល ពត , អៀង សារី និង សុន សេន ដែលត្រូវបានគេស្គាល់ថា ចាប់តាំងពីទសវត្សរ៍ ១៩៥០ តាមរយៈការចូលរួមរបស់ពួកគេ នៅក្នុងក្រុមម៉ាក្សនិយមនៅទីក្រុងប៉ារីសៗ

**២០៤.** មហាសន្និបាតបានអនុម័តមាគ៌ាយុទ្ធសាស្ត្រពីឯករាជ្យភាព អធិបតេយ្យភាព និងខ្លួនទីពឹងខ្លួន ហើយបានសម្រេចបន្តការតស៊ូប្រដាប់អាវុធ និងនយោបាយដើម្បីសម្រេចបានគោលដៅបដិវត្តន៍បក្សៗ ក្នុងការព្យាយាមដើម្បីបញ្ជាក់ពីឯករាជ្យភាពរបស់ខ្លួន និងការចេញពីកុម្មុយនីស្តវៀតណាម គណបក្សប្រជាជនបដិវត្តន៍ខ្មែរ បានប្តូរឈ្មោះទៅជាបក្សពលករកម្ពុជា ដែលការសម្រេចនេះត្រូវបានធ្វើឡើងដោយមិនបានពិភាក្សាជាមួយបក្សកុម្មុយនីស្តវៀតណាមឡើយៗ ព្រឹត្តិការណ៍ជានិមិត្តរូបនេះ នៅពេលក្រោយមកជាមួយបក្សកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជាៗ បន្ទាប់ពីមហាសន្និបាត នោះមក កម្មាភិបាលបក្សពលករកម្ពុជាបានត្រឡប់ទៅខេត្ត និងភូមិភាគរបស់ពួកគេវៀងខ្លួនក្នុងកិច្ចខិតខំ ដើម្បីពង្រឹងមូលដ្ឋាននៅតាមជនបទរបស់បក្សដោយ ម៉ា ម៉ង់ និងប្រសិទ្ធិ បានត្រឡប់ទៅភូមិភាគនិរតី, រស់ ញឹម ត្រូវបានបញ្ជូនទៅពង្រឹងបណ្តាញអតីតឥស្សរនៅបាត់ដំបង ចំណែកឯ សោ ភឹម ត្រឡប់ទៅភូមិភាគបូព៌ាៗ

**២០៥.** នៅក្នុងឆ្នាំ ១៩៦០ កងកម្លាំងរបស់សម្តេច នរោត្តម សីហនុ បានចូលរួមក្នុងការបង្ក្រាបទៅលើពួកកុម្មុយនីស្តវៀតណាម ដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា ដោយទម្លាក់កំហុសទៅលើពួកគេថា បានធ្វើការវាយប្រហារដោយគ្រាប់បែកដាក់ក្នុងកញ្ចប់ទៅលើព្រះបរមរាជវាំង នៅក្នុងខែសីហា ឆ្នាំ១៩៥៩ ហើយបានលាបពណ៌ពួកគេថាជា «គ្រោះថ្នាក់ផ្នែកសីលធម៌ជានិរន្តរ៍ សម្រាប់ជាតិខ្មែរ»ៗ ការកៀបសង្កត់



មហាសន្និបាតរបស់បក្សកុម្មុយនីស្តកម្ពុជានៅស្តាតអូឡាំពិកៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាបន្តបន្ទាប់ទៅលើក្រុមឆ្វេងនិយមនៅកម្ពុជា បានបណ្តោយឲ្យបាត់ក្រុមប្រជាជននៅពេលបោះឆ្នោតឆ្នាំ១៩៦២។ ទោះជាយ៉ាងនេះក្តី សម្តេច នរោត្តម សីហនុ បានព្យាយាមពង្រឹកមូលដ្ឋាននយោបាយរបស់ព្រះអង្គ ហើយបានតែងតាំងបញ្ញវន្តឆ្វេងនិយម ហ៊ូ នឹម, ហ៊ូ យន់ និង ខៀវ សំផន នៅក្នុងរដ្ឋាភិបាលសង្គមរាស្ត្រនិយម។

**២០៦.** ការចាប់ខ្លួន និងការបាត់ខ្លួន ទូ សាមុត នាពេលបន្ទាប់មក នៅក្នុងឆ្នាំ ១៩៦២ តម្រូវឲ្យមានការតែងតាំងលេខាថ្មីរបស់បក្សពលករកម្ពុជា នៅក្នុងមហាសន្និបាតបក្សលើកទីពីរ ដែលបានធ្វើឡើង នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ នៅទីក្រុងភ្នំពេញ។ ប៉ុល ពត បានឡើងតួនាទីជាលេខាបក្ស ចំណែក នួន ជា នៅបន្តតួនាទីជាអនុលេខាបក្ស។ អៀង សារី និង សោ ភឹម បានឡើងតួនាទីជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ចំណែក វន់ វ៉េត, រស់ ញឹម, សុន សេន និង តាម៉ុក ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការមជ្ឈិម។ មហាសន្និបាត ក៏បានបញ្ជាក់ឡើងវិញពីការប្រើប្រាស់ហិង្សានយោបាយ និងប្រដាប់អាវុធ បើទោះបីជាតថភាពនយោបាយនៅពេលនោះបានរឹត ត្បិតលើលទ្ធភាពរបស់បក្ស ក្នុងការអនុវត្តហិង្សាប្រដាប់អាវុធជាចំហក៏ដោយ។ ដើម្បីរក្សាប្រត្តិបត្តិការសម្ងាត់របស់ខ្លួនបក្សមិនអនុញ្ញាតឲ្យសមាជិកក្រុមប្រជាជនអចិន្ត្រៃយ៍ ដូចជា កែវ មាស ចូលរួមនៅក្នុងមហាសន្និបាតលើកទីពីរឡើយ។ នៅពេលនោះ វន់ វ៉េត ត្រូវបានតែងតាំងជាគណៈកម្មាធិការបក្សប្រចាំទីក្រុងនៅភ្នំពេញជាមួយនឹង នួន ជា។

**២០៧.** នៅដើមខែមីនា ឆ្នាំ១៩៦៣ សម្តេច នរោត្តម សីហនុបានរំលាយរដ្ឋាភិបាល ដោយចោទប្រកាន់សង្គមរាស្ត្រនិយមថា ដោះស្រាយមិនបានត្រឹមត្រូវទៅលើការបះបោររបស់ប្រជាជននៅខេត្តសៀមរាប នៅចុងឆ្នាំ១៩៦២ ហើយបណ្តាលឲ្យស្លាប់បាតុករវ័យក្មេងម្នាក់ដែលស្ថិតនៅក្រោមការឃុំឃាំងរបស់នគរបាល និងមានការប្រឆាំងតទៅលើអាជ្ញាធរ។ ប៉ុន្មានថ្ងៃក្រោយមក សម្តេច នរោត្តម សីហនុ បានចេញផ្សាយបញ្ជីឈ្មោះមនុស្សចំនួន ៣៤ រូប ដែលត្រូវបានកំណត់និងដាក់ការសង្ស័យថាជាអ្នកឆ្វេងនិយម ក្នុងនោះមាន ខៀវ សំផន, ប៉ុល ពត, ហ៊ូ នឹម, ហ៊ូ យន់, អៀង សារី, សុន សេន និង ជូ ជេត ជាហេតុជំរុញឲ្យពួកគេបង្កើតរដ្ឋាភិបាលថ្មីមួយ។ ដោយសារភ័យខ្លាចការចាប់ខ្លួន ប៉ុល ពត, អៀង សារី និង សុន សេន បានរត់គេចខ្លួនចូលព្រៃ ទៅកាន់តំបន់ក្បែរព្រំដែនវៀតណាម ដោយទុកឲ្យ នួន ជា ធ្វើជាប្រធានបក្សដែលមានតែឈ្មោះ នៅក្នុងទីក្រុងភ្នំពេញ។ ខៀវ សំផន និង ហ៊ូ យន់ ក្នុងចំណោមអ្នកដែលយកចិត្តទុកដាក់ចំពោះការអំពាវនាវរបស់សម្តេច នរោត្តម សីហនុ មិនហ៊ានបង្កើតរដ្ឋាភិបាលថ្មីតាមការជំរុញរបស់ព្រះអង្គឡើយ ហើយបានស្នើសុំឲ្យព្រះអង្គជាអ្នកដឹកនាំរដ្ឋាភិបាលវិញ។ អ្នកទាំងពីរនេះ បានបាត់បង់តំណែងជារដ្ឋមន្ត្រីរបស់ខ្លួនដោយសារតែរឿងអាស្រូវនេះ ប៉ុន្តែគាត់នៅបន្តកាន់អាសនៈនៅក្នុងរដ្ឋសភាបន្តទៀត។ ហ៊ូ នឹម បានបាត់បង់តំណែងជានិពន្ធនាយកនៃសារព័ត៌មានផ្លូវការរបស់សង្គមរាស្ត្រនិយម។

**២០៨.** ការវាយប្រហារជាបន្តបន្ទាប់ទៅលើក្រុមឆ្វេងនិយមផ្នែកនយោបាយ បានជំរុញឲ្យគណៈកម្មាធិការមជ្ឈិមនៃបក្សពលករកម្ពុជាអនុម័តយក «អំពើហិង្សាបដិវត្តន៍» ជាផ្នែកមួយនៃមាគ៌ាបក្ស នៅក្នុងខែមករា ឆ្នាំ១៩៦៥ ជាមាគ៌ាមួយដែលបក្សពលករវៀតណាមបានជំទាស់។ នៅពេលបំពេញទស្សនកិច្ចនៅក្រុងហាណូយ នៅពាក់កណ្តាលឆ្នាំ១៩៦៥ ប៉ុល ពត ត្រូវបានបក្សពលករវៀតណាម ទទូចឲ្យផ្អាកជម្លោះប្រដាប់អាវុធរហូតដល់ពេលដែលវៀតណាមខាងត្បូង «ត្រូវបានរំដោះ» ដែលនៅពេលនោះ វៀតណាមនឹងរំដោះកម្ពុជា។ នៅពេលនោះ ប៉ុល ពត មិនបានដឹងសោះថា សម្តេច នរោត្តម សីហនុ នៅប៉ុន្មានខែមុននោះបានបង្កើតសម្ព័ន្ធភាពជាមួយវៀតណាមខាងជើង ដោយអនុញ្ញាតឲ្យរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង (វៀតកុង) បោះទីតាំងទ័ពនៅក្នុងទឹកដីកម្ពុជា និងទទួលយកអាវុធពីចិន ដែលដឹកជញ្ជូនតាមកំពង់ផែកំពង់សោម (ក្រុងព្រះសីហនុ)។

**(តនៅលេខក្រោយ)**





# មជ្ឈមណ្ឌលឯកសារកម្ពុជាបើកដំណើរការមជ្ឈមណ្ឌលមួយនៅខេត្តតាកែវ អំពីរបបខ្មែរក្រហម និងផលវិបាកនៃរបបនេះ

***មជ្ឈមណ្ឌលនេះនឹងជួយបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រដែលនឹងបង្រៀនប្រវត្តិសាស្ត្រនៃរបបនេះ នៅតាមបណ្តាសាលារដ្ឋ ព្រមទាំងព្យាយាមជួយឱ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចែករំលែករឿងរ៉ាវរបស់ខ្លួនទៅកាន់កូនចៅរបស់គាត់។***

**មីរ៉ែយល ឌាំតុន**



លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា ចូលរួមជាគណអធិបតីក្នុងពិធីបើកសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តតាកែវ ជាផ្លូវការកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលប្រទេសកម្ពុជាស្ថិតនៅក្នុងសង្គ្រាមស៊ីវិល ខេត្តតាកែវបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមទៅហើយ។

ជំរំការងារដំបូងបង្អស់ ដែលក្រោយមកត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសក្នុងរបបនោះ បានបើកដំណើរការប្រហែលឆ្នាំ១៩៧៣ អមជាមួយគុក និងមន្ទីរសម្លាប់គ្រប់គ្រងដោយ តាម៉ុក ដែលបន្ទាប់មកជាអ្នកពាក់ព័ន្ធនឹងបទឧក្រិដ្ឋដ៏អសោចរបស់ខ្មែរក្រហមជាច្រើនទៀត។ បទឧក្រិដ្ឋទាំងនោះ ក៏ចាប់ផ្តើមចេញពីខេត្តតាកែវដែរ។

ហេតុនេះហើយទើបកាលពីឆ្នាំមុន នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា សម្រេចចិត្តបើកដំណើរមជ្ឈមណ្ឌលនៅខេត្តតាកែវ ដោយរួមសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានគ្រោងដាក់បញ្ចូលព្រឹត្តិការណ៍ជាក់លាក់នានា ដែលធ្លាប់បានកើតឡើងនៅក្នុងខេត្តនេះក្នុងអំឡុងរបបខ្មែរក្រហម។



កងកុមារីវ័យជំទង់ កំពុងដឹកជញ្ជូនសម្ភារ និងគ្រាប់រំសេវ។ រូបថតប្រហែលក្នុងឆ្នាំ១៩៧៧។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារខេត្តតាកែវ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងឆ្លុះបញ្ចាំងពីផលវិបាកដែលប្រទេសកម្ពុជាបានទទួលរងបន្ទាប់ពីសង្គ្រាម និងជម្លោះជាច្រើនទសវត្សរ៍ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ និងទសវត្សរ៍ឆ្នាំ១៩៨០ ព្រមទាំងបទពិសោធន៍ឆ្លងកាត់ ដែលអ្នករស់រានមានជីវិតជាច្រើនក្នុងព្រឹត្តការណ៍ទាំងនោះ នៅមិនទាន់អាចទទួលយកបានទាំងស្រុងនៅឡើយ។

## ការបង្រៀនគ្រូអំពីវិធីសាស្ត្របង្រៀនអំពីប្រវត្តិសាស្ត្រនៃរបបនេះដែលទើបតែបញ្ចប់ថ្មីៗ

មជ្ឈមណ្ឌលនេះ ត្រូវបានបើកសម្ពោធជាផ្លូវការនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ដោយមានវត្តមានរបស់លោកជំទាវ ទន់ សាអ៊ឹម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលបានថ្លែងសុន្ទរកថាស្វាគមន៍នៅក្នុងពិធីបើកសម្ពោធថា ដោយសារតែជំងឺរាតត្បាតកូវីដ-១៩ កម្មវិធីនេះ មានវត្តមានភ្ញៀវចូលរួមប្រមាណ ២០ នាក់តែប៉ុណ្ណោះ ដោយភ្ញៀវកិត្តិយសទាំងអស់ត្រូវពាក់ម៉ាសការពារ និងវាស់កម្តៅនៅពេលអញ្ជើញមកដល់ ព្រមទាំងត្រូវគោរពតាមគោលការណ៍រក្សាគម្លាត។

ដោយសារតែគូនាទីមួយក្នុងចំណោមតួនាទីទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជួយបណ្តុះបណ្តាលគ្រូដែលបង្រៀនក្នុងមុខវិជ្ជាប្រវត្តិសាស្ត្រនៅតាមបណ្តាសាលារដ្ឋ មជ្ឈមណ្ឌលនេះ មានទីតាំងស្ថិតនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ។ លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានមានប្រសាសន៍ថា «[យើង] មិនចង់ឲ្យគ្រូបង្រៀនបង្រៀនពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់វិធីសាស្ត្រខុស»។

លោកបានពន្យល់ថា គ្រូផ្នែកប្រវត្តិសាស្ត្រដែលបង្រៀននៅតាមសាលារៀនទូទាំងប្រទេសកម្ពុជា មានពីរក្រុម។ ក្រុមទីមួយ គឺជាគ្រូបង្រៀនដែលធ្លាប់បានឆ្លងកាត់របបនេះ (ពីខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩) ឬសង្គ្រាមស៊ីវិលដែលបានកើតមានឡើងនៅទសវត្សរ៍ឆ្នាំ១៩៨០ ។ លោក រ៉ាស៊ី បានលើកឡើងថា «អ្នកទាំងនេះ មានអារម្មណ៍ខឹងសម្បារ ហើយបានដាក់កំហឹងនេះទៅក្នុងការបង្រៀនរបស់ខ្លួន។ ចំណែកឯសិស្សានុសិស្សក៏មានអារម្មណ៍ថាខឹងដែរ»។

លោកបានបន្តថា «គ្រូបង្រៀនមួយក្រុមទៀត គឺជាអ្នកជំនាន់ក្រោយដែលកើតក្រោយរបបខ្មែរក្រហម។ គ្រូបង្រៀនទាំងនោះ មិនបានដឹងអំពីខ្មែរក្រហម ឬ ពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រនៃរបបនេះទេ។ ដោយសារតែមូលហេតុនេះ យើងចង់ប្រមូលផ្តុំគ្រូទាំងពីរក្រុម ដើម្បីពន្យល់បកស្រាយអំពីវិធីសាស្ត្របង្រៀនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ក្នុងគោលបំណងពិភាក្សាខ្លឹមសារប្រវត្តិសាស្ត្រ ព្រមទាំងផ្តល់ជាវិធីសាស្ត្របង្រៀនដល់គ្រូទាំងនោះ»។





## បង្ហាញអំពីព្រឹត្តិការណ៍នានាដែលលងបន្លាចប្រជាជនរហូតដល់សព្វថ្ងៃ

មជ្ឈមណ្ឌលខេត្តតាកែវ ត្រូវបានរៀបចំឡើង ដើម្បីបង្ហាញអំពីប្រវត្តិសាស្ត្ររបស់ខេត្តនេះក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០។

លោក រ៉ាស៊ី បាននិយាយថា "ប្រសិនបើអ្នកទៅទស្សនាការិយាល័យនេះ អ្នកនឹងឃើញរូបថតរបស់មនុស្សចំនួន ៣០នាក់ ដែលបច្ចុប្បន្នកំពុងរស់នៅក្នុងស្រុកអន្លង់វែង។ អ្នកទាំងនេះមានដើមកំណើតមកពីខេត្តតាកែវ ហើយគាត់ គឺជាសាច់ញាតិរបស់អតីតសមាជិកខ្មែរក្រហម ដែលបានផ្លាស់ទៅនៅស្រុកអន្លង់វែងក្នុងខេត្តឧត្តរមានជ័យ ហើយមិនដែលត្រឡប់មកវិញទេ"

លោក រ៉ាស៊ី បានបន្តទៀតថា មានរូបថតនៃអតីតអ្នកទោសខ្មែរក្រហមមកពីខេត្តតាកែវចំនួន ៣៦សន្លឹក ទៀតដែរ។ «រូបថតទាំងអស់នេះត្រូវបានថតនៅ ទួលស្លែង [ជំរំសម្លាប់ក្នុងទីក្រុងភ្នំពេញ] នៅចន្លោះឆ្នាំ ១៩៧៦ និងឆ្នាំ១៩៧៨។ នេះមានន័យថា ប្រជាជនទាំងអស់នៅក្នុងបណ្តុំរូបថតនេះ បានស្លាប់ក្នុងរបបខ្មែរក្រហម។

លោក រ៉ាស៊ី បានបន្ថែមថា «មនុស្សទាំង ២ ក្រុមខាងលើ មានដើមកំណើតមកពីខេត្តតាកែវ»។

បណ្តុំរូបថតទាំងពីរនេះ បានឆ្លុះបញ្ចាំងអំពីស្ថានភាពស្មុគស្មាញ ដែលបន្សល់ទុកដោយរបបខ្មែរក្រហម និងសង្គ្រាមដែលកើតមាននាទសវត្សរ៍ឆ្នាំ១៩៨០ ហើយមនុស្សជាច្រើនបានបន្តប្រឈមតទល់នឹងស្ថានភាពស្មុគស្មាញទាំងអស់នោះ។

អ្នកស្រី សូ ហ្វារីណា នាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានមានប្រសាសន៍ថា «នៅឆ្នាំ១៩៧៣ ប្រហែលជាង ៧០ ភាគរយ នៃផ្ទៃប្រទេស (រួមទាំងខេត្តតាកែវ) ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ប្រជាជនត្រូវបានបង្ខំឲ្យចូលរួមក្នុងចលនាខ្មែរក្រហម ហើយក្នុងអំឡុងពេលនៃការបោសសម្អាតដែលធ្វើឡើងដោយរបបនេះ នៅរវាងឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨ អ្នកដែលបានចូលរួមជាមួយខ្មែរក្រហមជាច្រើនបានទៅរស់នៅក្នុងស្រុកអន្លង់វែង ដែលក្រោយមកក្លាយទៅជាតំបន់កាន់កាប់របស់ខ្មែរក្រហមនៅភាគខាងជើងប្រទេសកម្ពុជា។ អ្នកទាំងនោះមិនដែលវិលត្រឡប់ទៅស្រុកវិញទេ ដោយសារមូលហេតុថា អ្នកទាំងនោះខ្លាចរអាចំពោះការសងសឹកប្រសិនបើខ្លួនវិលត្រឡប់ស្រុកមកកំណើតវិញ ឬដោយសារតែអ្នកទាំងនោះបានកសាងជីវិតរបស់ខ្លួននៅស្រុកអន្លង់វែងរួចទៅហើយ។

ការតាំងបង្ហាញបណ្តុំរូបថតទាំងនេះ នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីផ្សារភ្ជាប់ក្រុមខាងលើជាមួយនឹងសាច់ញាតិរបស់ខ្លួននៅក្នុងខេត្តតាកែវ។ លោក រ៉ាស៊ី បានបន្តថា «បច្ចុប្បន្ន មានតែរូបថតរបស់បុគ្គលទាំងនោះតែប៉ុណ្ណោះ ដែលបង្ហាញខ្លួននៅខេត្តតាកែវ។ ប៉ុន្តែនៅពេលក្រោយ បុគ្គលទាំងនេះអាចនឹងមកកាន់ខេត្តតាកែវដោយផ្ទាល់ ដើម្បីស្វែងរកជួប និងនិយាយទៅកាន់ក្រុមគ្រួសាររបស់ខ្លួន។»

ដោយសារតែការផ្សះផ្សា គឺជាគោលដៅរបស់មជ្ឈមណ្ឌលនៅតាមខេត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បី៖ អនុញ្ញាតឲ្យមានអន្តរកម្មរវាងជនរងគ្រោះនៃរបបខ្មែរក្រហម ដែលតស៊ូរស់រានមានជីវិតពីរបបនេះ និងអតីតខ្មែរក្រហម, លើកទឹកចិត្តឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះនិយាយទៅកាន់កូន និងចៅរបស់ខ្លួន ដោយហេតុថា អ្នករស់រានមានជីវិតភាគច្រើនមិនធ្លាប់បានរៀបរាប់ពីបទពិសោធន៍របស់ខ្លួននៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ និងទសវត្សរ៍ឆ្នាំ១៩៨០ ពីមុនមក។

## ផ្សព្វផ្សាយទៅកាន់ប្រជាជននៅទូទាំងប្រទេស ទាំងតាមប្រព័ន្ធអនឡាញនិងដោយផ្ទាល់

លោក រ៉ាស៊ី បាននិយាយថា «នៅក្នុងអំឡុងពេលជំងឺរាតត្បាតជាសាកលនេះ ការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអនឡាញ ចាំបាច់គួរធ្វើឡើងជាងការទាក់ទងផ្ទាល់ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានទីតាំងនៅទីក្រុងភ្នំពេញ បានរៀបចំកន្លែងនិងឧបករណ៍ ដែលអាចឲ្យមនុស្សម្នាអាចធ្វើសន្និសីទតាមប្រព័ន្ធអនឡាញក្នុងរាជធានីភ្នំពេញ ហើយប្រជាជននៅខេត្តតាកែវក៏អាចចូលរួមសន្និសីទនេះបានតាមប្រព័ន្ធអនឡាញដូចគ្នា នៅឯមជ្ឈមណ្ឌលខេត្តតាកែវ។ បន្ថែមលើសពីនេះទៅទៀត មជ្ឈមណ្ឌលខេត្តតាកែវ អនុញ្ញាតឲ្យប្រជាជន

ចូលទៅប្រើប្រាស់បណ្ណសារឯកសារស្តីពីរបបខ្មែរក្រហម ដ៏សម្បូរបែបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមប្រព័ន្ធអនឡាញថែមទៀតផង។

អ្នកស្រី ហ្សារីណា បាននិយាយថា «ទោះបីជាយ៉ាងណាក្តី សកម្មភាពទាំងអស់មិនអាចធ្វើឡើងតាមប្រព័ន្ធអនឡាញទាំងអស់ទេ នេះជាមូលហេតុដែលការបង្កើតឲ្យមានមជ្ឈមណ្ឌលពិតប្រាកដ គឺពិតជាមានសារសំខាន់។ ការទៅស្វែករកឯកសារដោយផ្ទាល់ គឺសំខាន់ដូចគ្នា ដូចទៅនឹងការប្រើប្រាស់ឯកសារតាមប្រព័ន្ធអនឡាញ ពីព្រោះថា ដើម្បីរំឭកប្រជាជនកម្ពុជា និងពិភពលោកពីអំពើប្រល័យពូជសាសន៍ ព្រមទាំងដើម្បីទប់ស្កាត់ការកើតមានឡើងវិញនៃអំពើហិង្សានៅក្នុងប្រទេសកម្ពុជានិងនៅតាមទីតាំងដទៃទៀត យើងចាំបាច់ត្រូវមានទីតាំងពិតប្រាកដ និងការខិតខំប្រឹងប្រែងជាបន្តបន្ទាប់។

អ្នកស្រី ហ្សារីណា បានបន្តថា «ដូច្នេះ នេះគឺជាហេតុផលសំខាន់មួយ ដែលយើងបង្កើតមជ្ឈមណ្ឌលខេត្តតាកែវ និងមជ្ឈមណ្ឌលនៅតាមបណ្តាខេត្តនានា។ ទន្ទឹមនឹងនេះដែរ គឺដើម្បីបញ្ជាក់ថាប្រជាជន ឬ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មិនមែនមាននៅក្នុងទីក្រុងតែប៉ុណ្ណោះទេ ប៉ុន្តែគឺនៅគ្រប់ទីកន្លែងទូទាំងប្រទេស ហើយយើងចាំបាច់ចូលទៅជិតគាត់»។

លោកស្រីបានបន្ថែមថា នេះគឺជាមូលហេតុដែលមជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបើកមជ្ឈមណ្ឌលមួយចំនួនបន្ថែមទៀត ក្នុងរយៈពេលពីរឆ្នាំខាងមុខ។

មជ្ឈមណ្ឌលឯកសារខេត្តតាកែវ អាចបើកដំណើរ-ការបាន ដោយសារទទួលបានជំនួយគាំទ្រចម្បងពីសំណាក់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនៅកម្ពុជា។

សហភាពអឺរ៉ុប និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ ក៏បានផ្តល់ការគាំទ្រចំពោះការបើកដំណើរការមជ្ឈមណ្ឌលតាមបណ្តាខេត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅទូទាំងផ្ទៃប្រទេសដែរ។



កងយុទ្ធនារី ខ្មែរក្រហម។
រូបថតក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៨។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ការដ្ឋានលើកទំនប់ដីកប្រឡាយក្នុងរបបខ្មែរក្រហម
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# វត្តមាននៃការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តតាកែវ

## ជំរុញការសិក្សាស្រាវជ្រាវនិងបង្កើនការយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យ

សន ប៊ុនស៊ីម



លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា ចូលរួមជាគណអធិបតីក្នុងពិធីបើកសម្ពោធ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តតាកែវ ជាផ្លូវការកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្ពោធដាក់ឲ្យប្រើប្រាស់ «ការិ-យាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តតាកែវ ជាផ្លូវការកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ នៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ។ ការិយាល័យនេះ នឹងដើរតួនាទីជាទីតាំងផ្លូវការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រចាំនៅខេត្តតាកែវ ដើម្បីទទួលស្វាគមន៍អ្នកស្រាវជ្រាវ និងសាធារណជន ព្រមទាំងចែកចាយឯកសារទាក់ទងនឹងរបបខ្មែរក្រហមដោយផ្តោត ជាពិសេស លើភូមិភាគនិរតីក្នុងរបបកម្ពុជាប្រជាធិបតេយ្យរួមមាន ខេត្តតាកែវ កំពត និងផ្នែកខ្លះនៃខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ។

ពិធីសម្ពោធនេះ មានការអញ្ជើញចូលរួមពីសំណាក់លោកជំទាវ ទន់ សាអ៊ឹម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា, លោកស្រី សាវី ផល្លី អនុប្រធានមន្ទីរអប់រំ យុវជននិងកីឡា ខេត្តតាកែវ, តំណាងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ, តំណាងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិប្រចាំនៅកម្ពុជា, លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវនិងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងវត្តមានចូលរួមពីសំណាក់គរុសិស្ស, លោកគ្រូ-អ្នកគ្រូ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។

«ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តតាកែវ ដែលទទួលថវិកាគាំទ្រពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ នឹងដាក់តម្កល់ឯកសារប្រមាណជាង១លានឯកសារ ដែលរួមមាន ឯកសារជាក្រដាស រូបថត ខ្សែភាពយន្ត ខ្សែអាត់សំឡេង និងឯកសារភ័ស្តុតាងជាក់ស្តែង (ឯកសាររណ្តៅសាកសព)។ ឯកសារទាំងនេះ ផ្តល់ជាព័ត៌មានស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមយ៉ាងសម្បូរបែប ដែលជាធនធានស្រាវជ្រាវសម្រាប់គ្រូបង្រៀន មន្ត្រីរាជការសិស្សានុសិស្ស និងប្រជាជនទូទៅរស់នៅក្នុងខេត្តតាកែវ និងខេត្តកែប្រខាង។ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តតាកែវនេះ គឺជាមជ្ឈមណ្ឌលតំណាងទីបួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់ពីវត្តមាននៃ «មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង» ក្នុងខេត្តឧត្តរមានជ័យ «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តព្រៃវែង និង «មជ្ឈមណ្ឌលឯកសារកោះថ្ម» ក្នុងខេត្តត្បូងឃ្មុំ។

គួរបញ្ជាក់ថា ការបង្កើត «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» នេះ គឺជាផ្នែកមួយនៃគម្រោងអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យនៃគម្រោងសំណងតាមផ្លូវតុលាការនៅក្នុងក្របខណ្ឌនៃសំណុំរឿង០០២ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីឆ្នាំ២០១៣ ។ គម្រោងសំណងទាំងនេះមានគោលដៅ «ស្តារកិត្តិយស សេចក្តីថ្លៃថ្នូរ ប៉ះប៉ូវការឈឺចាប់ផ្លូវចិត្ត និងផ្នែកសង្គមរបស់ដើមបណ្តឹងរដ្ឋប្បវេណី រំឭកដល់អ្នកដែលបានបាត់បង់ជីវិត លើកកម្ពស់ការយល់ដឹង និងការស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម ព្រមទាំងដើម្បីធានាថាបទពិសោធន៍ក្នុងសម័យខ្មែរក្រហមនឹងមិនកើតមានជាថ្មីម្តងទៀតក្នុងសង្គមកម្ពុជានាពេលអនាគត»។

ទន្ទឹមនឹងនេះដែរ ការបង្កើត «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម» ខេត្តតាកែវនេះឡើង គឺស្របទៅនឹងស្មារតីនៃអនុស្សរណៈយោគយល់គ្នារវាងក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២២ ក្នុងការបន្ត និងបង្កើតថ្មីនូវកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដើម្បីពង្រីកវិសាលភាពនៃការអប់រំពីប្រវត្តិ-សាស្ត្រខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ និងគ្រូបង្រៀនទូទាំងប្រទេសឲ្យយល់កាន់តែច្បាស់ពីរឿងរ៉ាវពីអតីតកាលរបស់ប្រទេសខ្លួន។

តាមរយៈវត្តមាននៃការិយាល័យតាមបណ្តាខេត្តទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា អាចពង្រីកសកម្មភាពចែកចាយឯកសាររបស់ខ្លួនទៅកាន់ប្រជាជននៅតាមបណ្តាលខេត្ត ឬតំបន់ដែលមានការអភិវឌ្ឍតិចតួចដែលស្ថិតនៅក្រៅរាជធានីភ្នំពេញ បានទូលំទូលាយជាងមុន។ ថ្វីត្បិតតែមានការយាយីនៃជំងឺរាតត្បាតជាសកលយ៉ាងណាក្តី មជ្ឈមណ្ឌលឯកសារកម្ពុជា នៅតែបន្ត ចែករំលែកការយល់ដឹងនិងព័ត៌មាននានា ដែលជួយបង្កើនការយល់ដឹងរបស់សាធារណជនអំពីប្រវត្តិ-សាស្ត្រខ្មែរក្រហម។ ទោះបីជាស្នាក់នៅផ្ទះ មនុស្សម្នាក៏អាចប្រើប្រាស់បណ្តុំទិន្នន័យសព្ទជ្រុងជ្រោយរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាតាមប្រព័ន្ធអនឡាញ ដើម្បីស្វែងរកឯកសារនានា ដោយមានជំនួយពីបុគ្គលិកមជ្ឈមណ្ឌលប្រសិនបើចាំបាច់។ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ការផ្តល់ជាឯកសារផ្សេងៗតាមប្រព័ន្ធអនឡាញដល់អ្នកស្រាវជ្រាវទូទៅ នឹងលើកទឹកចិត្តឲ្យបុគ្គលទាំងនោះនៅផ្ទះ និងបង្កើនការអាននៅក្នុងអំឡុងពេលនៃភាពវឹកវរនៃជំងឺរាតត្បាត ដោយនេះគឺជាសកម្មភាពសាមញ្ញតែមានសារសំខាន់ក្នុងការចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ក្នុងការបង្ការការឆ្លងជំងឺកូវីដ១៩។





## «ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# សូត នៅ ៖ វេជ្ជបណ្ឌិត

**កូនស្រីរបស់គាត់ គឹម សុផានី បាន និយាយរៀបរាប់ប្រាប់ថា៖**

នៅក្នុងចំណោមឪពុកម្តាយរបស់យើង និងបងប្អូនប្រុសស្រី ១៣នាក់ មានតែយើងពីរនាក់គត់នៅមានជីវិតរស់នៅ ក្រោយរបបខ្មែរក្រហម។ ពួកគាត់ស្ទើរតែទាំងអស់ បានស្លាប់នៅឆ្នាំ១៩៧៧ ដោយសារការអត់ឃ្លាន និងជំងឺ។ ឪពុករបស់ខ្ញុំជាមនុស្សម៉ឺងម៉ាត់ និងមានការទទួលខុសត្រូវគាត់មិននិយាយស្តីច្រើនទេ។ គាត់កើតនៅក្នុងគ្រួសារក្រីក្រមួយមានកូនច្រើន ហើយបានរស់នៅក្នុងវត្តនៅពេលដែលគាត់ធំដឹងក្តី។



អែ វ៉ា នៅក្នុងពិធីទទួលរង្វាន់មួយ នៅភ្នំពេញ ឆ្នាំ១៩៦០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្តាយរបស់គាត់ឈឺជាញឹកញាប់ ហើយគាត់មានការពិបាកខ្លាំងណាស់ ព្រោះគាត់តែងតែខ្ចីប្រាក់អ្នកដទៃយកទៅព្យាបាលម្តាយគាត់។ ដូច្នេះគាត់បានសម្រេចចិត្តរៀនវេជ្ជសាស្ត្រ ជាមុខវិជ្ជាដែលគាត់ស្រឡាញ់។ គាត់ជានិស្សិតឆ្នើមម្នាក់ ទាំងពីរមុខវិជ្ជាទាំងវិទ្យាសាស្ត្រ និងភាសាបារាំង។

ឪពុករបស់ខ្ញុំ ខំប្រឹងធ្វើការយ៉ាងខ្លាំង ដើម្បីផ្គត់ផ្គង់កូន ១៨នាក់ របស់គាត់ ហើយបានឡើងឋានៈជាញឹកញាប់។ យើងរស់នៅក្នុងផ្ទះធំមួយ ព្រោះគាត់សន្សំប្រាក់បានច្រើន។ បន្ថែមពីលើការងារនៅមន្ទីរពេទ្យសុខភាពចិត្តសាស្ត្រនៅព្រែកត្នោត គាត់មានគ្លីនិកឯកជនមួយដែលអាចរកចំណូលក្រៅបន្ថែមបាន។ ម្តាយរបស់ខ្ញុំដាំ បន្លែខ្លះៗនៅផ្ទះ និងលក់បន្លែនោះនៅផ្សារដើម្បីជួយផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ។

ការជម្លៀសនៅឆ្នាំ១៩៧៥ បានជិតមកដល់ នៅទីនោះមានការបាញ់កាំភ្លើងនិងគ្រាប់បែកផ្ទុះរាល់យប់ដែលធ្វើឲ្យឪពុកខ្ញុំមិនអាចសម្រាន្តបាន។ ជាញឹកញាប់ គាត់បានស្នាក់នៅផ្ទះប្អូនស្រីពៅរបស់ខ្ញុំនៅក្រុងភ្នំពេញ ខណៈម្តាយរបស់ខ្ញុំរស់នៅជាមួយបងស្រីខ្ញុំនៅខេត្តកណ្តាល។ ឪពុកខ្ញុំបានចាកចេញពីផ្ទះនៅថ្ងៃ១៧ មេសា។

ពេលដែលគាត់បានមកដល់ ម្តាយខ្ញុំនិងប្អូនប្រុសស្រីផ្សេងទៀតបានចេញផុតទៅហើយ។ ឪពុកខ្ញុំដឹងថា ម្តាយខ្ញុំបាននាំកូនៗទាំងអស់ទៅស្រុកកំណើតរបស់គាត់នៅស្រុកស្អាង ហើយបានជួបយើងនៅទីនោះ។ ប៉ុន្តែយើងមិនអាចរស់នៅសុខស្រួលឡើយនៅក្នុងភូមិរបស់ម្តាយខ្ញុំ ព្រោះប្រជាជនជាច្រើននៅទីនោះបានដឹងថាយើងជាអ្នកធូរធា។

បន្ទាប់មកគ្រួសាររបស់យើងត្រូវបានបញ្ជូនទៅខេត្តកំពង់ឆ្នាំង។ ឪពុកខ្ញុំត្រូវធ្វើការធ្ងន់ ដោយមិនមានអាហារគ្រប់គ្រាន់។ គាត់ចាស់ហើយ ដូច្នេះគាត់មិនអាចស៊ូទ្រាំនឹងការងារលំបាកខ្លាំងដែលគាត់បានប្រឈមទេ។ យប់មួយនោះគាត់បានសម្រេចចិត្តទៅលួចបេះស្វាយទុំនៅខាងក្រោយមន្ទីរយោធាខ្មែរក្រហម។ ខ្ញុំព្យាយាមបញ្ឈប់គាត់ ប៉ុន្តែគាត់មិនស្តាប់ខ្ញុំឡើយ។ គាត់មានសំណាងមែន ពេលនោះមេឃងងឹត និងមានភ្លៀងធំ គាត់មិនត្រូវបានចាប់ខ្លួនឡើយ។ គាត់យកស្វាយទុំ១០ផ្លែឲ្យកូនៗដែលរស់នៅជាមួយគាត់។ បងប្អូនប្រុសស្រីរបស់ខ្ញុំ៥នាក់ធ្វើការនៅក្បែរព្រំដែនកម្ពុជា-ថៃ អត់ឃ្លានរហូតដល់ស្លាប់ម្នាក់ម្តងៗជាបន្តបន្ទាប់។

ប្រជាជនជាច្រើននៅក្នុងភូមិ បានចាប់ផ្តើមស្លាប់ដោយសារអត់ឃ្លាននៅឆ្នាំ១៩៧៦។ នៅឆ្នាំ១៩៧៧ ស្បៀងជិតអស់ ហើយអង្គការមិនបានផ្តល់អង្ករឲ្យយើងចំនួនបីថ្ងៃ។ ម្តាយរបស់ខ្ញុំបានដូរគ្រឿងអលង្ការរបស់គាត់យកជាអង្ករ ត្រី និងប្រហុក។ នៅពេលដែលគ្រឿង

អលង្ការរបស់គាត់អស់ទៅឪពុករបស់ខ្ញុំបានស្លាប់ដោយសារការអត់ឃ្លាន។ បងស្រីខ្ញុំបានសរសេរឈ្មោះរបស់ឪពុកខ្ញុំនៅលើក្រដាសមួយសន្លឹក ហើយដាក់ចូលទៅក្នុងដបមួយ។ យើងបានកប់ដបនោះជាមួយនិងគាត់។ បងស្រីខ្ញុំចង់យើងចំណាំថា ប្រសិនបើមាននរណាម្នាក់ក្នុងចំណោមបងប្អូនយើងបានរស់ យើងអាចរកឃើញផ្នូររបស់គាត់នៅថ្ងៃមួយ ហើយធ្វើបុណ្យជូនគាត់។ មួយខែក្រោយមក ម្ដាយខ្ញុំបានស្លាប់ដោយសារគាំងបេះដូង។

នៅចុងឆ្នាំ១៩៧៨ អ្នកភូមិមួយចំនួនបានស្ដាប់វិទ្យុផ្សាយថា កងទ័ពវៀតណាមបានរំដោះប្រទេសកម្ពុជា។ អង្គការបានបញ្ជូនកងចល័តរបស់ខ្ញុំឲ្យជីករូងមួយដើម្បីរក្សាទុកអង្ករ ត្រីងៀត និងអំបិល។ ប្រជាជនដែលបានធ្វើការនៅក្នុងកងចល័តពីមុន ត្រូវបានបាញ់សម្លាប់បន្ទាប់ពីបានបញ្ចប់ការងាររបស់ខ្លួន។ ដូច្នេះបន្ទាប់ពីបានជីករូងរួច យើងបានរត់ចេញពីទីនោះ។

ខ្ញុំបានធ្វើដំណើរកាត់ព្រៃស្រោងជាច្រើនថ្ងៃ រហូតខ្ញុំបានទៅដល់ខេត្តកំពង់ឆ្នាំង។ ខ្ញុំបានសុំរថយន្តកងទ័ពវៀតណាមជិះជាមួយ។ បន្ទាប់ពីបានរស់នៅជាមួយម្ដាយមីងពីរនាក់របស់ខ្ញុំប្រហែលជាមួយឆ្នាំ ខ្ញុំបានត្រឡប់ទៅខេត្តកណ្ដាល ហើយបានឃើញបងស្រីបង្អស់របស់ខ្ញុំ គាត់ទើបតែចេញមកពីព្រៃស្រោង។

បងស្រីខ្ញុំ និងខ្ញុំនៅតែមិនអាចរកឃើញផ្នូររបស់ឪពុកខ្ញុំ ដោយសារមានរណ្ដៅសាកសពច្រើននៅក្នុងបរិវេណនោះ។

ប៊ុន ពីរ័ន្ត និង វេនី ខកហ្គៀល

## ដំណឹងស្វែងរកឪពុក និងបង



នាងខ្ញុំឈ្មោះ **ឡាត់ កញ្ញា** ឈ្មោះហៅក្រៅ ចក់។ ខ្ញុំមានបងប្អូន ៥នាក់ ខ្ញុំជាកូនពៅក្នុងគ្រួសារ។ ខ្ញុំកំពុងរកក្រុមគ្រួសារដែលបានបាត់ច្រើនឆ្នាំមកហើយ។ ប៉ារបស់ខ្ញុំឈ្មោះ សាមឿន ហៅ ឯម បែកគ្នានៅឆ្នាំ១៩៧៥ ។ បងស្រី វន្នី បានបែកគ្នានៅឆ្នាំ១៩៧៦។ ចំណែកបងប្រុសឈ្មោះ អាយបានបែកគ្នានៅឆ្នាំ១៩៧៩។ កាលឆ្នាំ១៩៧៩ ម៉ាក់របស់ខ្ញុំឈ្មោះ សេង លាង បងប្រុស និងខ្ញុំរស់នៅជាមួយគ្នា។ ក្រោយមកម៉ាក់ក៏បានស្លាប់នៅស៊ីសុផុន នៅក្នុងអំឡុងឆ្នាំ ១៩៧៩។ ខ្ញុំនិងបងប្រុសក៏បែកគ្នា ព្រោះបងប្រុសរបស់ខ្ញុំចង់ទៅភ្នំពេញ ដើម្បីតាមរកបងស្រី វន្នី សិន រីឯខ្ញុំក៏ទៅស្រុកថៃជួបជុំបងប្អូនជីដូនមួយរបស់ម៉ាក់។ សព្វថ្ងៃខ្ញុំរស់នៅសហរដ្ឋអាមេរិក។ រូបនេះ ថតនៅហ្វីលីពីន ក្នុងអំឡុងឆ្នាំ១៩៨០។ ខ្ញុំមានស្រុកកំណើតនៅសៃវ៉ា ខេត្តតាកែវ។ ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះខាងលើ សូមទំនាក់ទំនងមកនាងខ្ញុំតាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬអ៊ីម៉ែល truthbunthorn.s@dccam.org និងលេខទូរសព្ទ ០១២ ៩៩៦ ៧៥០។ សូមអរគុណ!

គេហទំព័រ៖ www.dccam.org



ស្វែងរកការពិត-ផ្នែកស្រាវជ្រាវរកក្រុមគ្រួសារ លេខ២៤៨ ខែសីហា ឆ្នាំ២០២០

«ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ព្រុំ ធុជ ៖ វេជ្ជបណ្ឌិត

**ក្មួយប្រុសសាច់ថ្លៃរបស់គាត់ឈ្មោះ ជា យ៉ុម បាននិយាយរៀបរាប់ប្រាប់ថា៖**

ធុជ បានបាត់ខ្លួននៅអំឡុងពេលជម្លៀសចេញពីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ គាត់បានកើតនៅខេត្តព្រៃវែង បន្ទាប់ពីបញ្ចប់វិទ្យាល័យមក គាត់បានសិក្សាវេជ្ជសាស្ត្រនៅក្រុងភ្នំពេញ។ គាត់បានជួបប្រពន្ធរបស់គាត់ឈ្មោះ ហៅ វណ្ណា នៅពេលដែលគាត់ទៅលេងខេត្តបាត់ដំបង។

បន្ទាប់ពីរៀបការរួចមក គាត់បានជួលផ្ទះល្វែងមួយនៅតាមមហាវិថីកម្ពុជាក្រោមនៅក្នុងរាជធានីភ្នំពេញ។ គាត់បានធ្វើការនៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា ប៉ុន្តែគាត់បានបើកគ្លីនិកមួយដើម្បីរកចំណូលបន្ថែម។ ប្រពន្ធរបស់គាត់បានគ្រប់គ្រងគ្លីនិក ហើយគ្រួសាររបស់គាត់មានជីវភាពធូរធារ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ធុជបានចាកចេញពីភ្នំពេញជាមួយប្រពន្ធ កូនៗ ឪពុកម្ដាយ និងបងប្អូនប្រុសស្រីរបស់គាត់ដោយធ្វើដំណើរតាមផ្លូវជាតិលេខ១១។ នៅពាក់កណ្ដាលផ្លូវ ប្រពន្ធ កូនៗ និងគាត់បានបែកផ្លូវ ដោយបាននិយាយថា ឪពុកម្ដាយរបស់គាត់ត្រូវតែទៅទិសដៅផ្សេងគ្នា។ គាត់មិនចង់ត្រឡប់ទៅភូមិកំណើតរបស់គាត់ទេ ព្រោះប្រជាជននៅទីនោះបានដឹងអំពីប្រវត្តិរបស់គាត់។ គាត់បានសុំខ្ញុំឲ្យជួយមើលថែទាំឪពុកម្ដាយរបស់គាត់។ បន្ទាប់មក ធុជ បានបាត់ខ្លួនទៅ។



ព្រុំ ធុជ នៅមន្ទីរពេទ្យ ព្រះកេតុមាលា ក្រុងភ្នំពេញ មុនឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឪពុកម្ដាយរបស់ ធុជ បងប្អូនប្រុសស្រីរបស់គាត់ពីរនាក់ទៀត និងខ្ញុំបានទៅភូមិកំណើតរបស់គាត់នៅខេត្តព្រៃវែង។ នៅអំឡុងរបបនោះ យើងបានផ្លាស់ទីលំនៅពីភូមិមួយទៅភូមិមួយទៀត ដើម្បីរកទីកន្លែងប្រសើរដែលមានស្បៀងច្រើន។ អ្នកទាំងអស់គ្នានៅក្នុងគ្រួសាររបស់ខ្ញុំជាប្រជាជនមូលដ្ឋាន ធុជ ជាមនុស្សម្នាក់គត់នៃគ្រួសារយើងដែលជាប្រជាជនថ្មី។

ម្ដាយរបស់ ធុជ បានស្លាប់ដោយជំងឺគ្រុនក្ដៅនៅអំឡុងរបបនោះខ្វះខាតថ្នាំពេទ្យព្យាបាល រួមនិងការខ្វះខាតស្បៀងអាហារ។ បន្ទាប់ពីគាត់ស្លាប់បាន៥ខែ ឪពុករបស់ ធុជ បានដាច់សរសៃឈាមខួរក្បាល ហើយក៏បានស្លាប់ទៅដែរ។ បន្ទាប់មកបងស្រីបង្អស់របស់ ធុជ ឈ្មោះ ជូ បានស្លាប់ដោយសារជំងឺ។ ប្អូនស្រីពៅរបស់ ធុជ ឈ្មោះ សាប ត្រូវបានបញ្ជូនទៅភូមិថ្មីមួយជាមួយកូនរបស់គាត់បីនាក់ ក៏បានបាត់ខ្លួនដែរ។ ខ្ញុំគិតថានាងត្រូវបានអង្គការសម្លាប់។ អ្នកភូមិជាច្រើននាក់ដែលបានបញ្ជូនទៅទីនោះមិនឃើញត្រឡប់មកវិញឡើយ។ ប្រពន្ធរបស់ ធុជ និងកូនៗ ឥឡូវនេះកំពុងរស់នៅប្រទេសអាមេរិក។ នៅឆ្នាំ១៩៨៣ វណ្ណា បានផ្ញើសំបុត្រមួយច្បាប់មកខ្ញុំ និយាយថា ធុជ បានស្លាប់ជាយូរឆ្នាំមកហើយ។ គាត់បាននិយាយថា កូនៗរបស់គាត់ដូចឪពុកណាស់។ នៅពេលនោះស្ថានការណ៍នយោបាយនៅក្នុងប្រទេសកម្ពុជាមិនមានសន្តិភាពឡើយ ខ្ញុំក៏មិនបានឆ្លើយឆ្លងទៅគាត់ដែរ។ បន្ទាប់មកខ្ញុំបានបាត់អាសយដ្ឋានរបស់គាត់។ ខ្ញុំសង្ឃឹមថា ធុជ នៅរស់នៅឡើយ។ ប្រសិនបើគាត់នៅរស់ គាត់នឹងត្រឡប់មកភូមិកំណើតរបស់គាត់។ ខ្ញុំសង្ឃឹមថាថ្ងៃណាមួយ ខ្ញុំនឹងរកឃើញអាសយដ្ឋានរបស់ប្រពន្ធគាត់នៅអាមេរិក ដូច្នេះខ្ញុំអាចផ្ញើរូបថតរបស់ ធុជ ទៅគាត់។

ចម្លើយសារភាពរបស់ ព្រុំ ធុជ បញ្ជាក់ថាគាត់បានចូលគុកទួលស្លែងនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦។

ប៊ុន ពីរ័ន្ត និង វេនី ខកហ្គៀល

«ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# អៃ វ៉ា ៖ អ្នកគ្រប់គ្រងសេវាកម្មអាហារដ្ឋាន

**ប្រពន្ធរបស់ អៃ វ៉ា ឈ្មោះ កែវ ម៉ារ៉ែត បាននិយាយរៀបរាប់ប្រាប់ថា៖**

ប្តីរបស់ខ្ញុំ និងខ្ញុំជាបងប្អូនជីដូនមួយនឹងគ្នា យើងបានធំដឹងក្តីជាមួយគ្នានៅខេត្តកំពង់ចាម។ ឪពុកម្តាយរបស់យើងបានរៀបចំពិធីមង្គលការរបស់យើង នៅពេលដែលប្តីខ្ញុំមានអាយុ២៥ឆ្នាំ ហើយនាងខ្ញុំមានអាយុ១៨ឆ្នាំ។ វ៉ា ជាមនុស្សល្អ សុភាពរាបសារ និងជាអ្នកខំប្រឹងប្រែងធ្វើការងារ។

នៅឆ្នាំ១៩៧០ វ៉ា ត្រូវបានតម្លើងជាប្រធាននាយកដ្ឋានសេវាកម្មម្ហូបអាហារ នៅសណ្ឋាគារសុខា ក្នុងក្រុងព្រះសីហនុ។ លក្ខខណ្ឌនៃការរស់នៅរបស់យើងមានលក្ខណៈល្អប្រសើរ។ គាត់ត្រូវបានផ្តល់ប្រាក់បន្ថែមខ្លះៗ សម្រាប់ចំណាយលើសុខភាព ព្រោះនៅក្នុងតំបន់របស់យើងជាកន្លែងដែលងាយកើតជំងឺគ្រុនចាញ់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានឮប្រជាជននិយាយថា ប្រទេសមានសន្តិភាព។ ខ្ញុំមានសេចក្តីត្រេកអរនិងរំភើបណាស់។ ខ្ញុំអាចទៅជួបឪពុកម្តាយរបស់ខ្ញុំជាលើកទីមួយក្នុងពេល៥ឆ្នាំ។ នៅថ្ងៃដដែលនោះ ប្តីរបស់ខ្ញុំបានទិញថ្នាំពេទ្យនៅផ្សារ ប៉ុន្តែហាងទាំងអស់ត្រូវបានបិទទ្វារ ហើយប្រាក់មិនត្រូវបានចាយវាយទៀតទេ។ យោធាខ្មែរក្រហមបានរឹបអូសយកម៉ូតូរបស់វ៉ា ហើយគាត់ក៏បានដើរមកផ្ទះ។



អៃ វ៉ា នៅក្នុងពិធីទទួលរង្វាន់មួយនៅភ្នំពេញ ឆ្នាំ១៩៦០។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យោធាខ្មែរក្រហមបានប្រាប់យើងឲ្យចាកចេញពីផ្ទះរបស់យើង ដូច្នេះយើងអាចធ្វើដំណើរទៅជួបឪពុកម្តាយរបស់យើង។ ខ្ញុំជឿជាក់លើយោធាខ្មែរក្រហម។ គ្រួសាររបស់យើងមិនទាន់បានចាកចេញទេ រហូតដល់ថ្ងៃ២៨ ខែមេសា ព្រោះប្តីរបស់ខ្ញុំនៅមើលថែសណ្ឋាគារ ទាល់តែភ្ញៀវទាំងអស់ចាកចេញ។ ភាគច្រើននៃភ្ញៀវជាមន្ត្រីជាន់ខ្ពស់ និងខ្លះទៀតជាជនបរទេសមានចិន បារាំង និងអាមេរិកកាំង។

មានគ្រួសារផ្សេងទៀតចំនួនតែពីរបីគ្រួសារប៉ុណ្ណោះនៅតាមផ្លូវពេលដែលយើងធ្វើដំណើរចាកចេញ។ យើងចង់ទៅភូមិកំណើតរបស់យើង ប៉ុន្តែអង្គការបានបញ្ជូនយើងឲ្យទៅស្រុកព្រៃនប់។ យើងរស់នៅក្នុងតង់មួយអាទិត្យ រហូតដល់យើងធ្វើបានខ្ទមតូចមួយសម្រាប់គ្រួសាររបស់យើង។

អង្គការបានចាប់ផ្តើមសួរប្រវត្តិរូបរបស់យើងភ្លាមៗ។ ខ្ញុំបានប្រាប់អង្គការថា ប្តីរបស់ខ្ញុំជាអ្នកលក់ទឹកកក ហើយថាខ្ញុំជាអ្នកលក់បារី។ ខ្ញុំមិនបានដឹងថាអង្គការជឿយើងឬអត់ទេ។ យើងត្រូវបានផ្តល់នូវអង្ករចំនួន ៧កំប៉ុង ក្នុងមួយថ្ងៃ មួយកំប៉ុងសម្រាប់ប្តីខ្ញុំ ខ្ញុំ និងកូន៥នាក់របស់យើង។ ដំបូងឡើយយើងបានហូបគ្រប់គ្រាន់ អង្គការក៏បានផ្តល់ឲ្យយើងនូវត្រី សាច់ និងបន្លែខ្លះៗដែរ។

នៅអំឡុងពេលប្រមូលផលស្រូវ អង្គការបានចាត់តាំងយើង និងបួនគ្រួសារផ្សេងទៀតឲ្យទៅប្រចួតកាត់នៅភូមិថ្មីមួយ។ បន្ទាប់ពីធ្វើដំណើរបានមួយឬពីរថ្ងៃ យើងដឹងថាយើងស្ថិតនៅក្នុងខេត្តកោះកុង ដែលប្រជាជនបាននិយាយគ្រាមភាសា តែខ្ញុំមិនអាចយល់ពីន័យបាន។ យើងបានរស់នៅជាមួយប្តីប្រពន្ធចំណាស់មួយគូ ដែលអ្នកទាំងពីរមានសន្តានចិត្តល្អគាត់បានចម្អិនបបរស្ករឲ្យយើងហូប។

ខ្ញុំត្រូវបានចាត់តាំងឲ្យស្ទូងស្រូវ ប៉ុន្តែនៅក្នុងស្រែមានឈ្លើងជាច្រើន។ ប្តីរបស់ខ្ញុំបានប្រាប់ខ្ញុំកុំឲ្យស្រែកនៅពេលឈ្លើងទាមខ្ញុំ បើមិនអ៊ីចឹងទេ អង្គការនឹងបញ្ជូនខ្ញុំទៅរៀនសូត្រមិនខាន។ ទីបំផុត ខ្ញុំទម្លាប់បានទៅនឹងឈ្លើងទាម។





វ៉ា ត្រូវបានអង្គការយកទៅរៀនសូត្ររយៈពេលបីខែ នៅឃុំជើងគោ ពេលដែលគាត់កំពុងតែភ្ជួរស្រែ។ ខ្ញុំបារម្ភថា គាត់ត្រូវបានធ្វើទារុណកម្ម ឬបញ្ជូលទៅក្នុងពលកម្មធ្ងន់ធ្ងរ។ នៅថ្ងៃដែលគាត់ត្រឡប់មកវិញ ខ្ញុំមើលគាត់ស្ទើរតែមិនស្គាល់។ គាត់មានរូបរាងស្គមស្គាំង ជង្គង់របស់គាត់មានទំហំស្ទើរប៉ុនក្បាលរបស់គាត់ទៅហើយ។ ប្តីខ្ញុំបានខ្សឹបប្រាប់ខ្ញុំថា ប្រសិនបើគាត់មិនបាននៅជាមួយខ្ញុំ ខ្ញុំត្រូវតែម៉ឺងម៉ាត់ និងខំប្រឹងប្រែងធ្វើការងារ។

លក្ខខណ្ឌជីវិតរបស់យើងពិបាកខ្លាំងណាស់។ យើងមានខោអាវតែមួយបម្លាស់សម្រាប់ផ្លាស់ប្តូរ និងមិនមានមុងការពារមូសឡើយ។ យើងបានហូបបបរលាយជាមួយព្រលិត និងស្រទបចេក។ ថ្ងៃមួយនោះ អង្គការបាននិយាយថា យើងអាចដាំបន្លែផ្ទាល់ខ្លួនសម្រាប់ហូបបាន។ ដូច្នេះ យើងបានដាំដំឡូង ប៉ុន្តែអង្គការបានប្រកាសថា ដំឡូងជារបស់សហករណ៍។ កូនរបស់យើងយំជាញឹកញាប់ដោយចង់ហូបដំឡូង ប៉ុន្តែយើងមិនហ៊ានដកមើមដំឡូងឡើយ។

ប៉ុន្តែថ្ងៃមួយ នៅពេលដែល វ៉ា ត្រឡប់មកពីស្រែវិញ គាត់បានដកមើមដំឡូងបានបីដុំដែលដាំនៅក្រោមជណ្តើរផ្ទះរបស់យើង។ ខ្ញុំមកដល់ផ្ទះរៀបតែនឹងដួតទឹកទៅហើយ ពេលនោះខ្ញុំបានឮប្តីខ្ញុំប្រាប់កូនៗ ឲ្យយកដំឡូងមកឲ្យខ្ញុំហូប។ ខ្ញុំភ័យយ៉ាងខ្លាំង ខ្ញុំមិនដែលហ៊ានដកដំឡូងនោះឡើយ ទោះជាកូនរបស់យើងឃ្លានយ៉ាងណាក្តី។ ប្តីរបស់ខ្ញុំបាននិយាយថា គាត់នឹងត្រូវយកទៅរៀនប៉ុណ្ណោះ ប្រសិនបើអង្គការដឹង។

ខណៈដែលគាត់កំពុងស្ងោរដំឡូង អ្នកស៊ើបការណ៍ភូមិពីរនាក់បានឃើញគាត់ ហើយសួរគាត់ថាកំពុងធ្វើអី។ វ៉ា បានឆ្លើយថា គាត់កំពុងដាំទឹក។ ទោះយ៉ាងណា អ្នកស៊ើបការណ៍ភូមិបានឃើញដីនៅក្រោមខ្ទមរបស់យើងមានស្នាមគាស់កកាយ។ អ្នកស៊ើបការណ៍បានត្រឡប់មកវិញនាពាក់កណ្តាលអធ្រាត្រ ហើយបានហៅប្តីរបស់ខ្ញុំឲ្យទៅចាប់ក្របីដែលកំពុងស៊ីសំណាប។ គាត់បានចេញពីផ្ទះយ៉ាងប្រញាប់ យកបានតែក្រមារបស់គាត់ទៅតាមខ្លួន។ ខ្ញុំសម្លឹងគាត់ចាកចេញទៅជាមួយអ្នកផ្សេងពីរនាក់ទៀតមានអធិការកិច្ចម្នាក់ និងបុរសម្នាក់ទៀតដែលធ្វើការនៅសាលាក្រុងព្រះសីហនុ។

របបអាហាររបស់យើងត្រូវបានកាត់បន្ថយបន្ទាប់ពីប្តីខ្ញុំត្រូវបានយកចេញទៅ។ មានតែបាយមួយចានប៉ុណ្ណោះ ត្រូវចែករំលែកជាមួយកូនបីនាក់របស់ខ្ញុំ។ កូនទីមួយស្លាប់ ឈ្មោះសូរីវ៉ា វាអត់ឃ្លានរហូតដល់ស្លាប់។ ខ្ញុំបានយកវាទៅមន្ទីរពេទ្យ ដោយសង្ឃឹមថាអង្គការនឹងមានទឹកដោះគោ ប៉ុន្តែពេទ្យបាននិយាយថា ទឹកដោះគោអស់ហើយ ហើយខ្ញុំត្រូវតែរកបបរជំនួសវិញ។ ពេលខ្ញុំមកដល់ផ្ទះរកបានសម្ល កូនរបស់ខ្ញុំបានស្លាប់បាត់ទៅហើយ។

កូនរបស់ខ្ញុំពីរនាក់ទៀត រស់នៅឆ្ងាយពីខ្ញុំត្រូវបានចោទប្រកាន់ថាជាកូនរបស់ជនក្បត់។ នៅពេលដែលកូនៗសួរថាហេតុអ្វីឪពុករបស់ខ្លួនជាជនក្បត់? ខ្ញុំបានយកក្រមារុំមាត់ខ្ញុំ ដូច្នេះខ្ញុំយំមិនឮសំឡេងខ្លាំងឡើយ។ ប្រសិនបើអង្គការឮយើងយំ អង្គការនឹងសម្លាប់យើងទាំងអស់គ្នា។ ខ្ញុំមានបារីពីរកញ្ចប់ ហើយបានឲ្យបារីទាំងអស់នោះទៅបុរសម្នាក់ឈ្មោះពូ សុខ ដើម្បីយកព័ត៌មានអំពីប្តីរបស់ខ្ញុំ។ គាត់និយាយថា គាត់បានឃើញ វ៉ា នៅក្នុងមន្ទីរសន្តិសុខហើយ វ៉ា ស្គមខ្លាំងណាស់។ ខ្ញុំមិនដឹងថា ពូសុខ និយាយពិតឬមិនពិតនោះទេ។

ក្រោយមកអង្គការបានផ្ទេរប្រពន្ធរបស់បុរសៗ ដែលបានបញ្ជូនទៅឆ្ងាយ ឲ្យទៅធ្វើការនៅភូមិមួយនៅខេត្តកំពង់ស្ពឺ ជាទីកន្លែងដែលកូនទីពីររបស់ខ្ញុំស្លាប់។ អង្គការបានអនុញ្ញាតឲ្យខ្ញុំយកនាងទៅមន្ទីរពេទ្យ។ នៅពេលដែលគ្រូពេទ្យបានឃើញកូនស្រីខ្ញុំបើកភ្នែក គាត់និយាយថានាងជាទេ ហើយមិនបានព្យាបាលឲ្យនាងឡើយ។ នាងបានស្លាប់ទាំងបើកភ្នែក ហើយពេទ្យបានបន្ទោសខ្ញុំ ដោយនិយាយថា ខ្ញុំមិនបានប្រាប់ដល់ពេទ្យ។

នៅពេលដែលមានការបាញ់កាំភ្លើងចាប់ផ្តើមនៅដើមឆ្នាំ១៩៧៩ ប្រធានៗខ្មែរក្រហមបានរត់ទៅតាមទិសដៅផ្សេងៗ ហើយបានត្រឡប់ចូលភូមិវិញ មកប្រមូលយកអង្ករមួយចំនួនទៅហូបនៅតាមផ្លូវ។ ប្រជាជនបានប្រាប់ខ្ញុំមិនឲ្យស្នាក់នៅទីនោះទេ ព្រោះយោធាខ្មែរក្រហមនឹងត្រឡប់មករកស្បៀងវិញ ហើយអាចសម្លាប់យើង។ ដូច្នេះខ្ញុំបានធ្វើដំណើរទៅភ្នំពេញ ដោយបានសម្រាកនៅទីនោះមួយរយៈពេលខ្លី។ នៅទីបំផុត យើងបានត្រឡប់ទៅក្រុងកំពង់សោមវិញ។ នៅទីនោះយើងមានជីវិត។

នៅឆ្នាំ១៩៨២ ខ្ញុំបានទៅសណ្ឋាគារ ជាទីកន្លែងដែលប្តីខ្ញុំធ្លាប់ធ្វើការ។ នៅទីនោះខ្ញុំ ឃើញសណ្ឋាគារបាក់បែក ទ្រុឌទ្រោម បានធ្វើឲ្យខ្ញុំនឹកប្តីរបស់ខ្ញុំយ៉ាងខ្លាំង។ គាត់បានស្លាប់ព្រោះដំឡូងពីរបីដុំ។

**ប៉ាង ពីច័ន្ទ និង ទេនី ខកម្ហៀល**

## «ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ទន់ ឈុំ ៖ វេជ្ជបណ្ឌិត

ខ្ញុំបានចេញពីគ្រួសារក្រីក្រមួយនៅក្នុងខេត្តតាកែវ និងបានរៀនសូត្រជាមួយបងប្រុសច្បងបង្អស់របស់ខ្ញុំជាលោកសង្ឃមួយអង្គ។ នៅក្នុងតំបន់ខ្ញុំមិនមានសាលារៀនច្រើនទេដូច្នេះខ្ញុំបានរៀននៅវត្ត។ នៅឆ្នាំ១៩៥៩ ខ្ញុំបានចាប់ផ្តើមរៀននៅសាលារៀនមួយ ប៉ុន្តែវានៅឆ្ងាយពីផ្ទះរបស់ខ្ញុំ ដូច្នេះខ្ញុំបានជួលកន្លែងស្នាក់នៅមួយនៅក្នុងក្រុង។ មួយដងក្នុងមួយអាទិត្យខ្ញុំបានទៅផ្ទះ ហើយបានយកអង្ករ និងស្បៀងអាហារផ្សេងៗត្រឡប់មកវិញ។

នៅឆ្នាំ១៩៦២ ខ្ញុំបានប្រឡងជាប់សញ្ញាបត្រទុតិយភូមិ ហើយមួយឆ្នាំក្រោយមកខ្ញុំបានដាក់ពាក្យប្រឡងចូលរៀនសាលាវេជ្ជសាស្ត្រ។ ដំបូង ខ្ញុំបានដាក់ពាក្យប្រឡងច្រើនមុខជំនាញដែរ ប៉ុន្តែខ្ញុំបានប្រឡងជាប់វេជ្ជសាស្ត្រ។ រៀនផ្នែកវេជ្ជសាស្ត្រគឺពិបាករកការងារធ្វើ។ បន្ទាប់ពីខ្ញុំរៀនចប់ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្រសួងសុខាភិបាលសាធារណៈ នៅខេត្តកំពត។

នៅឆ្នាំ១៩៦៥ ខ្ញុំបានរៀបការជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ ហេង សាវ៉ាង។ យើងបានចំណាយពេលពីរឆ្នាំនៅកំពត បន្ទាប់មក ខ្ញុំត្រូវបានផ្ទេរទៅមន្ទីរពេទ្យមួយនៅក្រុងភ្នំពេញ។ នៅទីនោះខ្ញុំបានអប់រំប្រជាជនអំពីបញ្ហាសុខភាព និងចែកចាយស្បៀងអាហារដល់ក្មេងៗដែលខ្វះជីវជាតិ ឬវីតាមីន។



ទន់ ឈុំ និងគ្រួសាររបស់គាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទោះបីយ៉ាងណា ខ្ញុំរកបានប្រាក់ចំណូលច្រើននៅទីក្រុង គឺច្រើនជាងពេលដែលខ្ញុំនៅជនបទ។ តម្លៃប្រាក់រៀលបានធ្លាក់ចុះថោកជាខ្លាំងនៅប្រទេសកម្ពុជា នៅក្នុងអំឡុងឆ្នាំ១៩៧០ ហើយតម្លៃមាសបានឡើងថ្លៃទ្វេជាពីរ។ ដូច្នេះយើងមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ទិញទំនិញ។ យើងបានរស់នៅជាមួយម្តាយក្មេករបស់ខ្ញុំនៅខេត្តកណ្តាល ហើយខ្ញុំបានបើករថយន្តទៅធ្វើការរាល់ថ្ងៃ។ ខ្ញុំបានរកប្រាក់ចំណូលបន្ថែមដោយដើរពិនិត្យ និងព្យាបាលអ្នកជំងឺនៅតាមផ្ទះ។

នៅពេលដែលយោធាខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុង ខ្ញុំមិនបានយករថយន្តរបស់ខ្ញុំទៅទេ។





យើងប្រញាប់ប្រញាប់ពេក ហើយបានវេចខ្ចប់យកតែរបស់របរសំខាន់ ដូចជាខោអាវ អង្ករ និងម្ហូបគ្រៀមប៉ុណ្ណោះ។ ពេលយើងទៅដល់ខេត្តកំពង់ស្ពឺ ប្រជាជនមូលដ្ឋានបានយករទេះគោមកទទួលប្រជាជនទីក្រុង។ អង្គការបានឲ្យយើងឈរជាជួរ សួរយើងអំពីអតីតភាព ហើយបានដកហូតយករបស់របរប្រើប្រាស់ផ្ទាល់ខ្លួនទាំងអស់ដែលយកមកពីទីក្រុង ហើយឲ្យរបស់ទាំងនោះទៅសហករណ៍។ បន្ទាប់មកខ្មែរក្រហមបានឲ្យខោអាវខ្មៅមកយើងសម្រាប់ស្លៀកពាក់។

កម្មាភិបាលបានសួរខ្ញុំថា "អ្នកឯងអាចធ្វើអ្វីបាន?"។ ខ្ញុំបានឆ្លើយថា "ខ្ញុំអាចធ្វើការងារប្រើកម្លាំងបានទាំងអស់"។ ខ្ញុំអាចខាត់ឈើឲ្យរលោងសម្រាប់ធ្វើកីតម្បាញ ព្រោះអីខ្ញុំបានធ្វើកិច្ចការនេះជាមួយឪពុកម្តាយរបស់ខ្ញុំនៅស្រុកជនបទ។ លើកដំបូងអង្គការបានស្នើខ្ញុំឲ្យធ្វើត្បាល់កិនតូចៗ សម្រាប់កិនស្រូវ បន្ទាប់មកខ្មែរក្រហមបានបញ្ជូលខ្ញុំទៅក្នុងសហករណ៍មួយដែលធ្វើកីតម្បាញ។ ក្រោយមកខ្មែរក្រហមបានសង្ស័យលើរូបខ្ញុំ ហើយបានសួរខ្ញុំម្តងទៀតអំពីជីវប្រវត្តិរបស់ខ្ញុំ។ ខ្ញុំបានប្រាប់ខ្មែរក្រហមនោះថា ខ្ញុំគឺជាជាងឈើនៅមន្ទីរពេទ្យមួយ។ ដូច្នេះ បន្ទាប់មកខ្មែរក្រហមបានឲ្យខ្ញុំសង់រហាត់ទឹក កីតម្បាញ និងត្បាល់ស្រែ។

កូនទីមួយរបស់ខ្ញុំបានស្លាប់ដោយសារកង្វះអាហារ និងថ្នាំពេទ្យព្យាបាលនៅចុងឆ្នាំ១៩៧៥។ ខ្ញុំដឹងត្រូវព្យាបាលជំងឺរបស់វាយ៉ាងម៉េច ប៉ុន្តែមិនមានថ្នាំពេទ្យគ្រប់គ្រាន់។ កូនខ្ញុំត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ប៉ុន្តែគិលានុបដ្ឋាយិកាខ្មែរក្រហមមិនបានព្យាបាលវាល្អឡើយ ហើយវាក៏ស្លាប់នៅទីនោះ។

យើងដាំបន្លែបានច្រើននៅជុំវិញផ្ទះរបស់យើង។ នៅពេលដែលខ្ញុំមិននៅផ្ទះ ប្រពន្ធខ្ញុំបានលួចបេះផ្លែល្ពៅរបស់យើងមួយផ្លែ ដើម្បីធ្វើសម្លសម្រាប់កូនៗរបស់យើង។ កម្មាភិបាលបានឃើញនាងហើយ បានយកនាងនិងកូនៗទៅមន្ទីរឃុំជាទីកន្លែងដែលឈ្លបចោទនាងថាបានលួចស្បៀងអាហាររបស់សហករណ៍។ ខ្ញុំក៏បានធ្វើឲ្យមានកំហុសមួយដែរ នៅពេលខ្ញុំបានលួចដំឡូងខ្លះហូប។ ខ្ញុំកំពុងស្ងោរដំឡូងនៅពេលដែលកងឈ្លបមកដល់។ ឈ្លបម្នាក់នោះបានទាត់ធាក់ខ្ញុំ ហើយចងដៃខ្ញុំទាំងពីរក្រពាត់ទៅក្រោយខ្នង។ ឈ្លបបានឃុំខ្ញុំនៅក្នុងមន្ទីរឃុំ ប៉ុន្តែបានដោះលែងខ្ញុំមួយថ្ងៃក្រោយមក នៅពេលដែលប្រជាជនម្នាក់ដែលជាអ្នកជិតខាងរបស់យើងបានអង្វរឈ្លបឲ្យលើកលែងទោសដល់ខ្ញុំ។ ប្រពន្ធខ្ញុំ និងកូនៗត្រូវបានដោះលែងដែរ។

នៅខែតុលា ឆ្នាំ១៩៧៥ អង្គការបានផ្លាស់ទីលំនៅប្រជាជនជាច្រើននៅក្នុងភូមិរបស់ខ្ញុំឲ្យទៅខេត្តពោធិ៍សាត់។ យើងជិះរថយន្តច្រើនគ្រឿង ដែលបើកយ៉ាងលឿននៅតាមផ្លូវ។ រាល់ពេលដែលអ្នកបើកបរម្នាក់ក្នុងចំណោមអ្នកបើកបរច្រើននាក់ ជាន់ហ្វ្រាំង ប្រជាជនបានធ្លាក់ចេញពីរថយន្ត ហើយបានស្លាប់។ ឪពុករបស់ខ្ញុំនិងប្អូនប្រុសឈ្មោះ ឆាន់ បានជម្លៀសទៅពោធិ៍សាត់ដែរ។ យើងបានជួបគ្នានៅទីនោះ ហើយបន្ទាប់មកយើងបានទៅខេត្តបាត់ដំបងជាមួយគ្នា។

នៅពេលដែលយើងទៅដល់ត្រាក់ទ័រច្រើនគ្រឿងបានរង់ចាំយើង។ លក្ខខណ្ឌរស់នៅរបស់យើងបានប្រសើរនៅខេត្តបាត់ដំបង ព្រោះអីយើងអាចរកបន្លែផ្ទាល់ខ្លួនសម្រាប់ហូប ហើយអង្គការនៅទីនោះមិនតឹងរ៉ឹងឡើយ។ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅកាប់ដើមឈើនៅក្នុងព្រៃស្រោង។ ក្មួយរបស់ខ្ញុំបានទៅជាមួយខ្ញុំដែរ។ ថ្ងៃមួយវាមិនបានទៅធ្វើការ ព្រោះអីវាមានជំងឺគ្រុនចាញ់។ អង្គការបានយកវាទៅសម្លាប់។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យធ្វើការជាគ្រូផ្សំថ្នាំបុរាណ និងដុតសាកសពប្រជាជន។ ខ្ញុំបានទៅព្រៃជ្រៅដើម្បីរករុក្ខជាតិសម្រាប់យកទៅផ្សំធ្វើថ្នាំ ហើយបានឃើញសាកសពជាច្រើននៅទីនោះ។ ខ្ញុំបានដុតសាកសពបីដងក្នុងមួយថ្ងៃ ប៉ុន្តែពេលខ្លះខ្ញុំមិនអាចរកអុសដុតគ្រប់គ្រាន់ ហើយបានកប់សាកសពទាំងនោះជំនួសវិញ។

ថ្ងៃមួយ ខ្មែរក្រហមបានហៅខ្ញុំនិងប្អូនថ្លៃប្រុសរបស់ខ្ញុំទៅកប់សាកសពប្រជាជន២១នាក់។ ប៉ុន្តែប្រជាជនទាំងនោះមិនទាន់ត្រូវបានសម្លាប់នៅឡើយ។ ប្រជាជនទាំងនោះកំពុងតែកាប់រំលំដើមឈើនៅក្នុងព្រៃស្រោង។ នៅពេលដែលយើងទៅដល់ ខ្ញុំបានព្រួអ្នកទាំងនោះខ្សឹបខ្សៀវថា ឆាប់ៗនេះនឹងមានទាហានវៀតណាមជាច្រើនមករំដោះយើង។ ប្រជាជន២១នាក់នោះបានរកឃើញវិទ្យុមួយនៅក្នុងព្រៃ ហើយបានបើកស្តាប់វា។ មួយស្របក់ក្រោយមកយោធាបានកាត់ក្បាលប្រជាជនទាំងនោះ ហើយប្អូនខ្ញុំ និងខ្ញុំបានកប់សាកសពគេនៅក្នុងរណ្តៅសពរាក់មួយ។

ប៉ាង ពីច័ន្ទ និង ទេនី ខករហ្គៀល

«ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ទេព គីមទ្រី ៖ គិលានុបដ្ឋាយិកា

**ប្រពន្ធរបស់គាត់ ទេព ស៊ុយអៀង បាន និយាយរៀបរាប់ប្រាប់ថា៖**

ខ្ញុំបានស្រឡាញ់ការរៀនសូត្រ នៅពេលដែលខ្ញុំនៅវ័យក្មេង ប៉ុន្តែឪពុកម្តាយរបស់ខ្ញុំចង់ឲ្យខ្ញុំរៀបការ។ ទោះជាខ្ញុំបានពរពោះ ខ្ញុំនៅតែបន្តរៀនសូត្រទាល់តែពោះខ្ញុំរីកធំ។ បន្ទាប់មកឪពុកម្តាយរបស់ខ្ញុំបានឲ្យខ្ញុំធ្វើជាអ្នកគ្រប់គ្រងអាជីវកម្មមួយដែលមានស៊ីក្លូឲ្យអ្នកជួល។ ប្តីរបស់ខ្ញុំឈ្មោះ ទេព គីមទ្រី ជាគិលានុបដ្ឋាយិកានៅមន្ទីរពេទ្យមួយនៅក្នុងទីក្រុងភ្នំពេញ។ យើងមិនដែលបានជួបគ្នារហូតដល់ថ្ងៃយើងភ្ជាប់ពាក្យ។ ខ្ញុំមិនសប្បាយចិត្តឡើយ ហើយបានព្យាយាមជៀសវាងជួបគាត់ដែលបានធ្វើឲ្យ ទ្រី សង្ស័យថា ខ្ញុំមានមិត្តប្រុស។ នៅពេលនោះ ខ្ញុំមិនទាន់បានដឹងអំពីអត្ថន័យស្នេហាឡើយ។ យើងបានរៀបការនៅឆ្នាំ១៩៧៣។



ទេព គីមទ្រី និង ទេព ស៊ុយអៀង មួយខែបន្ទាប់ពីពិធីមង្គលការរបស់ពួកគេ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិធីជប់លៀងមង្គលការបានបញ្ចប់នៅម៉ោង៨យប់។ នៅពេលវេលាចូលគេង ទ្រីនិងខ្ញុំ បានសន្ទនាជាមួយគ្នាយ៉ាងយូរ។ នេះជាពេលដែលយើងត្រូវស្គាល់គ្នាយ៉ាងម៉េច។ នៅមុនថ្ងៃពិធីមង្គលការខ្ញុំបានហៅគាត់ថា "លោកគ្រូ ពេទ្យ" ប៉ុន្តែឆាប់ៗមកយើងបានចាប់ផ្តើមហៅគ្នាយ៉ាងផ្អែមល្ហែម "បងសម្លាញ់ អូនសម្លាញ់"។ មួយឆ្នាំក្រោយមក ខ្ញុំបង្កើតបានកូនប្រុសមួយដែលមានស្បែកស្អាត ហើយដូចទៅនឹងឪពុករបស់គេ។ វាបានស្លាប់ដោយសារជំងឺគ្រុនក្តៅ នៅពេលដែលវាមានអាយុបីខែ។ ទ្រី និងខ្ញុំស្ទើរតែរំលងបេះដូង។

ឪពុករបស់ខ្ញុំឈ្មោះ ស៊ាម ស៊ុក ប៉ុន្តែខ្ញុំហៅគាត់ថា ប៉េ ។ គាត់ស្រឡាញ់ខ្ញុំខ្លាំងណាស់ ប៉ុន្តែគាត់ក៏ស្រឡាញ់ប្រាក់ដែរ។ នៅពេលដែលយើងកំពុងជម្លៀសចេញពីទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ គាត់មិនបានចាកចេញទៅជាមួយគ្រួសារទេ គឺគាត់បានស្នាក់នៅក្រោយគេ ដើម្បីមើលថែរក្សាប្រាក់របស់គាត់។ គាត់បានជឿខ្មែរក្រហម នៅពេលខ្មែរក្រហមនិយាយថាអ្នករាល់គ្នាអាចត្រឡប់ចូលក្រុងវិញក្នុងពេលបីថ្ងៃ ដូច្នេះគាត់បានពួននៅក្នុងផ្ទះទាល់តែយោធាខ្មែរក្រហមបង្ខំគាត់ឲ្យចេញ។ គាត់បានចាប់ផ្តើមរកយើងជាច្រើនថ្ងៃ បន្ទាប់ពីអ្នកទាំងអស់គ្នានៃគ្រួសារយើងបានចាកចេញពីទីក្រុង។ សាច់ញាតិរបស់យើងខ្លះបានយកថង់ប្រាក់ជាច្រើនមកតាមខ្លួន នៅពេលដែលពួកគេបានចាកចេញពីភ្នំពេញ ប៉ុន្តែឪពុកខ្ញុំយកបានស៊ីក្លូមួយគ្រឿង។ មានរបស់របរជាច្រើនបានដាក់លើស៊ីក្លូ ហើយយើងបានដោះដូររបស់ទាំងនោះយកអង្ករ។ យើងមានអង្ករគ្រប់គ្រាន់សម្រាប់រយៈពេលខ្លី។

ប៉េ មានជំងឺយូរមកហើយ ដែលធ្វើឲ្យជើងគាត់ហើម ដូច្នេះគាត់មិនអាចដើរបានឆ្ងាយ។ បន្ទាប់ពីគាត់បានជួបជុំគ្រួសារយើង ជើងរបស់គាត់បានវិវត្តទៅជាដំបៅក្លាយ និងឈឺចាប់ជាខ្លាំង។ គាត់បានសុំខ្ញុំឲ្យកាត់ជើងគាត់ចោល។ នៅលើកដំបូង ខ្ញុំបានរួញរា ព្រោះអីខ្ញុំខ្លាចវានឹងនាំមកនូវសំណាងអាក្រក់។ ម្តាយរបស់ខ្ញុំឈ្មោះ វីល កាក់គីម ក៏បានបដិសេធដែរនូវការសុំរបស់គាត់ ហើយបានប្រាប់គាត់ថា សំណាងរបស់ខ្ញុំនឹងអាក្រក់ប្រសិនជាគាត់ឲ្យខ្ញុំធ្វើរឿងនេះ។ ប៉ុន្តែ ប៉េបានអង្វរខ្ញុំឲ្យកាត់ជើងគាត់ គាត់និយាយថាវានឹងធ្វើឲ្យខ្ញុំទៅជាកូនស្រីវិសេសម្នាក់ ហើយខ្ញុំនឹងអាចធ្វើអ្វីបានទាំងអស់នៅអនាគត។ ខ្ញុំបានសម្រេចចិត្តជាចុងក្រោយកាត់កជើងឪពុកខ្ញុំនៅកណ្តាលវាល។ ខ្ញុំបានពរពោះនៅពេលនោះ ហើយកូនរបស់ខ្ញុំបានកើតមកយឺត។

ឪពុករបស់ខ្ញុំបានស្លាប់នៅឆ្នាំ ១៩៧៦ ដោយសារកង្វះខាតស្បៀងអាហារ។ ខ្ញុំបានរស់នៅក្នុងភូមិមួយផ្សេងទៀត ហើយបានមកមើលគាត់នៅមុនពេលគាត់ស្លាប់។ យើងមិនមានបន្ទះក្តារគ្រប់គ្រាន់ធ្វើក្តាមឈូសសម្រាប់គាត់ទេ ហើយអង្គការក៏មិនអនុញ្ញាតឲ្យពូនដីនៅលើផ្នូររបស់គាត់ដែរ ព្រោះអង្គការត្រូវការដីសម្រាប់ដាំស្រូវ។ ប៉ុន្តែ អង្គការបានអនុញ្ញាតឲ្យយើងកាប់ឫស្សី មកក្រង ដើម្បីរុំសាកសព បន្ទាប់មកយកទៅកប់នៅក្នុងវាលស្រែ។

ខ្ញុំបានពរពោះម្តងទៀត។ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅវាលស្រែ។ នៅពេលនោះហ្វូងកណ្តុរបានបំផ្លាញស្រូវអស់មួយភាគធំ ដូច្នេះខ្ញុំត្រូវបានប្រាប់ឲ្យចាប់កណ្តុរទាំងនោះ។ ប្រធានកងរបស់ខ្ញុំបានខឹងខ្ញុំជាខ្លាំង ព្រោះអីខ្ញុំខ្លាចកណ្តុរ និងមិនអាចចាប់បានកណ្តុរមួយឡើយ។ ប្តីខ្ញុំបានដឹងរឿងនេះ ដូច្នេះគាត់ដាក់អន្ទាក់បានកណ្តុរខ្លះ ហើយលាក់កណ្តុរនោះទុកនៅវាលស្រែ។ បន្ទាប់មកគាត់បានឲ្យសញ្ញាសម្គាល់ដល់ខ្ញុំ អញ្ចឹងខ្ញុំអាចរកកណ្តុរទាំងនោះឃើញ។ ខ្ញុំបានដើរជុំវិញជាមួយកណ្តុរ ហើយអ្នករាល់គ្នាគិតថាខ្ញុំចាប់បានកណ្តុរទាំងនោះ។ ខ្ញុំក៏ខ្លាចខ្មោចលងដែរ ប៉ុន្តែដោយសារយើងស្រេកឃ្លាន ខ្ញុំបានដើរទៅបឹងម្នាក់ឯងនៅពេលយប់ ដើម្បីទៅរាវខ្ចង ចាប់ក្តាម និងដកព្រលិត។ កូនទីបីរបស់ខ្ញុំឈ្មោះ ភីរម្យ បានកើតនៅពេលប្រទេសមិនមានថ្នាំពេទ្យគ្រប់គ្រាន់ ឬគិលានុបដ្ឋាយិកា ហើយវាបានឈឺជារឿយៗ។ ទោះជាវាមានអាយុដល់បីឆ្នាំ ភីរម្យ នៅតែមិនអាចដើរបាន។




ទេព ស៊ុយអៀង ខាងស្តាំ ជាមួយបងស្រីនិងក្មួយ។ ថតនៅមជ្ឈមណ្ឌលតាំងទីលំនៅ ឈុនបុរី ប្រទេសថៃ ឆ្នាំ១៩៨០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលមួយ ខ្ញុំបានពុលដោយសារដំឡូងខ្ញុំហូបនៅពេលអាហារថ្ងៃត្រង់។ ខ្ញុំបានសុំមិត្តខ្ញុំម្នាក់កោសខ្យល់ឲ្យខ្ញុំ ប៉ុន្តែវាមិនបានជួយខ្ញុំឲ្យបានធូរស្បើយឡើយ។ បន្ទាប់មកមិត្តខ្ញុំបានយកខ្ញុំទៅមន្ទីរពេទ្យជាទីដែលកម្មា-ភិបាលឈ្មោះ រិន ឲ្យខ្ញុំផឹកទឹកអ៊ីម៉្យាង។ បន្ទាប់ពីចូលក្នុងមាត់ភ្លាម ខ្ញុំស្រែកថាវាជាប្រេងកាត។ កម្មាភិបាល រិន បានស្រែកតបវិញថា វាជាថ្នាំពេទ្យ ប៉ុន្តែបន្ទាប់មកវាជាក្លិនប្រេងកាត។ នាងបានឆែកដបនោះមើល។ ជាចុងក្រោយ នាងបានដឹងថាខ្ញុំមិនបាននិយាយកុហក។ នាងនិយាយថាមានអ្នកណាម្នាក់បានដាក់ដបប្រេងកាតនៅជិតដៃនាង។

នៅអំឡុងចូលឆ្នាំខ្មែរ នៅឆ្នាំ ១៩៧៧ អង្គការបានឲ្យអ្នកភូមិទាំងអស់ឈប់សម្រាកបីថ្ងៃ ពីការងារនៅវាលស្រែ។ បងប្រុសរបស់ខ្ញុំឈ្មោះ

កៀង ធ្លាប់ធ្វើជាគ្រូបង្រៀននៅក្រុងភ្នំពេញ បានត្រឡប់មកផ្ទះជាមួយប្តីខ្ញុំ ហើយបានលេងបាល់ទាត់។ កៀងបានលេងឈ្នះ ដែលធ្វើឲ្យគណៈភូមិចង់ដឹងច្រើនអំពីប្រវត្តិរូបរបស់គាត់។ អង្គការបានបញ្ជូន កៀង និងអតីតគ្រូបង្រៀនពីរនាក់ផ្សេងទៀតទៅដឹកជញ្ជូនខ្សាច់នៅក្នុងភូមិមួយទៀត។ ការបាត់ខ្លួនបងប្រុស ខ្ញុំបានធ្វើឲ្យម្តាយខ្ញុំគាំងបេះដូង។ បន្ទាប់មកមានការបាត់ខ្លួនប្រជាជនជាបន្តទៀត ដូច្នេះបានធ្វើឲ្យខ្ញុំបារម្ភអំពីប្តីរបស់ខ្ញុំ។ ប្រជាជននៅក្នុងភូមិបានដឹងថាប្តីខ្ញុំធ្លាប់ធ្វើជាគិលានុបដ្ឋាយិកា។

នៅយប់មួយ នៅអំឡុងរដូវស្ទូង ប្តីខ្ញុំមិនបានមកផ្ទះទេ ទោះប្រជាជននៅកងបានត្រឡប់មកវិញស្ទើរគ្រប់គ្នាក៏ដោយ។ នៅពេលដែលខ្ញុំមកដល់ខ្ទមរបស់យើង ម្តាយខ្ញុំបានយំ និយាយថាប្តីខ្ញុំត្រូវបានចាប់ខ្លួន។ ខ្ញុំបានខ្យល់ចាប់នៅខណៈដែលខ្ញុំបានឮព័ត៌មាននោះ។ នៅពេលដែលខ្ញុំចូលទៅម្តាយខ្ញុំបាននិយាយថា កម្មាភិបាលម្នាក់ឈ្មោះ ផុន បានចងដៃទ្រីក្រពាត់ទៅក្រោយខ្នង ហើយនាំគាត់ចេញទៅតាមទូក។ បន្ទាប់មក ផុន បានមកផ្ទះយើង ដើម្បីរកនាឡិកាដៃរបស់ទ្រី។ ខ្ញុំបានកុហកហើយនិយាយថា ខ្ញុំមិនអាចរកឃើញនាឡិកានោះទេ។

បន្ទាប់ពីបាត់បង់ប្តីខ្ញុំ ខ្ញុំបានបាត់បង់ភាពក្លាហានរបស់ខ្ញុំ។ ម្តាយខ្ញុំបានខឹងនឹងខ្ញុំ ហើយរំឭកខ្ញុំ នូវពាក្យសម្តីរបស់ទ្រី ៖ ខ្ញុំត្រូវតែតស៊ូ និងព្យាយាមប្រសិនបើគាត់មិនបាននៅជាមួយខ្ញុំ។ ពាក្យទាំងនោះបានដាស់តឿនខ្ញុំឲ្យក្រោកឡើង ចាប់ផ្តើមហូបនិងធ្វើការដូចធម្មតា។ បន្ទាប់មកខ្ញុំបានកោរសក់ក្បាល ដែលខ្ញុំអាចបន់ស្រន់ខទិសដល់គាត់។

នៅដើមឆ្នាំ១៩៧៨ ម្តាយខ្ញុំបានធ្លាក់ខ្លួនឈឺធ្ងន់ ដូច្នេះខ្ញុំបានសុំការអនុញ្ញាតពីអង្គការទៅធ្វើការនៅជិតផ្ទះ ដើម្បីមើលថែទាំគាត់។ ម្តាយខ្ញុំមានជំងឺចម្លែកដែលពោះរបស់គាត់បានហើមធំ ដូចស្ត្រីមានទម្ងន់។ គាត់តែងតែមានអារម្មណ៍ឃ្លានជាខ្លាំង។ មួយខែក្រោយមក គាត់បានស្លាប់គួរឲ្យសង្វេគ។

សំឡេងកាំភ្លើងបានឮនៅក្នុងភូមិរបស់យើងនៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាម បានចូលមកដល់យ៉ាងលឿន។ ក្មេងដែលកំពុងធ្វើការនៅទីឆ្ងាយពីឪពុកម្តាយត្រូវបានបញ្ជូនត្រឡប់មកភូមិវិញ។ មន្ទីរពេទ្យបានបិទទ្វារ។ បន្ទាប់មកគណៈភូមិ និងប្រធានកងបានរត់ចេញ ដូច្នេះយុវជន យុវនារីបានត្រឡប់មកផ្ទះវិញ។ ប្រជាជនបានព្យាយាមដណ្តើមយកស្បៀងដែលអាចយកបានពីរោងកិនស្រូវ និងឃ្លាំងជាច្រើន។

បងស្រីបង្អស់របស់ខ្ញុំឈ្មោះ ឆន បានត្រឡប់មកផ្ទះវិញនៅឆ្នាំ១៩៧៩ ដែលខ្ញុំមិនមានព័ត៌មានអ្វីអំពីគាត់ពីរបីឆ្នាំមកហើយ។ ខ្ញុំស្ទើរតែមិនស្គាល់គាត់នៅពេលដែលយើងបានជួបគ្នា។ គាត់ស្គមខ្លាំងណាស់។ គាត់បានរស់រានមានជីវិតដោយសារប្តូរឈ្មោះរបស់គាត់ និងធ្វើការនៅក្នុងកងចល័តជាទីដែលមិនមានអ្នកណាម្នាក់ស្គាល់គាត់។

សព្វថ្ងៃនេះខ្ញុំរស់នៅប្រទេសបារាំង ប៉ុន្តែបេះដូងរបស់ខ្ញុំដក់ជាប់នៅឡើយជាមួយប្តីរបស់ខ្ញុំនៅប្រទេសកម្ពុជា។ នៅពេលណាដែលខ្ញុំហូបត្រយស្តៅលីង ខ្ញុំតែងគិតអំពីគាត់។ ប្តីខ្ញុំបានរំឭកខ្ញុំនៅពេលដែលខ្ញុំពរពោះ ហើយចង់ហូបត្រយស្តៅ។ ប្តីខ្ញុំបានឡើងដើមស្តៅដើម្បីបេះត្រយស្តៅ ពិតណាស់គាត់បានអ្វីដែលខ្ញុំចង់ហូប។

**ប៊ាង ពីច័ន្ទ និង ខេនី ខករហ្គៀល**

## ការបោះពុម្ពផ្សាយរឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

ទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថាប្រជាជនកម្ពុជាគ្រប់រូប និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅ អំពីរឿងរ៉ាវពិតផ្ទាល់ខ្លួនទាក់ទងនឹងរបបខ្មែរក្រហម ហើយមានបំណងផ្សព្វផ្សាយ សូមផ្ញើមកទស្សនាវដ្តីស្វែងរកការពិតតាមអាសយដ្ឋាន ៖ ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥ ឬ (៨៥៥) ៩៩៦ ៧៥០

អ៊ីម៉ែល៖ truthbunthorn.s@dccam.org - គេហទំព័រ៖ www.dccam.org





# ព្រឹត្តិការណ៍ ថ្ងៃ១៥មេសា
## ឧក្រិដ្ឋកម្មមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
## កៅ សំរិទ្ធ (តចប់)

ធ្វើការចោទប្រកាន់ និងចាប់ចង។

### យុទ្ធនាការបោសសម្អាតខ្មាំង

មុននឹងបញ្ជូនឲ្យមកក្តាប់ស្រុកជីក្រែង អង្គការថ្នាក់លើប្រាកដជាដាក់ទិសឲ្យក្រុម**តាសុក**យកការចាប់ចង និងសម្លាប់ជាការងារអាទិភាពក្រោមពាក្យស្លោក**បោសសម្អាតខ្មាំង**។ ក្នុងការប្រជុំនានា ពួកវាតែងលើកឡើងថា ខ្មាំងមាន២ប្រភេទគឺ **ខ្មាំងជាមនុស្ស** និង**ខ្មាំងសតិអារម្មណ៍**។ ខ្មាំងជាមនុស្សគឺ រាល់អ្នកណាដែលធ្លាប់បានឬកំពុងប្រឆាំងនឹងបដិវត្តន៍ អ្នកដែលធ្លាប់ធ្វើការបម្រើរបបចាស់ អ្នកមានមុខមានមាត់ខ្ពស់ក្នុងសង្គម អ្នកមានការអប់រំខ្ពស់រាប់តាំងពីសិស្សវិទ្យាល័យឡើងទៅ អ្នកមានទ្រព្យធនច្រើន។ល។ រួមទាំងសមាជិកគ្រួសាររបស់ពួកគេទាំងអស់ផងដែរ។ ខ្មាំងសតិអារម្មណ៍គឺជាការគិតពីអ្វីៗដែលខុសពីការណែនាំដែលបណ្តាលឲ្យមិនសម្រេចបានតាមទិសអង្គការ ឬមានកំហុសឆ្គងក្នុងពេលបំពេញការងាររួមមានការធ្វើឲ្យបាក់ភ្លៀងនង្គ័ល បាក់ស្លាបព្រាសម្រាប់ហូបបាយជាដើម (ស្លាបព្រាដែលខ្មែរក្រហមស្ម៉ាស៊ីនឡានផលិត មានគុណភាពអន់បំផុត)។ ខ្មាំងទាំងពីរប្រភេទខាងលើនេះហើយ ដែលខ្មែរ



កៅ សំរិទ្ធ

ក្រហមធ្វើការតាមដានស្រាវជ្រាវយកទៅប្រហារទាំងយប់ទាំងថ្ងៃ។

ជាញឹកញយណាស់ដែលខ្ញុំតែងឮពួកកម្មាភិបាលនិយាយក្នុងពេលប្រជុំថា **«នៅសល់តែមួយចំហៀងខ្លួនក៏នៅតែអាចធ្វើបដិវត្តន៍បានដែរ»** បានន័យថា ពួកវាសម្លាប់ទាល់តែអស់មនុស្សរលីងក៏គ្មានបញ្ហា។ **សមមិត្តផេង** ដែលជាកម្មាភិបាលក្នុងជួរម្នាក់បានខ្សឹបប្រាប់អ្នកមីង **គង់ វ៉ាត** នៅភូមិតាភ្វា ពីផែនការសម្ងាត់មួយ គឺអង្គការនឹងទុកតែយុវជនយុវនារីខ្មែរតែមួយចំនួនប៉ុណ្ណោះ ដើម្បីបង្កាត់ជាមួយជនជាតិចិនឲ្យបានជាមនុស្សជំនាន់ថ្មីមួយ (នាឆ្នាំ១៩៧៩ខ្ញុំក៏បានប្រទះអត្ថបទកាសែតមួយអំពីរឿងហ្នឹងដែរ)។

ក្រោយថ្ងៃមហាប្រល័យ១៥មេសា នៅពេលដែលបរិវេណវត្តមិនទាន់បាត់ក្លិនឆ្អាបឈាមជនរងគ្រោះនៅឡើយ មានរថយន្តជាច្រើនគ្រឿងបានមកដល់ ដើម្បីដឹកស្រូវដែលស្តុកក្នុងព្រះវិហារ។ ស្ត្រីៗនៅក្បែរៗវត្តត្រូវបានគេហៅឲ្យទៅកើបស្រូវចេញពីក្នុងព្រះវិហារទៅដាក់ក្នុងឡាន។ បរិមាណស្រូវកាលនោះមានកម្ពស់លិចដងខ្លួនព្រះបដិមាអង្គធំ ហើយត្រូវគេដឹកចេញទាល់តែអស់រលីង។

ក្រោយពីអស់ស្រូវហើយ ព្រះពុទ្ធបដិមាអង្គធំក៏ត្រូវវាយបំផ្លាញ ព្រះវិហារក៏ត្រូវប្រើជាកន្លែងចងអ្នកទោសឃុំឃាំងទុកមុននឹងដឹកឡានចេញទៅសៀមរាប (ប្រហែលជាដឹកទៅសម្លាប់នៅភូមិអន្ទ្រង់ ចម្ងាយ១៨គីឡូម៉ែត្រខាងកើតសៀមរាប)។ អ្នកដែលពាក់ព័ន្ធនឹងបាតុកម្មកន្លងមក អ្នករដ្ឋការចាស់ អ្នកដែលពួកវាហៅថា អនុធន (គឺដូចជា គ្រូបង្រៀន ពេទ្យ ជាដើម) ហើយសូម្បីតែសិស្សវិទ្យាល័យចាប់ពីថ្នាក់ទី ៣ ចាស់ (បច្ចុប្បន្នថ្នាក់ទី ១០) គឺត្រូវចាប់ទាំងអស់។ ជារៀងរាល់ថ្ងៃខ្ញុំឃើញឡានកាត់ កាត់ចិនបិទបាំងដោយធាងដូងចូលមកដឹកជនរងគ្រោះទាំងនោះ។

នាយប់មួយ ប្រជាជនដែលរស់នៅក្បែរវត្ត បានឮសំឡេងស្ត្រីជនរងគ្រោះម្នាក់ស្រែកអង្វរថា «ធ្វើអីខ្ញុំក៏ធ្វើចុះតែសូមទុកជីវិតកូនខ្ញុំផង»។ ស្ត្រីនោះអាចជាអតីតគ្រូបង្រៀន ដែលពួកវាចាប់យកមកពីភូមិព្រៃវាំង ប្រហែលជាពួកវារំលោភ រួចសម្លាប់នៅម្តុំទួលគោកខ្មោចខាងកើតវត្ត។

ទន្ទឹមនឹងការចាប់មនុស្សដាក់ឡានធាងដូង ដឹកយកទៅសម្លាប់នៅក្រៅភូមិសាស្ត្រស្រុក ពួកយោធាស្រុកក៏តែងដើរចាប់ចងប្រជាជនតាមភូមិជារៀងរាល់យប់ បណ្តើរយកទៅសម្លាប់នៅកំពង់ក្តីដែរ។ ជារៀងរាល់ម៉ោង៥-៦ល្ងាច ពួកយោធាដែលមានគ្នាពី១៥៣០នាក់ ដើរកាត់វាលស្រែ (ដើម្បីមិនឲ្យប្រជាជនឃើញ) តម្រង់ទៅភូមិនានាជាគោលដៅរបស់វា។ វាតែងនាំគណៈភូមិ និងកងឈ្លបដើរជាមួយដើម្បីផាយស្វែងរកជនរងគ្រោះ។ គណៈភូមិខ្លះ មានចិត្តមេត្តាបានជួយលាក់បាំង និងសង្គ្រោះជីវិតមនុស្សបានជាច្រើន តែខ្លះទៀតដែលមានចិត្តទោសៈ បានរាយការណ៍ប្រាប់ពួកយោធាដោយគ្មានលាក់លៀមដែលធ្វើឲ្យអ្នក១៧មេសាក្នុងភូមិត្រូវស្លាប់ស្ទើរគ្មានសល់។

លោកមា **ព្រំ រី** ដែលរួចជីវិតពីព្រឹត្តិការណ៍ថ្ងៃ១៥មេសា បានក្លាយជាមនុស្សដែលពួកយោធាស្រុកស្គាល់ និងទុកចិត្ត បានធ្វើបញ្ជីឈ្មោះអ្នកភូមិត្រពាំងវែងដាក់ថា ជាអ្នកមូលដ្ឋានចាស់ទាំងអស់ គឺជួយអ្នក១៧មេសាក្នុងទូទាំងភូមិឲ្យបានរួចជីវិត ក្នុងនោះមានទាំងលោកយាយ **ម៉ែម៉ឺន** តារាភាពយន្តដ៏ល្បីល្បាញ និងភរិយាទាំងពីរនាក់របស់លោក **លី វ៉ា** ដែលជាចាងហ្វាងផលិតកម្មភាពយន្តផងដែរ។

លោកតូ **សុខ** ប្រធានភូមិថ្កស្នាប់ ដែលមានផ្ទះទល់មុខនឹងផ្ទះខ្ញុំ ជាប្រធានភូមិចិត្តធម៌ ដែលបានជួយសង្គ្រោះជីវិតខ្ញុំ។ អ្នកមីង **ស៊ាន** ដែលជាប្រពន្ធលោកតូ **សុខ** បាននិយាយដំណាលថា ថ្ងៃមួយនាពាក់កណ្តាលអាធ្រាត្រ មានយោធាអាវខ្មៅ ៣នាក់ បានមកសួរគាត់រកគ្រួសារអ្នក ១៧ មេសា តែលោកតូ **សុខ** ឆ្លើយថាគ្មានទេ។ បើសិនជាពេលនោះ គាត់គ្រាន់តែបូញមាត់តែបន្តិច ជីវិតខ្ញុំប្រាកដជាត្រូវសូន្យបង់ជាមិនខាន។ មានម្តងនោះ លោកតូ **សុខ** ដែលទើបមកពីប្រជុំរឿងផែនការចាប់ចង បានដើរមកប្រាប់ខ្ញុំថា«បើមានគេសួរថារៀនដល់ថ្នាក់ទីប៉ុន្មាន ត្រូវប្រាប់គេថារៀនដល់ថ្នាក់ណាដែលទាបបានហើយ»។

លោកអ៊ំ **ហេង ជុយ** ជាអ្នកមូលដ្ឋានចាស់តែជាប់និន្នាការជាអ្នករដ្ឋការចាស់ក៏ត្រូវគេចាប់ចងដាក់ក្នុងព្រះវិហារដែរ។ ថ្ងៃមួយគាត់បានឃើញបុរសម្នាក់ដែលជាប់ចំណងអង្គុយក្បែរជញ្ជាំង បាននិយាយអង្វរពួកអ្នកយាមឲ្យបន្ធូរចំណងដៃបន្តិច ស្រាប់តែត្រូវពួកវាបាញ់បំបែកក្បាលខ្ទាយខួរនិងឈាមខ្ទាតប្រឡាក់ជញ្ជាំងដែលបន្សល់ទុកស្លាកស្នាមអស់រយៈពេលជាច្រើនឆ្នាំ។ អ៊ំ **ហេង ជុយ** មានសំណាងណាស់ដែលបានអ្នកយាមមានមនោសញ្ចេតនាអាណិត ក៏ស្រាយចំណងឲ្យគាត់ត្រឡប់ទៅផ្ទះវិញ។

ជាទូទៅ ពួកយោធាខ្មែរក្រហមហាក់ដូចជាស្រេកឃ្លានជីវិតមនុស្សណាស់ គឺវាចាប់តាំងពីអ្នកដំណើរដែលវាជួបតាមផ្លូវ។ នាចុងឆ្នាំ១៩៧៧ មានបុរសម្នាក់ឈ្មោះ **អេង ហុក ឡាន** អាយុ ៣១ឆ្នាំ ដែលកំពុងដើររកគោនៅក្នុងភូមិសាស្ត្រ ភូមិពោធិសិរី ខាងកើតកំពង់ក្តី ត្រូវពួកបើកឡានធាងដូងជួប ហើយចាប់ចងបោះដាក់ក្នុងឡានយកទៅបាត់។

យុវជនម្នាក់ទៀតឈ្មោះជា សូវេត អាយុ២៨ឆ្នាំ រស់នៅភូមិក្របីរៀល ជិះកង់ទៅលេងបងប្អូននៅភូមិសង្កែមានជ័យ គាត់ក្បែរសាលាស្រុក ក៏ត្រូវពួកអ្នកយាមចាប់ចងយកទៅប្រហារផងដែរ។

យុវជនឈ្មោះ **សៀវ សុផុន** បានចងចាំនូវហេតុការណ៍ប្រល័យមនុស្សយ៉ាងសាហាវឃោរឃៅមួយ កើតឡើងនៅភូមិអណ្តូងថ្ម សង្កាត់គោកធ្លកក្រោម ស្រុកជីក្រែង តាមបណ្តោយផ្លូវជាតិលេខ៦ មិនឆ្ងាយប៉ុន្មានពីផ្ទះដែលគាត់រស់នៅ។ នាថ្ងៃមួយក្នុងឆ្នាំ១៩៧៧ វេលាល្ងាចម៉ោងជិត ៦ គឺពេលដែលប្រជាជនវិលត្រឡប់មកពីស្ទូងដកមកដល់ផ្ទះវិញ មានឡានកាត់.កាត់មួយគ្រឿងពីកំពង់ក្តី មកចតនៅក្បែរផ្ទះប្រជាជនមូលដ្ឋានចាស់មួយគ្រួសារ។ យោធាអាវខ្មៅ ៣៤ នាក់ចេញពីឡាន ដើរតម្រង់ទៅម្តុំដែលមានអ្នក ១៧មេសារស់នៅចម្ងាយពីរ-បី រយម៉ែត្រពីថ្នល់ជាតិ។ នៅទីនោះមានបុរសចំណាស់ម្នាក់ដែលគេតែងហៅគាត់ថា«តាពេទ្យ» ព្រោះគាត់ធ្វើពេទ្យកាលពីសម័យលន់ នល់។ ពួកអាវខ្មៅហៅគាត់ឲ្យចុះពីលើផ្ទះ ហើយក៏ស្ទុះទៅសំពងក្បាលគាត់នឹងខ្នងពូថៅដួលប្រកាច់ស្លាប់នៅនឹងជណ្តើរផ្ទះតែម្តង។ រួចពីនោះ ពួកវាក្រឡេកទៅឃើញយុវជនម្នាក់ដេកក្នុងអង្រឹងនៅក្រោមផ្ទះ ក៏ចូលទៅវាយ





សម្លាប់ផងដែរ។ យុវជននោះឈ្មោះ តុត ជាកូនទី២ របស់លោកតាពេទ្យ ដែលទើបមកពីធ្វើការនៅកងចល័តនៅអូររូង សង្កាត់ពង្រក្រោម។

បន្ទាប់មក ពួកឃាតករបានដើរតម្រង់ទៅផ្ទះមួយទៀត ក៏ជួបវាក់ជាមួយនារីម្នាក់ឈ្មោះ បុប្ផា ដែលត្រឡប់មកពីយកត្រីទៅអាំងនៅផ្ទះអ្នកជិតខាង។ គាត់ត្រូវពួកឃាតកវាយក្បាលនឹងខ្នងពូថៅ ជ្រុះត្រីពីដៃ របូតសំពត់ចោមពុង ប្រកាច់ស្លាប់យ៉ាងអាណោចអាធ័មបំផុត។ ជាចុងក្រោយនារីម្នាក់ទៀត ក៏ត្រូវពួកវាសម្លាប់ដោយវិធីដដែលដែរ។ ក្រោយពីសម្លាប់អ្នកទាំង៤នាក់ហើយ ពួកពេជ្ឈឃាតក៏បោះពូថៅចោល ហើយដើរត្រឡប់ទៅឡានវិញ និងទៅសុំទឹកអ្នកនៅផ្ទះក្បែរនោះលាងដៃវាដែលប្រឡាក់ឈាមជនរងគ្រោះ រួចក៏បើកត្រឡប់ទៅកំពង់ក្តីវិញ។

ចាប់តាំងពីមានការចោទប្រកាន់កម្មាភិបាលភូមិភាគឧត្តរថាជា «ខ្មាំង» ក្បត់អង្គការបក្ស កម្មាភិបាល មកពីភូមិភាគនិរតី ត្រូវបានបញ្ជូនឲ្យមកក្តាប់ ហើយ**យុទ្ធនាការបោសសម្អាតខ្មាំង**ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ។ កាលពីមុន **មុខសញ្ញាខ្មាំង** មានតែនៅក្នុងចំណោមអ្នក ១៧ មេសាទេ តែលើកនេះ គឺមាននៅក្នុងជួរកម្មាភិបាលជំនាន់មុន រួមទាំង ពួកយោធាដែលត្រូវគេរំសាយពីជួរផងដែរ ហេតុនេះហើយបានជាពេលនោះអ្នកមូលដ្ឋានចាស់មិនសូវរើសអើងអ្នក១៧មេសាដូចកាលមុនទេ។

លោក **ណែម សារី** ដែលជម្លៀសទៅនៅភូមិជាស្នូន់ ឃុំមានជ័យ ស្រុកប្រាសាទបាគង បានរំឭកព្រឹត្តិការណ៍ដ៏សាហាវឃោរឃៅប្រព្រឹត្តដោយពួកកម្មាភិបាល មកពីភូមិភាគនិរតីដែលមានឈ្មោះ **តាហុន** ជាប្រធានគណៈតំបន់ តាំងពីពួកវាមកក្តាប់ភូមិភាគឧត្តរនាចុងឆ្នាំ ១៩៧៦។ កិច្ចការដំបូងរបស់ពួកនោះគឺ ចាប់ខ្លួនពួកកម្មាភិបាលជំនាន់មុន ចាប់ពីថ្នាក់សង្កាត់ឡើងទៅ។ ចំពោះអ្នក១៧ មេសា កាលពីជំនាន់គណៈតំបន់មុន មិនមានបញ្ជាឲ្យចាប់ខ្លួនសិស្ស និស្សិត គ្រូបង្រៀន ពេទ្យ និងបញ្ញវន្តដែលគេហៅជារួមថា វណ្ណៈអនុធនទេ តែនៅជំនាន់គណៈតំបន់ **តាហុន** គឺត្រូវចាប់ខ្លួនទាំងអស់ សូម្បីតែអ្នកធ្លាប់ធ្វើជាកងស៊ីយត្រាណតែមួយថ្ងៃក្តី។ អតីតគ្រូបង្រៀនខ្លះ ត្រូវពួកវាហៅឲ្យចុះពីលើផ្ទះ (ខ្ទម) ហើយបាញ់សម្លាប់នៅនឹងកាំជណ្តើរតែម្តង។

នាដើមឆ្នាំ ១៩៧៧ លោក **ណែម សារី** ត្រូវគេចាត់តាំងឲ្យទៅឡើងត្នោតនៅភូមិកក្រាញ់ប៉ែកខាងត្បូងក្រុងសៀមរាបតាមមាត់ស្ទឹង។ គាត់បានដឹងថា ពួកយោធាខ្មែរក្រហមពិការដោយសង្គ្រាម ដែលគណៈតំបន់មុនរៀបចំការប្រពន្ធ និងរស់នៅម្តុំវត្ត**ស្វាយ** មិនឆ្ងាយប៉ុន្មានពីភូមិកក្រាញ់ ត្រូវគណៈតំបន់ថ្មីបញ្ជាឲ្យយកទៅសម្លាប់ចោលទាំងអស់ ដោយចោលសំដីថា **«ពួកនោះស៊ីបាយអស់បាយ ស៊ីអង្ករអស់អង្ករ»** ។ ទីពិឃាតអ្នកទាំងនោះគឺ នៅក្នុងព្រៃអង្គរ ម្តុំបញ្ចារលក់សំបុត្រទស្សនាប្រាសាទ(ចាស់)។ លោក **ណែម សារី** ជាសាក្សីរស់ដែលបានឃើញរថយន្តដឹកអ្នកភូមិភ្នំក្រោម (ដែលមានរបរនេសាទត្រី) ទៅសម្លាប់មួយថ្ងៃមួយ ឡាន ជូនកាលពីរឡាន អស់រយៈពេលប្រមាណមួយខែ ដែលមនុស្សមួយឡានៗ មានប្រហែលជា៣០ ទៅ ៤០នាក់។

ល្បិចញុះញង់ប្រជាជនឲ្យងើបបះបោរ ហើយធ្វើការបង្ក្រាបក្រោមលេស **«ដើម្បីរកខ្មាំង»** មិនមែនកើតឡើងនៅតែស្រុកជីក្រែងមួយទេគឺមាននៅឃុំកែវពណ៌ស្រុកពួកផងដែរ។ លោក **ណែម សារី** ដដែលបានឲ្យដឹងថា កាលពីដើមឆ្នាំ ១៩៧៧ ប្រជាជនភេទប្រុសក្នុងទូទាំងឃុំកែវពណ៌ស្រុកពួកត្រូវពួកខ្មែរក្រហមចាប់យកទៅសម្លាប់ទាំងអស់ ក្រោមលេសមួយដែលមានដំណើររឿងដូចតទៅ ៖

នាចុងឆ្នាំ១៩៧៦ កម្មាភិបាលមកពីភូមិភាគនិរតីបានមកដល់ ហើយបានដើរបញ្ចុះបញ្ចូលប្រជាជនទូទាំងឃុំឲ្យមានកំហឹង និងងើបបះបោរប្រឆាំងនឹងកម្មាភិបាលថ្នាក់មូលដ្ឋាន។ ពួកវាបានបំពាក់កាំភ្លើងធុនស្រាល និងគ្រាប់បែកដៃមួយចំនួនដល់ប្រជាជន និងជំរុញពួកគាត់ឲ្យទៅវាយប្រហារមូលដ្ឋានទ័ពមួយកន្លែងនៅអាងអន្លង់សារនាមាត់ទន្លេសាប ដើម្បីដណ្តើមយកកាំភ្លើងទៅពង្រីកកម្លាំងបន្ថែមទៀត។ ដោយសារតែកាំភ្លើង និងគ្រាប់បែកដៃទាំងនោះត្រូវពួកវាដោះយកគ្រឿងក្នុងមួយចំនួនចេញបាត់ទៅហើយ បានជាក្នុងពេលប្រយុទ្ធគ្នានោះ ក្រុមបះបោរគ្មានបាញ់ចេញមួយគ្រាប់ណាទេ ឯគ្រាប់បែកក៏សុទ្ធតែស្អុយ ធ្វើឲ្យគ្នាគាត់ទាំង៣០-៤០នាក់ត្រូវពួកវាចាប់បានទាំងអស់ ហើយសម្លាប់ចោលគ្មានសល់ម្នាក់។ ដោយយកហេតុការណ៍នោះធ្វើជាលេស ពួកអាវខ្មៅក៏ធ្វើការចាប់ខ្លួនប្រជាជនភេទប្រុសតាំងពីក្មេងជំទង់អាយុ ១៥ឆ្នាំ

ឡើងក្នុងឃុំកែវពណ៌ទាំងមូលនិងភូមិខ្លះទៀតក្នុងឃុំផ្សេង ហើយដឹកយកទៅសម្លាប់នៅម្តុំបារាយណ៍ទឹកថ្លា។

លោក **ណែម សាវី** ក៏បានរៀបរាប់នូវរឿងរ៉ាវពិឃាតដ៏រន្ធត់ទាក់ទងនឹងឡានបាំងធាងដូងដែលគាត់បានដឹងពីស្ត្រីម្នាក់ឈ្មោះ រ៉ាត់ ដែលពួកឃាតកអាវខ្មៅបានដោះលែង។ ប្តីអ្នកស្រីធ្លាប់បានធ្វើជាកងស៊័យត្រាណក្នុងជំនាន់លន់ នល់ ហើយត្រូវបានជម្លៀសទៅនៅភូមិជាស្ទន់ក្នុងស្រុកប្រាសាទបាគង។ នៅពេលដែលពួកឈ្លបស្រាវជ្រាវដឹង ទាំងពីរនាក់ប្តីប្រពន្ធត្រូវចាប់ខ្លួនយកទៅវាលពិឃាតនៅភូមិអន្ទ្រង (ផ្សារអន្ទ្រងក្នុងស្រុកប្រាសាទបាគងបច្ចុប្បន្ន) ដែលអ្នករស់នៅភូមិនោះត្រូវបានគេជម្លៀសចេញអស់តាំងពីឆ្នាំ១៩៧៥។ បន្ថែមពីលើមនុស្សដែលពួកវាចាប់មកពីទីជិតៗនោះ អ្នកស្រីបានឃើញឡានបាំងធាងដូងមកពីទិសខាងកើត ពោរពេញទៅដោយមនុស្សជាប់ចំណង ត្រូវពួកអាវខ្មៅនាំយកទៅវាយសម្លាប់ទម្លាក់ចូលក្នុងអណ្តូងលូតាមផ្ទះដែលអ្នកភូមិធ្លាប់តែដងទឹកយកមកប្រើប្រាស់។ គាត់ឮសំឡេងជនជាប់ចំណងស្រែកអង្វរករសុំឲ្យទុកជីវិត និងសម្រែកឈឺចាប់ដោយសារដៃជាប់ចំណងស្ទាក់ខ្យល់រាប់ម៉ោង។ នៅរាល់ពេលដែលជនរងគ្រោះម្នាក់ៗត្រូវពួកវាសម្លាប់ គាត់ឮសូរសំឡេងវាយសំពងភូស និងសម្រែកអួយយ៉ាងអាណោចអធ័មជាទីបំផុត។ ប្តីរបស់អ្នកស្រីក៏ត្រូវបានសម្លាប់នៅពេលនោះដែរ។ ប្រហែលដោយសារតែគាត់ជាស្ត្រីតែម្នាក់គត់នៅទីពិឃាតនោះ ទើបមេឃាតករសម្រេចដោះលែងឲ្យវិលត្រឡប់ទៅផ្ទះវិញ។ នោះជាសំណាងតែមួយក្នុងរាប់ពាន់គ្រោះថ្នាក់របស់គាត់។

ថ្ងៃមួយនាដើមឆ្នាំ១៩៧៧ លោក **ណែម សាវី** បររទេះគោកាត់តាមទីពិឃាត នោះក៏បានឃើញក្បាលជនរងគ្រោះ៤៥ ត្រូវពួកពេជ្ឈឃាតដោតតម្រៀបគ្នាលើបង្គោលរបងធ្វើជាល្បែងកម្សាន្ត។

## ខាលពិឃាតនាពេលបច្ចុប្បន្ន

### ១. វាលពិឃាតភូមិត្រពាំងវែង

អស់រយៈពេល៤៣ឆ្នាំ កន្លងមកនេះ វាលពិឃាតដែលពីមុន គឺជាស្រែដែលមានគុម្ពោតព្រៃរបោះ មានសណ្ឋានខ្ពស់ទាប បានផ្លាស់ប្តូរទៅជាវាលស្រែរាបស្មើ ដែលមានតែដើមឈើខ្លះៗប៉ុណ្ណោះ។ ស្ពានឈើទី២ដែលជាទីកន្លែងចាប់ចង និងប្រហារជនរងគ្រោះខ្លះនាពេលនោះ ក្រោយមកត្រូវប្រជាជនហៅថា **ស្ពានអារ.ក** ។ នៅឆ្នាំ១៩៩៨ នៅពេលមានការជួសជុលផ្លូវ ស្ពានត្រូវគេរុះរើចោលហើយចាក់ដីលុបបំពេញ ដែលបច្ចុប្បន្នគ្រាន់តែជាផ្លូវថ្នល់ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តីឈ្មោះស្ពានអារ.ក នៅតែត្រូវបានប្រជាជនប្រើសម្រាប់ហៅទីតាំងម្តុំនោះ។ ស្លាកស្នាមប្រវត្តិសាស្ត្រដ៏ជូរចត់បានរលុបបាត់ហើយ នៅឡើយតែភាពតក់ស្លុត និងសោកសៅដែលដក់ជាប់ក្នុងអារម្មណ៍របស់អ្នកដែលបាត់បង់មនុស្សជាទីស្រឡាញ់តែប៉ុណ្ណោះ។

### ២. វាលពិឃាតវត្តគោកធ្លក

ភាគច្រើននៃគ្រួសារជនរងគ្រោះក្នុង**ព្រឹត្តិការណ៍ថ្ងៃ១៥មេសា** មិនបានទៅគាស់យកអដ្ឋិធាតុសមាជិកក្រុមគ្រួសារយកមកទុកដាក់ភ្លាមៗទេ ដោយខ្លាចគណៈភូមិឬពួកឈ្លបចោទប្រកាន់ថា ជាប់ជំពាក់ជាមួយខ្មាំង។ ទាល់តែក្រោយការដួលរលំនៃរបបខ្មែរក្រហមទើបពួកគាត់ស្វះស្វែងរកដោយផ្អែកលើព័ត៌មានពីអ្នកដែលរួចជីវិត ឬអ្នកកប់សាកសព ជាពិសេសគឺសម្លៀកបំពាក់ដែលជនរងគ្រោះស្លៀកនាថ្ងៃនោះ។ អ្នកខ្លះមានសំណាងបានរកឃើញ អ្នកខ្លះទៀតរកមិនឃើញ។

នៅឆ្នាំ១៩៧៩ ព្រះសង្ឃ និងចាស់ៗ អ្នកភូមិដែលរៀបចំកសាងវត្តគោកធ្លកឡើងវិញបាន ដើរប្រមែប្រមូលធាតុជនរងគ្រោះពីតាមរណ្តៅខ្លះ តាមវាលស្រែខ្លះ និងសាងសង់តូបមួយក្បែរព្រះវិហារសម្រាប់ទុកដាក់។ ធាតុមួយចំនួនត្រូវបានដឹកយកទៅទុកនៅ**វត្តពោធិវង្ស**ក្រុងសៀមរាបសល់ប៉ុន្មានត្រូវព្រឹទ្ធាចារ្យម្នាក់ជំរុញយកទៅដាក់នៅគោកខ្មោចក្រៅបរិវេណវត្ត គ្មានការថែទាំជាច្រើនឆ្នាំក៏ត្រូវបាត់បង់អស់គួរឲ្យសោកស្តាយបំផុត។

ដូចគ្នានឹងវាលពិឃាតភូមិត្រពាំងវែងដែរ វត្តគោកធ្លក បច្ចុប្បន្នស្ទើរតែគ្មានបន្សល់ស្លាកស្នាមនៃការប្រល័យអ្វីទេ ក្រៅពីដើមពោធិធំមួយដើមដែលក្រុមរងគ្រោះចុងក្រោយត្រូវពួកពេជ្ឈឃាតយកទៅប្រល័យនៅក្បែរនោះ។ ព្រះវិហារដែលធ្លាប់ជាកន្លែងឃុំឃាំងជនស្លូតត្រង់ក៏ត្រូវរុះរើចោល និងសាងសង់ជាថ្មី។ ព្រឹត្តិការណ៍ថ្ងៃ១៥ មេសា ដ៏ភ័យរន្ធត់មានតែនៅក្នុងការចងចាំរបស់ចាស់ៗមួយចំនួនដែលនៅមានជីវិតនៅឡើយតែប៉ុណ្ណោះ។





### ៣. ការដ្ឋានទំនប់រហាលព្រួល

ទីដែលជាផ្ទះឡើងនូវបាតុកម្មសម្រាប់កម្មាភិបាលខ្មែរក្រហមកាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៧ នោះត្រូវបានគេកសាងបញ្ចប់នៅឆ្នាំ១៩៧៨ ទើបបានជាមានឈ្មោះថាទំនប់ ៧៨ មកដល់សព្វថ្ងៃនេះ។ ក្នុងសម័យខ្មែរក្រហម មន្ទីរសន្តិសុខរហាលព្រួល គឺជាកន្លែងឃុំឃាំង និងជាទីពិឃាតមួយដែរ។ បច្ចុប្បន្ននេះយើងមិនឃើញមានសល់ស្លាកស្នាមទារុណកម្ម ឬប្រល័យអ្វីទាំងអស់ក្រៅតែពីអនុស្សាវរីយ៍ដ៏ខ្លោចផ្សានៃអ្នកដែលធ្លាប់ទៅធ្វើពលកម្មនៅទីនោះតែប៉ុណ្ណោះ។

## ខ្សែជីវិតពួកឃាតក

ប្រហែលជានៅពាក់កណ្តាលឆ្នាំ១៩៧៧ គណៈស្រុក**សុក** បានរំសាយបណ្តាកងយោធាស្រុកពីជំនាន់**តាស៊ុន**ឲ្យទៅនៅមូលដ្ឋាន(ភូមិកំណើត)វិញ។ ក្នុងចំណោមអ្នកទាំងនោះមានទាំងពេជ្ឈឃាតឃី និងធាជងដែរ។ ពួកនោះទៅធ្វើការក្នុងកងចល័តជាមួយប្រជាជនដទៃ រហូតទាល់តែរបបខ្មែរក្រហមដួលរលំនៅ**ថ្ងៃទី ៧ ខែមករាឆ្នាំ ១៩៧៩**។ នាដើមឆ្នាំ១៩៧៩ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា **ឃី** ត្រូវបានគេចាត់តាំងឲ្យធ្វើប្រធានភូមិគោកធ្លក។ ពីរបីឆ្នាំក្រោយមក ឃី ក៏មានជំងឺលើសឈាមស្លាប់មួយចំហៀងខ្លួនធ្វើការលែងកើត។ ជារឿងចៃដន្យបំផុតដែលប្រធានភូមិបន្ទាប់ពី **ឃី** គឺ **ម៉ៅ** ដែលធ្លាប់ជាពេជ្ឈឃាតដៃឆ្វេងម្នាក់ទៀតដែរ សកម្មក្នុងការចាប់ខ្លួនមនុស្សចងស្លាបសេកឲ្យរត់មុខកង់ ជូនកាលសេះ ក្នុងចម្ងាយផ្លូវជាង ១០គីឡូម៉ែត្រ។ អតីតមេភូមិ **ឃី** រស់នៅជាមួយជំងឺលើសឈាមយ៉ាងត្រដាបត្រដួសអស់ជាច្រើនឆ្នាំ និងស្លាប់នៅឆ្នាំ១៩៩២ ក្នុងអាយុ៣៧ឆ្នាំ។ ឯពេជ្ឈឃាត **ធា** (ហៅម៉ែនហែម)វិញ ត្រូវបានប្រធានភូមិឲ្យធ្វើជាគ្រូបង្រៀនតាំងពីឆ្នាំ១៩៧៩ រហូតដល់អាយុចូលនិវត្តន៍។ គាត់ក៏មានជំងឺទុរន់ទុរាអស់ជាច្រើនឆ្នាំដែរ ហើយស្លាប់ប្រមាណជា៥-៦ ឆ្នាំមុននេះ។

**សមមិត្ត ស៊ីម** ជាអ្នកភូមិគោកធ្លក ដែលបានជួយជីវិតមនុស្សមួយចំនួនក្នុងព្រឹត្តិការណ៍ ១៥មេសា នោះក្រោយពីត្រូវ **តាសុក** បោកប្រើរួចហើយក៏ត្រូវចាប់ខ្លួនទាំងប្តីទាំងប្រពន្ធបញ្ជូនទៅដាក់គុកនៅសៀមរាបមួយរយៈមុននឹងយកទៅសម្លាប់ចោល។ លោក **ស៊ុំ រិទ្ធី** ដែលធ្លាប់ជាប់គុកក្នុងបន្ទប់តែមួយជាមួយគ្នា បានរំឭកសម្តី **ស៊ីម** ថា **«បដិវត្តន៍នេះ មិនស្មោះត្រង់ក៏ស្លាប់ ស្មោះត្រង់ក៏នៅតែស្លាប់»** ។ ដោយសារតែធ្លាប់ជាកម្មាភិបាលថ្នាក់ស្រុកម្នាក់ នៅថ្ងៃដែលគេយកគាត់ទៅសម្លាប់ គេរៀបចំអាហារឆ្ងាញ់មួយពេលដោយមានបាយ និងម្ហូបដាក់ក្នុងថាសឲ្យហូប។

ខ្ញុំទទួលបានព័ត៌មាន ២ខុសគ្នាពីខ្សែជីវិតរបស់ **តាសុក** ដែលជាមេឃាតករយ៉ាងសាហាវឃោរឃៅ។ មួយ គឺត្រូវគណៈស្រុកថ្មីចាប់ចងបោះចូលក្នុងឡាន ហើយដឹកទៅសៀមរាបដែលមានន័យថា យកទៅសម្លាប់។ ពីរគឺមានអតីតយោធាខ្មែរក្រហមម្នាក់ឈ្មោះ **ហៀន ហំ** (បច្ចុប្បន្នរស់នៅភូមិថ្នល់ ឃុំគោកធ្លកលើ) បាននិយាយថាកាលពីដើមឆ្នាំ ១៩៧៩ នាព្រំដែនកម្ពុជាថៃក្នុងស្រុកសំពៅលូនខេត្តបាត់ដំបង ក្នុងគ្រាដែលទ័ពខ្មែរក្រហមប្រមូលផ្តុំគ្នា ដើម្បីវាយបកទ័ពវៀតណាមវិញ គាត់បានជួបកម្មាភិបាលម្នាក់ឈ្មោះ **សុក** ដែលអះអាងប្រាប់គាត់ថាធ្លាប់បានធ្វើជាគណៈស្រុកជីក្រែងខេត្តសៀមរាប។

លោកទូច ទ្រី បច្ចុប្បន្ននេះជាមេឃុំគោកធ្លកលើបានដំណាលថា ម្តងនោះគាត់បានចងអង្រឹងដេកទល់ក្បាលគ្នាជាមួយ**តាសុក** បានឆ្លៀតសួរថា «សមមិត្តអ៊ំ! កាលពីមុន យើងប្តូរស្លាប់រស់ធ្វើបដិវត្តន៍ទាំងអស់គ្នា ហេតុអ្វីពេលនេះ ចោទគ្នាថាក្បត់ទៅវិញ?» តាសុកឆ្លើយថា **«ពូជសំពោច និងស្កាវស៊ីមាន់ដូចតែគ្នាទេ។ ថ្ងៃនេះយើងចោទគេថាក្បត់ ថ្ងៃក្រោយនឹងមានគេផ្សេងចោទយើងថាក្បត់វិញម្តង»**។

នាខែមេសាឧសភាឆ្នាំ១៩៧៧ **តាហុន**ដែលជាប្រធានគណៈតំបន់ដ៏កាចសាហាវ ក៏ត្រូវចាប់ខ្លួនពីបទជាប់ខ្សែរយៈជាមួយ **ហ៊ូ នឹម** រដ្ឋមន្ត្រីក្រសួងឃោសនាការ។ អ្នកថ្មីដែលមកជំនួសគឺ **តាសែ** ហើយក្រោយមកក៏មានអ្នកផ្សេងចោទ **តាសែ** ថាក្បត់។ ពួកទាំងអស់ហ្នឹងជា**សត្វសំពោច និងស្កាវដែលស៊ីមាន់ដូចតែគ្នា**ដូចតាសុកថាអញ្ចឹង។

រូបក្របមុខ៖
នារីកំពុងធាក់រហាត់ទឹកបញ្ចូលស្រែក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-៧៩)
ថតដោយ ហ្គុនណា បឺយស្រ្តម ជនជាតិស៊ុយអែត ឆ្នាំ១៩៧៨។
(ហ្គុនណា បឺយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
នារីនៅកងចល័តកំពុងបោចស្មៅនៅវាលស្រែ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-៧៩)
ថតដោយ ហ្គុនណា បឺយស្រ្តម ជនជាតិស៊ុយអែត ឆ្នាំ១៩៧៨។
(ហ្គុនណា បឺយស្រ្តម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 248, August 2020 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.